ព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ការរក្សាព្រៃសម្រាប់កប់សាកសព ការសែនព្រេនពេលមានសមាជិកគ្រួសារឈឺថ្កាត់នានា ពេលមុននិងក្រោយពេលប្រមូលផលស្រូវ ឬដំណាំចំការនានា និងការប្រារព្ធនូវពិធី តាមបែបជនជាតិនៅពេលចូលឆ្នាំថ្មី (ធ្វើនៅពេលដូចគ្នានឹងជនជាតិខ្មែរ និងមានលក្ខណៈស្រដៀងគ្នា តែខុសគ្នាត្រង់ពួកគាត់មិនទៅវត្ត)។ ដោយឡែក របៀបរបបក្នុងការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិត មួយចំនួនធំ ត្រូវបានបងប្អូនជនជាតិដើមភាគតិចធ្វើការផ្លាស់ប្តូរហើយ។ ការផ្លាស់ប្តូរទាំងនោះរួមមាន៖ ការចេះធ្វើការលក់ដូរនូវផលិតផល ការចេះដើរស៊ីឈ្នួលគេដើម្បីរកចំណូលចូលគ្រួសារ ចេះកាប់ឈើលក់ ការកាត់បន្ថយនូវរបៀបធ្វើស្រែ និងចំការតាមបែបពាណិជ្ជកម្ម។

សេចក្តីសង្ខេបស្តីពីហេតុប៉ះពាល់ដែលនឹងអាចកើតមានចំពោះធនធានសង្គមទាំងនេះ ព្រមទាំង វិធានការកាត់បន្ថយមានបង្ហាញនៅក្នុងតារាងខាងក្រោម ហើយព័ត៌មានលម្អិតមានរៀបរាប់ក្នុងជំពូក៧។

Draft

តារាងសង្ខេបធនធានបរិស្ថាន ហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ តាមដំណាក់កាលនៃគម្រោង

ធនធានបរិស្ថាន	ហេតុប៉ះពាល់អវិជ្ជមាន	ទំហំ			វិធានការកាត់បន្ថយ	ដំណាក់កាល	
		ត	ម	ធ		ម.ប្រ	ប្រតិ
ធនធានរូបសាស្ត្រ							
សណ្ឋានដី និងហ៊ុនលេខា							
– ទីតាំងគម្រោងលាតសន្ធឹងលើផ្ទៃដីទំហំ ៦.៥០៩ ហ.ត ដែលមានសណ្ឋានដីស្ទើរពបស្មើ នឹងរយៈកម្ពស់ចែកជា៥តំបន់ដូចខាងក្រោម៖ • ៨០ ទៅ ៩០ ម៉ែត្រ ប្រមាណ ១៤២.៨១ ហ.ត ឬ ២.១៩% • ៩០ ទៅ ១០០ ម៉ែត្រ ប្រមាណ ៣,៦៤៨.១១ ហ.ត ឬ៥៦.០៤% ១០០ ទៅ ១២០ ម៉ែត្រ ប្រមាណ ២,៦៤៣.៤៥ ហ.ត ឬ ៤០.៦១% • ១២០ ទៅ ១៤០ ម៉ែត្រ ប្រមាណ ៧១.៩០ ហ.ត ឬ ១.១០% • ១៤០ ទៅ ២០០ ម៉ែត្រ ប្រមាណ ៣ ហ.ត ឬ ០.០៥%	– ការប្រែប្រួលដោយសារសកម្មភាពឈូសឆាយពង្រាបដីដើម្បីធ្វើផ្លូវក្រវ៉ាត់ព្រំ ប្រព័ន្ធផ្លូវប្រើប្រាស់ក្នុងតំបន់គម្រោង ផ្លូវបែងចែកឡូត៍ និងអនុតំបន់ ផ្ទះកម្មករ និងសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដែលមានទំហំសរុបប្រមាណ ៣៨៣ ហិកតា ឬ ៥,៩% នៃផ្ទៃដីគម្រោង	✓			ធ្វើការឈូសឆាយ និងរៀបចំដីទៅតាមលក្ខណៈសណ្ឋានដី និងទៅតាមទំហំដូចដែលបានគ្រោងក្នុងផែនការ	✓	✓
					ធ្វើការឈូសឆាយតែក្នុងរដូវប្រាំង និងរៀបចំដាំដំណាំភ្លាមៗក្រោយពីឈូសឆាយរួច ដើម្បីកាត់បន្ថយកម្រិត និងរយៈពេលនៃការហូរច្រោះ		✓
					មិនឈូសឆាយឬ កាប់ឆ្ការព្រៃនៅតាមតំបន់ទ្រនាប់អូរ ឬក្បែរមាត់ទឹក (រក្សាគម្របព្រៃឱ្យបានពី ១០០ម ទៅ ១៥០ម ពីប្រភពទឹក)		✓
					ជួយគាំពារព្រៃទ្រនាប់នានាដែលមាននៅក្នុងទីតាំងគម្រោង ដើម្បីការពារទីជម្រាល និងទប់ស្កាត់ការហូរច្រោះដី និងបាក់ច្រាំង		✓
					កាប់ឆ្ការព្រៃ ឈូសឆាយដី និងរៀបចំថ្នាលដំណាំ ជាដំណាក់កាលនៅត្រង់តំបន់ដែលមានជម្រាលខ្លាំង ហើយចាប់ផ្តើមធ្វើពីតំបន់ដែលមានរយៈកម្ពស់ខ្ពស់មុន ដើម្បីជៀសវាងការបាក់ដី		✓
					រៀបចំផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោងឱ្យមានទំហំសមស្រប ដើម្បីជានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ សំដៅជៀសវាងការអូសបន្លាយពេលសាងសង់ និងដាំដុះ (ឬទុកដីនៅទំនេរ) ដែលអាចនឹង	✓	✓

Draft

					បង្កឲ្យមានការហូរច្រោះដីកើតឡើង		
					ណែនាំអ្នកបើកបរមិនឱ្យដឹកជញ្ជូនលើសទម្ងន់ ដែលនាំឱ្យមានការបាក់ខូងផ្លូវ និងការហូរដីចេញពីផ្លូវជាពិសេសនៅរដូវស្សា		✓
គុណភាពដី							
– មួយភាគធំនៃដីក្នុងតំបន់គម្រោងគឺជាដីដែលមានដីជាតិខ្ពស់សម្រាប់ដាំដុះដំណាំគ្រប់ប្រភេទ និងមានគម្របព្រៃឈើពណ៌បៃតងគ្រប់រដូវ។ – ប្រភេទដីក្នុងតំបន់គម្រោងមានចំនួន ០៣ប្រភេទ គឺ៖ Acid Lithosols មានចំនួន ២,២១៥.០៩ហ.ត (៣៤.០៣%), Gray hydromorphic មានចំនួន ៣,៤៦០.១៤ហ.ត (៥៣.១៦%) និង Plinthite podzols មានចំនួន៨៣៤.០៣ហ.ត (១២.៨១%) – គុណភាពដីនាពេលបច្ចុប្បន្នមានដូចតទៅ៖ • pH៖ ប្រែប្រួលពី ៤,៥១ ទៅ ៥,៦០ • សារធាតុសរីរាង្គមានប្រមាណពី ០,០៩% ទៅ ០,២៣ % • Copper មានកំហាប់ចន្លោះពី ០,០៤ ទៅ ១,២៤ ug/g. dry • Zinc មានកំហាប់ចន្លោះពី ០,០៤ ទៅ ០,៧៦ ug/g. dry • កំហាប់ Lead, Cadmium និងArsenic មានតិចតួច • កំហាប់ Total nitrogen ប្រែប្រួលពី ០,០២ ទៅ ០,០៦%	– ដីផលិតកម្មដំបូង (Primary Industry) ប្រមាណ ៣៨៣ ហិកតា ឬ៥,៩% នៃផ្ទៃដីគម្រោងសរុបនឹងត្រូវបាត់បង់នៅក្នុងដំណាក់កាលសាងសង់ ដោយសាការបំលែងឲ្យជាដីហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ – បម្រែបម្រួលគុណភាពដី ដោយសារតែការគ្រប់គ្រងសំណល់រឹង រាវ មិនបានល្អ និងការប្រើប្រាស់មិនបានត្រឹមត្រូវតាមបច្ចេកទេស និងលើសពីតម្រូវការ នូវដីគីមី ថ្នាំសម្លាប់សត្វល្អិត ឬស្មៅ ព្រមទាំងការសឹករេចរឹលនៃដីស្រទាប់លើដោយសារតែការទុកដីទំនេរចោល ក្រោយពីការឈូសឆាយដីព្រៃរួច នៅក្នុងដំណាក់កាលប្រតិបត្តិ។	✓			សាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅលើប្រភេទដីដែលមានគុណភាពទាប ឱ្យបានច្រើនជាអតិបរិមា	✓	
					ធ្វើការឈូសឆាយរៀបចំដីទៅតាមទំហំដីដែលបានគ្រោង ដើម្បីជៀសវាងការបាត់បង់ដីផលិតកម្មដំបូងលើសពីផ្ទៃដីហេដ្ឋារចនាសម្ព័ន្ធគម្រោង	✓	
					បកយកដីស្រទាប់លើដែលមានជីជាតិ ដើម្បីចាកគ្របលើទីតាំងជុំវិញសំណង់អគារ និងរៀបចំទីតាំងទាំងនោះទៅជាសួនច្បារ ឬដាំរុក្ខជាតិ ដើមឈើលម្ហនៅជុំវិញសំណង់អគារទាំងនោះ	✓	
					រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង	✓	✓
					ធ្វើការឈូសឆាយតែក្នុងផ្លូវប្រាំង និងរៀបចំដាំណាំភ្លាមៗក្រោយពីឈូសឆាយរួច ដើម្បីកាត់បន្ថយកម្រិត និងរយៈពេលនៃការហូរច្រោះ	✓	✓
					រៀបចំផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោងឱ្យមានទំហំសមស្រប ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ សំដៅជៀសវាងការអូសបន្លាយពេលសាងសង់ និងដាំដុះ (ឬទុកដីនៅទំនេរ) ដែលអាចនឹងបង្កឲ្យមានការហូរច្រោះដីកើតឡើង		✓
					រៀបចំទីតាំងចម្ការដំណាំឱ្យមានប្រព័ន្ធបង្ហូរទឹកត្រឹមត្រូវ និងអនុវត្តការក្ខ្លួរាស់តាមបច្ចេកទេសដែលមាន		✓

• កំហាប់ Ammonia ប្រែប្រួលពី ០,០២ ទៅ ០,០៨% • កំហាប់ Copper ប្រែប្រួលពី ០,០០៤ ទៅ ១.២៤ ug/g dry; • កំហាប់ Nitrites មាន តិចតួច • កំហាប់ Phosphorus មិនត្រូវបានរកឃើញឡើយ					មេត្រីភាពបរិស្ថាន (ឧ. មិនក្លិនរាស់ជ្រៅពេក ក្លិនរាស់ជាលក្ខណៈកាំជណ្តើរ ជាពិសេសនៅទីតាំងដែលមានជម្រាលខ្ពស់)		
					ប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវកំទេចកំទីមែក ឬស្លឹករុក្ខជាតិដែលបានកាប់ឆ្ការ ជាគម្របដី ដើម្បី កាត់បន្ថយការហូរច្រោះ និងរំហួត និងផ្តល់ជីជាតិដល់ដី		✓
					ប្រើប្រាស់តែជីគីមីកសិកម្ម ថ្នាំសម្លាប់សត្វល្អិត ឬស្មៅ ដែលមានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ		✓
					រៀបចំផែនការប្រើប្រាស់ដីឱ្យបានច្បាស់លាស់ និងអនុវត្តតាមផែនការនេះឲ្យបានខ្ជាប់ខ្ជួន ដើម្បីជៀសវាងការប្រើប្រាស់ដីគីមីលើសកម្រិតដែលបណ្តាលឲ្យខូចគុណភាពដី		✓
					កាត់បន្ថយការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ដោយការរៀបចំ និងអនុវត្តផែនការត្រៀមដើម្បីទប់ស្កាត់កំណើនលើសលប់នៃចំនួនសត្វល្អិត (avoid the outbreak occurs)		✓
					ដាំដុះបន្ថែមនូវប្រភេទដំណាំបន្ទាប់បន្សំ ដូចជាពោត សណ្តែក ឬពពួកបន្លែបង្គារនានា នៅតាមចន្លោះរង ឬនៅក្នុងចន្លោះពេលសម្អាតថ្នាលបន្ទាប់ពីពេលប្រមូលផលដំណាំចម្បងរួច ធ្វើជាគម្របដីដើម្បីកាត់បន្ថយការហូរច្រោះ និងបាត់បង់ដីជាតិដី		✓
ប្រព័ន្ធដលសាស្ត្រ							
– ក្រៅពីទន្លេសេសាន នៅក្នុងតំបន់គម្រោងមានប្រព័ន្ធផ្លូវទឹកសំខាន់ៗចំនួន ០៧គឺ៖ អូរភ្នំ, អូរតាង, ពាមមាត់អូរ, អូរតាឡាត, អូរដរិក និងអូរស្វាយរៀង	– ប្រព័ន្ធផ្លូវទឹក អាចនឹងមានការប្រែប្រួលទ្រង់ទ្រាយខ្លះៗ ដោយសារតែការឈូសឆាយដីព្រៃ ដើម្បីធ្វើប្រព័ន្ធផ្លូវ សង់ផ្ទះ	✓			សាងសង់ស្ពានឆ្លងកាត់ ឬរៀបចំប្រព័ន្ធលូបង្ហូរឱ្យបានត្រឹមត្រូវ ក្នុងករណីសាងសង់ហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ប្រព័ន្ធផ្លូវទឹក	✓	

Draft

– អូរកន្សែង គឺជាអូរដែលសំខាន់បំផុត ព្រោះជាប្រភពទឹកសម្រាប់ប្រជាជនក្នុងតំបន់ និងជាកន្លែងគោរពបូជារបស់ជនជាដើមភាគតិច។	ស្នាក់នៅ ការដ្ឋានក្រុមហ៊ុន ឬសំណង់អគារផ្សេងៗទៀត នៅដំណាក់កាលសាង់សង់។ – បម្រែបម្រួលទ្រង់ទ្រាយអូរ ឬប្រលាយដោយសារតែការស្តារឡើងវិញ ឬសាង់សង់ទំនប់ទប់ទឹក ទុកសម្រាប់ប្រើប្រាស់នៅរដូវប្រាំង។				សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញមានសមត្ថកិច្ច ដើម្បីវាយតម្លៃ និងផ្តល់អនុសាសន៍បច្ចេកទេស ក្នុងករណីដែលក្រុមហ៊ុនធ្វើទំនប់ស្នាក់ទឹក	✓	✓
					សាងសង់សំណង់ផ្សេងៗនៅចម្ងាយយ៉ាងហោចណាស់ ១០០ម. ទៅ១៥០ម. ពីអូរ និងប្រព័ន្ធផ្លូវទឹកនានា ដើម្បីការពារការហូរច្រោះដី និងកំទេចកំទីមែកឈើ ស្លឹកឈើ ចូលទៅក្នុងប្រព័ន្ធផ្លូវទឹកទាំងនោះ	✓	
					សិក្សាពីស្ថានភាពសមតុល្យទឹកក្រោមដីឲ្យបានច្បាស់លាស់ មុននឹងធ្វើការខូង ឬបូមយកទឹកពីប្រភពទឹកក្រោមដី មកប្រើប្រាស់		✓
គុណភាពទឹក							
– បច្ចុប្បន្នគុណភាពទឹកនៅក្នុងអូរទាំងអស់នៅក្នុងតំបន់គម្រោងគឺមានភាពល្អជម្មតា។ កំហាប់នៃប៉ារ៉ាម៉ែត្រដែលបានវិភាគទាំងអស់គឺមានកម្រិតទាបគោរពទៅតាមស្តង់ដារ លើកលែងតែកំហាប់ TP និង TN នៅត្រង់ទីតាំងខ្លះដែលមានកំហាប់លើសស្តង់ដារ។ កម្រិតកំហាប់នៃប៉ារ៉ាម៉ែត្រសំខាន់មួយចំនួនមានដូចខាងក្រោម៖ • DO ប្រែប្រួលពី ៣.៦៦ ទៅ ៥.៨០ mg/l • TSS ប្រែប្រួលពី ១៥ ទៅ ៤៩ mg/l • Cl^- ប្រែប្រួលពី ០.៩៧ ទៅ ៨.០៥ mg/l • BOD_5 ប្រែប្រួលពី ០.៨៤ ទៅ ៤.៩២ mg/l • COD_{Mn} ប្រែប្រួលពី ១.៥៦ ទៅ ១១.៧៦ mg/l • Heavy metal មានតិចតួ • Total coliform ប្រែប្រួលពី ១៥០ ទៅ 930	– គុណភាពទឹកអាចនឹងធ្លាក់ចុះទាំងនៅក្នុងដំណាក់កាលមុនប្រតិបត្តិ និងនៅដំណាក់កាលប្រតិបត្តិដោយសារតែ៖ ការឈូសឆាយព្រៃឈើតាមមាត់អូរ ការគ្រប់គ្រងសំណល់រឹង រាវ មិនបានល្អ ការហូរជ្រាបនៃដីគីមី ថ្នាំសម្លាប់សត្វល្អិតនិងស្មៅ ចូលទៅក្នុងប្រភពទឹកដោយសារការប្រើប្រាស់ខុសបច្ចេកទេស ឬលើសតម្រូវការ និងការចោលកាកសំណល់សំបកកំប៉ុងថ្នាំពស់វាលពស់កាល		✓		ធ្វើការឈូសឆាយតែក្នុងរដូវប្រាំង និងសាងសង់ ដាំដុះភ្លាមៗដោយមិនទុកដីឲ្យនៅទំនេរចោល ដើម្បីការពារ ឬកាត់បន្ថយការហូរច្រោះដីចូលទៅក្នុងប្រភពទឹក	✓	✓
					រក្សាទុកព្រៃតាមទ្រនាប់ដងអូរ និងតំបន់មាត់ទឹក ក្នុងចម្ងាយពី ១០០ម. ទៅ១៥០ម. សងខាង ដើម្បីការពារការហូរច្រោះដី និងការហូរនាំនូវសំណល់ផ្សេងៗចូលទៅក្នុងប្រភពទឹក	✓	✓
					ជៀសវាងការដាក់ដី ឬបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅ មុនពេលដែលទំនងជាមានភ្លៀងធ្លាក់ ដើម្បីកាត់បន្ថយការហូរនាំសារធាតុទាំងនេះចូលទៅក្នុងប្រភពទឹក។		✓
					រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង	✓	✓

MPN/100ml					តាមដានគុណភាពទឹកតាមរយៈការយកសំណាកទឹកទៅពិនិត្យនៅមន្ទីរពិសោធន៍ឱ្យបានទៀងទាត់ (២ដង/ឆ្នាំ) និងសហការជាមួយស្ថាប័នមានសមត្ថកិច្ច ក្នុងការស្វែងរក និងអនុវត្ត វិធានការចាំបាច់នានា ក្នុងករណីពិនិត្យឃើញថាគុណភាពទឹកមានបម្រែបម្រួលជាអវិជ្ជមាន ដើម្បីកែលម្អ ឬស្តារគុណភាពទឹកឲ្យបានល្អប្រសើរឡើងវិញ	✓	✓
គុណភាពខ្យល់							
– គុណភាពខ្យល់នៅក្នុងទីតាំងគម្រោងនាពេលបច្ចុប្បន្នមិនមានការបំពុលដែលលើសកម្រិតស្តង់ដារឡើយ។ កំហាប់នៃប៉ារ៉ាម៉ែត្រសំខាន់ៗមួយចំនួនមានដូចខាងក្រោម៖ – CO មានកំហាប់ ១ mg/m^3 – NO_2 មានកំហាប់ 0.0១៨ mg/m^3 – SO_2 មានកំហាប់ 0.0១ mg/m^3 – TSP មានកំហាប់ 0.២៧៥ mg/m^3 – PM10 មានកំហាប់ 0.១៨0 mg/m^3	– គុណភាពខ្យល់ នឹងអាចមានការធ្លាក់ចុះក្នុងកម្រិតតិចតួច ដោយសារការសាយភាយធូលី ផ្សែង និងឧស្ម័នផ្សេងៗចូលទៅក្នុងបរិយាកាស តាមរយៈសកម្មភាពឈូសឆាយ ឬការដឹកជញ្ជូនសម្ភារៈសំណង់ នឹងការការដឹកជញ្ជូនកសិផលដោយប្រើប្រាស់គ្រឿងចក្រ គ្រឿងម៉ាស៊ីនផ្សេងៗ ព្រមទាំងការដុតសំណល់រឹង និងសំណល់កំទេចកំទីមែកឈើ ជាដើម។	✓			ធ្វើការឈូសឆាយដីព្រៃដើម្បីសាងសាង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ តាមដំណាក់កាលដែលបានកំណត់ក្នុងផែនការមេ រួចធ្វើការបង្ហាប់ដីឆ្លាម និងសាងសង់ ដោយដោយមិនទុកដីឲ្យនៅទំនេរចោល	✓	
					ជៀសវាងការដុតសំណល់គ្រប់ប្រភេទ ដោយអនុវត្តទៅតាមផែនការគ្រប់គ្រងសំណល់រឹង និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវកំទេចកំទីមែកឈើ និងសំណល់កសិកម្មក្នុងដំណើរការដាំដុះ	✓	✓
					សាងសង់សំណង់ផ្សេងៗនៅចម្ងាយពី ១00ម. ទៅ ១៥0ម. ពីអូរ ដើម្បីរក្សាទុកព្រៃមាត់អូរឲ្យជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទ្ធខ្យល់	✓	
					ធ្វើការស្រោចទឹក និងបង្ហាប់ដីឲ្យអស់លទ្ធភាពនៅពេលឈូសឆាយស្ថាបនាផ្លូវនានា	✓	
					គ្រប់គ្រង និងថែទាំគ្រឿងចក្រ យានជំនិះឱ្យបានល្អ និងទៀងទាត់ (ឧ. ប្តូរប្រេងរំអិល បំពាក់គម្រងចម្រោះឧស្ម័នពុល) ដើម្បីកាត់បន្ថយ	✓	✓

					បរិមាណឧស្ម័នបំភាយចូលបរិយាកាស		
					អប់រំ-ណែនាំឱ្យប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន ឲ្យមានប្រសិទ្ធិភាព ដោយជៀសវាងនូវការបញ្ចេះម៉ាស៊ីនទុកចោលនៅពេលដែលមិនចាំបាច់ ឬរោទ៍ខ្លាំងពេក	✓	✓
					ពិនិត្យតាមដានកម្រិតនៃការបញ្ចេញឧស្ម័នបំពុលពីគ្រឿងចក្រ និងយានយន្តដែលប្រើប្រាស់ក្នុងដំណើរការគម្រោង ព្រមទាំងធ្វើការជួសជុល ឬផ្លាស់ប្តូរថ្មីនូវគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញឧស្ម័នបំពុលលើសកម្រិតស្តង់ដារ	✓	✓
					កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសម្ភារសំណង់ បរិក្ខាផ្សេងៗ និងកសិផល ចេញ-ចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាសារៀន ជាដើម	✓	✓
					រក្សាទុកដើមឈើនៅតាមព្រំទីតាំងគម្រោងដើម្បីដើម្បីជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទខ្យល់		✓
សំឡេង-រំញ័រ							
– កម្រិតសំឡេង នឹងរំញ័រនាពេលបច្ចុប្បន្ន គឺស្ថិតនៅក្រោមកម្រិតស្តង់ដារ អតិបរមាដែលអនុញ្ញាតឱ្យបញ្ចេញនៅតំបន់លំនៅដ្ឋាន	– ការរំខានដោយសំឡេង នឹងរំញ័រអាចនឹងកើតឡើងដោយសារសកម្មភាពមួយចំនួនដូចជា៖ សំឡេងចេញពីរណារយន្តអារឈើសម្លេងគ្រឿងចក្រឈូសឆាយ ម៉ាស៊ីនភ្លើង និងម៉ាស៊ីនផ្សេងៗទៀតដែលគាំទ្រដល់សកម្មភាពគម្រោង ព្រមទាំងសំឡេងចេញពីរថយន្តដឹកជញ្ជូនសម្ភារសំណង់ និងសម្ភារបរិក្ខាផ្សេងៗ ។ល។	✓			អនុវត្តការងារជីងជញ្ជួន ឈូសឆាយ សាងសង់ និងដាំដុះ តែពេលថ្ងៃ ដោយជៀសវាងអនុវត្តការងារនៅពេលយប់	✓	✓
					ប្រើប្រាស់គ្រឿងចក្រ និងយានយន្ត ដែលមានបំពាក់ឧបករណ៍កាត់បន្ថយសំឡេង ឬមានការបញ្ចេញសំឡេងគោរពតាមស្តង់ដារកំណត់	✓	✓
					ពិនិត្យតាមដានកម្រិតនៃការបញ្ចេញសំឡេងរំខានពីគ្រឿងចក្រ និងយានយន្ត ព្រមទាំងធ្វើ	✓	✓

Draft

					ដែលបានកាត់ចេញ ព្រៃសហគមន៍ ដងផ្លូវ និងតំបន់សាធារណៈផ្សេងទៀត		
					ចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពរបស់ស្ថានីយ៍បណ្តុះកូនឈើ របស់ផ្នែករដ្ឋបាលព្រៃឈើវ៉ឺនសៃ ដើម្បីផ្គត់ផ្គង់កូនឈើសម្រាប់ការដាំដុះក្នុងតំបន់	✓	✓
ធនធានសត្វព្រៃ							
– វត្តមានរបស់សត្វព្រៃនៅក្នុង និងក្បែរទីតាំងគម្រោងសរុបទាំងអស់មានចំនួនប្រមាណ ៣៥១ប្រភេទ ដែលក្នុងនោះរួមមានថនិកសត្វចំនួន ៥៣ប្រភេទ, ល្មូន/ឧង្គេសត្វចំនួន ៩៤ប្រភេទ, និងបក្សីចំនួន ២០៤ប្រភេទ – យោងតាមប្រកាសលេខ ក.ស.ក ២០០៧៖ ប្រភេទកំពុងរងគ្រោះថ្នាក់ជិតផុតពូជ (EN) មាន ១២ប្រភេទ, ប្រភេទមានដោយកម្រ (R) មាន ៤០ប្រភេទ, ប្រភេទមានដោយបង្គួរ (C)នាម ២៩៦ប្រភេទ និងប្រភេទមិនទាន់ចាត់ថ្នាក់ (NA) មាន៣ប្រភេទ	– សត្វព្រៃប្រមាណ ៣៥១ប្រភេទដែល មានវត្តមាននៅតំបន់គម្រោងអាចនឹងរងផលទាំងដោយផ្ទាល់ ឬដោយប្រយោល នឹងនៅក្នុងរយៈពេលយូអង្វែង ដោយសារបុព្វហេតុមួយចំនួនដូចជា៖ ការបាត់បង់ជម្រក និងប្រភពចំណីដោយសារការកាប់ឆ្ការព្រៃដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោ ការរំខានដែលបង្កដោយសម្លេងគ្រឿងចក្រ និងយានយន្ត ក្នុងកិច្ចដំណើរការសាងសង់នានា និងការគំរាមកំហែងដោយសារសកម្មភាពបរបាញ់ខុសច្បាប់ពីសំណាក់បុគ្គលិក-កម្មករគម្រោង នឹងសកម្មភាពបរបាញ់ខុសច្បាប់ដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។					
					ធ្វើការឈូសឆាយ សាងសង់ និងដាំដុះ ជាដំណាក់ៗតាមអនុតំបន់ដូចមានក្នុងផែនការរបស់គម្រោង ដើម្បីទុកផ្លូវ និងពេលវេលាឲ្យសត្វព្រៃធ្វើការសៀសខ្លួនទៅកាន់តំបន់ផ្សេងៗ	✓	✓
					ពន្លឿនការដាំដំណាំឡើងវិញនៅក្នុងអនុតំបន់របស់គម្រោងឲ្យបានឆាប់រហ័ស ដើម្បីបង្កើតជាជម្រកថ្មីដល់ប្រភេទសត្វព្រៃមួយចំនួន		✓
					ចូលរួមធ្វើការដាំដើមឈើនៅក្នុងព្រៃសហគមន៍ និងព្រៃឈើរក្សាទុក ដើម្បីជាជម្រកនៃប្រភេទសត្វព្រៃ		✓
					កាត់បន្ថយឲ្យអស់លទ្ធភាពនូវការរំខានដោយសំឡេង-រំញ័រ តាមរយៈការប្រើប្រាស់គ្រឿងចក្រ ឬយានយន្តដែលបញ្ចេញសម្លេង-រំញ័រតិច	✓	✓
					អប់រំ និងហាមឃាត់បុគ្គលិក-កម្មករគម្រោង និងបុគ្គលិក-កម្មកររបស់អ្នកមៅការ (ឈូសឆាយ សាងសង់ និងដាំដុះ) មិនឲ្យធ្វើការបរបាញ់ប្រភេទសត្វព្រៃដែលមាននៅក្នុងតំបន់ដោយខុសច្បាប់ ព្រមទាំងធ្វើការផ្សព្វផ្សាយឲ្យពួកគាត់បានដឹងពីអត្ថប្រយោជន៍សត្វព្រៃ	✓	✓

					ដាក់បំរាមមិនឲ្យបុគ្គលិក-កម្មករ បរិភោគសាច់សត្វព្រៃ និងមិនអនុញ្ញាឱ្យទិញសាច់ ឬសត្វព្រៃពីអ្នកលក់ ឬពីប្រជាពលរដ្ឋមូលដ្ឋាន	✓	
					លើកទឹកចិត្តដល់បុគ្គលិក-កម្មករ (ផ្តល់ជាង្វាន់) ឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ចក្នុងករណីសង្កេតឃើញមានការលួចបរបាញ់ខុសច្បាប់	✓	
					ធ្វើការផាកពិន័យតឹងរឹង (ឧ. ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងការណីបុគ្គលិក-កម្មករណាមួយប្រព្រឹត្តិបទល្មើសនឹងបំរាមពាក់ព័ន្ធនឹងការបរបាញ់ និងបរិភោគសត្វព្រៃ	✓	
ធនធានមច្ឆជាតិ							
– នៅក្នុង និងក្បែរតំបន់គម្រោង មានវត្តមានមច្ឆជាតិចំនួន ២៨៣ប្រភេទ ដែលក្នុងនោះមានពពួកវាវីសត្វចំនួន ១១ប្រភេទ – អនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ៖ ប្រភេទជិតផុតពូជ (EN) មាន ៩ប្រភេទ, ប្រភេទកំពុងរងគ្រោះថ្នាក់ (CR) មាន ៤ ប្រភេទ, ប្រភេទងាយរងគ្រោះថ្នាក់ (VU) មាន ៣ប្រភេទ , ប្រភេទមិនទាន់បានចាត់ថ្នាក់ជាប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ (NA) មាន ២២៧ ប្រភេទ	– មច្ឆជាតិប្រមាណ ២៨៣ប្រភេទ ដែលមានវត្តមាននៅក្នុងតំបន់គម្រោងអាចនឹងរងផលប៉ះពាល់ ដោយសារការធ្លាក់ចុះនៃគុណភាពទឹកក្នុងអូរដែលបង្កឡើងដោយការហូរច្រោះដីល្បាប់ពីទីតាំងការដ្ឋានសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការបំពុលទឹកដែលកើតឡើងដោយសារការគ្រប់គ្រងកាកសំណល់រឹង រាវ មិនបានត្រឹមត្រូវតាមបច្ចេកទេស ការស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹក និងការសាងសង់ស្រះ ឬអាងស្តុកទឹកដែលនឹងធ្វើឱ្យមានការប្រែប្រួលចរន្តទឹក និងការរេសាទខុសច្បាប់ពីសំណាក់បុគ្គលិក-កម្មករគម្រោង		✓		ជៀសវាងការរំខានដល់កន្លែង ឬតំបន់ដែលជម្រកមច្ឆជាតិសំខាន់ៗ ក្នុងករណីដែលក្រុមហ៊ុនស្តារប្រព័ន្ធផ្លូវទឹកទោះជាក្នុងគោលបំណងអ្វីក៏ដោយ	✓	
					ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹកដែលមាននៅក្នុង និងក្បែរទីតាំងតំបន់គម្រោង ក្នុងរយៈពេល១ឆ្នាំម្តង	✓	
					ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបានលួចរេសាទត្រីខុសច្បាប់ និងលើកទឹកចិត្តដល់បុគ្គលិក-កម្មករឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានសកម្មភាពលួចធ្វើការរេសាទត្រីខុសច្បាប់	✓	
					រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង	✓	

2. សេដ្ឋកិច្ច-សង្គម							
កម្មសិទ្ធិដីធ្លី និងការប្រើប្រាស់ដី							
▪ មុខរបរចំបងៗរបស់ប្រជាពលរដ្ឋ ភាគច្រើនស្ថិតក្នុងវិស័យ កសិកម្ម និងការស្វែងរកផល និងអនុផលព្រៃឈើ ដែលពឹងផ្អែកលើការមានដីធ្លី ▪ ទំនៀមទំលាប់ និងប្រពៃណីរបស់ជនជាតិដើមភាគតិចសំខាន់ៗក្នុងឃុំនៅរក្សាបាន មួយចំនួន ធំដូចជា៖ ប្រពៃណីគោរពព្រៃ អារក្ស ការការពារ ព្រៃបម្រុងទុកសម្រាប់ កូនចៅជំនាន់ក្រោយ ការរក្សាព្រៃសម្រាប់ កប់សាកសព ការសែនព្រេនពេលមាន សមាជិក គ្រួសារឈឺថ្កាត់នានា ពេលមុននិងក្រោយ ពេលប្រមូលផលស្រូវ ឬដំណាំចំការនានា និងការប្រារព្ធនូវពិធី តាមបែបជនជាតិ នៅពេលចូលឆ្នាំថ្មី។ល។	▪ ដំណើរការកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន បានប៉ះពាល់ដល់ព្រៃសហគមន៍ ព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ព្រៃអារក្ស ផ្លូវដួនតា ប្រភពទឹកធម្មជាតិ ដីស្រែ-ចម្ការ ជាពិសេសចម្ការរំលងជុំរបស់គ្រួសារជនជាតិដើមភាគតិចនិងគ្រួសារខ្មែរមួយចំនួន (ភូមិប៉ង់ និង ភូមិហ្វាំង ឃុំហាតប៉ក់ និង ភូមិពែត់ និង ភូមិតាឡាត ឃុំតាឡាត) ។			✓	សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំ និងផ្សព្វផ្សាយអំពីគោលការណ៍ក្នុងការដោះស្រាយទំនាស់ដល់ប្រជាពលរដ្ឋ	✓	
					ធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងប្រជាពលរដ្ឋដែលមានដីធ្លីជាប់ព្រំទីតាំងគម្រោង ដើម្បីផ្តល់ជាព័ត៌មានលម្អិតស្តីពីព្រំ ប្រទល់គម្រោង	✓	
					ធ្វើការបង្ហាញដល់ប្រជាជន នូវដំណើរ ការវិនិយោគនេះ តាំងពីដំណាក់កាល ស្នើសុំរាជរដ្ឋាភិបាល រហូតដល់ដំណាក់កាល វិនិយោគ និងបញ្ចប់គម្រោង ព្រមទាំងលើក ឡើងនូវាល់វិធានការកាត់បន្ថយ ដើម្បី បញ្ចៀសនូវការប៉ះពាល់អវិជ្ជមាននានា (រួមទាំងការកាត់ចេញនូវផ្នែដីពាក់ព័ន្ធនានាដែលបានធ្វើឡើងកន្លងមក)	✓	
					មិនឈូសឆាយដីហួសពីព្រំដីដែលទទួលបានពីរដ្ឋាភិបាល	✓	✓
					គាំទ្រអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការប្រើប្រាស់ដីក្នុងតំបន់ឲ្យបានសមរម្យ	✓	
					សហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដីធ្លីដែល ប្រជាជននៅតែអះអាងថាមិនទាន់បានដោះស្រាយ (រួមមាន៖ ដីសហគមន៍ជនជាតិដើម ភាគតិចគ្រឹង និងដី ចម្ការរំលងជុំ និងដីបម្រុង ទុក		✓

ម្ចាស់គម្រោង ៖ SK Plantation (Cambodia) Pte. Ltd.

Draft

					សម្រាប់កូនចៅជំនាន់ក្រោយ)		
មុខរបរ និងប្រាក់ចំណូល							
▪ មុខរបរចំបងរបស់ប្រជាពលរដ្ឋមាន៣ប្រភេទ ហើយ មុខរបរចំបង២ប្រភេទស្ថិតក្នុងវិស័យកសិកម្មពឹងផ្អែកលើការមានដីធ្លី៖ ការធ្វើស្រែវស្សារហូតដល់ទៅជិត៦០% ការធ្វើស្រូវ និងចំការប្រមាណ២០% និងមុខរបរក្នុងវិស័យ សេវាកម្ម គឺការលក់ដូរ និងធ្វើការមានប្រាក់ខែមានភាគរយប្រមាណ១០% ▪ ក្រៅពីរបរចំបងទាំងនេះ ប្រជាពលរដ្ឋអាចប្រកបរបរកេ ផល និងអនុផលព្រៃឈើ និងនេសាទបន្ថែម។	▪ អាចនឹងបាត់បង់ឱកាសបង្កើនដីធ្លីសម្រាប់ធ្វើស្រែចំការដោយសារវត្តមានក្រុមហ៊ុន ហើយនឹងអាចបាត់ បង់លទ្ធភាពរកប្រាក់ចំណូល ដោយការបាត់បង់ ផលអនុផលព្រៃឈើ នៅពេលគម្រោងចាប់ផ្តើម ដំណើរការ				រៀបចំ និងអនុវត្ត គម្រោងកសិកម្មបែបកិច្ចសន្យា (គាំទ្របច្ចេកទេសដាំដុះ និងទិញយកកសិផល) ចំពោះមុខដំណាំដែលជាមុខព្រួញនៃគម្រោងវិនិយោគនេះ (ដូចជា កាកាវ ដូង អាកាស្យាសេណេហ្គាល់ សណ្តែកសៀង)		✓
					សហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ ដើម្បីបណ្តុះ បណ្តាលចំណេះដឹង ជំនាញ ចិញ្ចឹមសត្វ និងជំនាញឯកទេសផ្សេងទៀតដល់ប្រជាជនមូលដ្ឋាន		✓
					ផ្តល់ឱកាសសមស្របដល់ប្រជាជន អាចបម្រើការងារនៅក្នុងតំបន់គម្រោង ដោយមានប្រាក់បៀវត្សសមរម្យអាចទទួលយកបានពីសំណាក់ពួកគាត់ ដើម្បីអាចចូលរួម ស្តារស្ថានភាពជីវភាពឡើងវិញ		✓
					ផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានក្នុងការចូលរក និងប្រមូលអនុផលព្រៃឈើជាលក្ខណៈប្រពៃណី (ដូចបានចែងនៅក្នុងច្បាប់ស្តីពី ព្រៃឈើ) ក្នុងព្រៃរក្សាទុក ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់		✓
ការប្រើប្រាស់ទឹក សុខភាព និងអនាម័យក្នុងការរស់នៅរបស់ប្រជាជនមូលដ្ឋាន							
▪ ប្រជាជនរស់នៅជុំវិញ និងក្បែរតំបន់គម្រោងពឹងផ្អែកលើទន្លេសេសាន និងប្រព័ន្ធផ្លូវទឹក សំខាន់ៗចំនួន ០៧គឺ៖ អូរភ្នំ, អូរតាង, ពាមមាត់	▪ ការឈូសឆាយលុបប្រភពទឹកអូរ អាចនឹងកើតមាន ▪ សកម្មភាពឈូសឆាយដីអាចនឹងធ្វើឲ្យមាន		✓		មិនធ្វើទំនប់ស្តាក់ទឹក ឬឈូសឆាយលុប ប្រភពទឹកដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណធារទឹក និងការប្រើប្រាស់ទឹករបស់ប្រជាជន នៅខ្សែទឹក	✓	✓

Draft

អូរ, អូរតាឡាត, អូរជរិក អូរស្វាយរៀង និងអូរកន្សែង (ជាអូរសំខាន់ជាងគេ ព្រោះជា ប្រភពទឹក និងជាកន្លែងគោរពបូជារបស់ ប្រជាជនក្នុងតំបន់)។ ▪ គុណភាពទឹក ទាំងទឹកលើដី និងក្រោមដី ជាទូទៅគឺមានស្ថានភាពល្អធម្មតា និងមិនមានវត្តមានសារធាតុបំពុលអ្វី (pollutants) គួរឲ្យកត់សម្គាល់ឡើយ។	ការហូរ ច្រោះដី កកកុញ ▪ ការបោះចោលសំណល់រឹង និងបង្ហូរសំណល់រាវចូលទៅក្នុងប្រភពទឹក ក៏អាចនឹងធ្វើឲ្យ មាន ការបំពុលប្រភពទឹកប្រើប្រាស់ របស់មនុស្ស និងសត្វ។ល។ ប្រសិនបើ មិនបានអនុវត្តតាមវិធានការត្រឹមត្រូវអាចនឹងមានការបំពុលប្រភពទឹក ▪ ការគ្រោងស្នាក់ទប់ទឹកទុកប្រើតែនៅក្នុងតំបន់គម្រោងនិងសកម្មភាពនៃការឈូសឆាយលុបប្រភពទឹកអូរបស់ក្រុមហ៊ុនអាចនឹងធ្វើឲ្យមានការរំខានដល់ការប្រើប្រាស់ទឹករបស់ប្រជាជនសម្រាប់ដីកោពប្រចាំថ្ងៃ និងសម្រាប់ការងារកសិកម្ម ជាពិសេសនៅរដូវប្រាំង។				ខាងក្រោម		
					ជីកស្រះស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ទឹកពីប្រព័ន្ធផ្លូវទឹកធម្មជាតិ និងទឹកក្រោម	✓	✓
					រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង ដើម្បីការពារការបំពុលប្រភពទឹក	✓	✓
					ធ្វើការដាំដើមឈើនៅតាមដងអូរដែលគ្មានគម្របព្រៃ ឬមានព្រៃរេចរឹលឲ្យបានចម្ងាយពី ១០០ ម៉ែត្រ ទៅ ១៥០ម៉ែត្រ ដើម្បីបង្កើតជារនាំង ចម្រោះទឹកធម្មជាតិ		✓
					គាំទ្រការបង្កើនសួនបន្លែធម្មជាតិ និងកសិដ្ឋានចិញ្ចឹមសត្វប្រចាំគ្រួសារ ដើម្បីកាត់បន្ថយការទិញចំណីអាហារពីទីផ្សារ		✓
					គាំទ្រដល់កម្មវិធីអប់រំ ផ្សព្វផ្សាយអំពីសុខភាពអនាម័យក្នុងការរស់នៅ (ជាពិសេសរៀបចំ និងចែកចាយនូវផ្ទាំងផ្សព្វផ្សាយអំពីបំរាមក្នុងការប្រើប្រាស់ធុងថ្នាំគីមីកសិកម្មសម្រាប់ស្តុកម្ហូបអាហារ និងទឹកបរិភោគ)		✓
					គាំទ្រដល់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព		✓
					គាំទ្រដល់ដំណើរការមណ្ឌលសុខភាពដែលមានស្រាប់ក្នុងតំបន់ (មណ្ឌលសុខភាពភ្នំកុក និងមណ្ឌលសុខភាពវ៉ឺនសៃ)		✓
					គាំទ្រដល់ដំណើរការបង្កើតមណ្ឌលសុខភាពក្នុងភូមិតាឡាត ឬភូមិរំពាត់ នៃឃុំតាឡាត		✓

Draft

					(ភូមិទាំងពីរនេះនៅជាប់ស្រយោលពីទីប្រជុំឃុំ និងស្ថិតនៅក្រោមខ្សែទឹកនៃទីតាំងគម្រោង)		
ប្រពៃណី ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច							
▪ ប្រជាជនក្នុងឃុំទាំង០៤ សរុបមានប្រមាណ ១០,០៤៩នាក់ក្នុងឆ្នាំ២០១៥។ ▪ ក្នុងតំបន់មានជនជាតិដើមភាគតិចចំនួន ០៥ (ទំពួន គ្រឹង ការ៉ែត លន់ និងព្រៅ) ដែលគោរពបូជាអារក្សអ្នកតា ហើយមួយចំនួនតូចប៉ុណ្ណោះជាជនជាតិខ្មែរដែលគោរពព្រះពុទ្ធសាសនា។ ▪ ទោះបីស្ថានភាពសេដ្ឋកិច្ច និងសង្គមកំពុង មានការប្រែប្រួលទៅតាមរបត់សង្គម ក៏ទំនៀមទំលាប់ របស់ជនជាតិដើមភាគតិចសំខាន់ៗក្នុងឃុំនៅរក្សាបាន មួយចំនួនធំដូចជា៖ ប្រពៃណីគោរពព្រៃ អារក្ស ការការពារ ព្រៃបម្រុងទុកសម្រាប់ កូនចៅជំនាន់ក្រោយ ការរក្សាព្រៃសម្រាប់ កប់សាកសព ការសែនព្រេនពេលមានសមាជិក គ្រួសារឈឺថ្កាត់នានា ពេលមុននិងក្រោយ ពេលប្រមូលផលស្រូវ ឬដំណាំចំការនានា និងការប្រារព្ធនូវពិធី តាមបែបជនជាតិនៅពេលចូលឆ្នាំថ្មី។ល។	▪ ទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិដើមភាគតិច ជាពិសេសសហគមន៍ដែលនៅជាប់ នឹងទីតាំងគម្រោង អាចនឹងទទួលរងនូវ ឥទ្ធិពលពីវប្បធម៌ថ្មី ដែលនាំចូលមកជាមួយ នឹងបុគ្គលិក-កម្មករដែលជាជនចំណូលថ្មី។ ▪ កសិកម្មពនេចរបស់ប្រជាជនជនជាតិដើមអាចនឹងត្រូវបានកម្រិត ក្រោយផ្ទៃដីព្រៃឈើក្នុងតំបន់មួយភាគធំ ត្រូវបានប្រគល់ឲ្យក្រុមហ៊ុនដើម្បីដំណើរការគម្រោង ▪ ការបាត់បង់ព្រៃឈើអាចនឹងធ្វើឲ្យបាត់បង់ប្រពៃណីទំនៀមទម្លាប់មួយចំនួនដូចជា៖ ការកប់សព ការសែនព្រេនអារក្សអ្នកតា ការប្រកបរបរ បណ្តើរឆ្កែដេញសត្វ ការដងជំរំ និងរកអនុ ផលព្រៃឈើផ្សេងៗ	✓			ផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តនូវប្រពៃណីនៃការប្រមូលអនុផលព្រៃឈើ ដោយមិនហាមឃាត់ពួកគាត់មិនឱ្យចូលព្រៃរក្សាទុក		✓
					ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើម ភាគតិច ដល់ បុគ្គលិក-កម្មករ និងជាក់បំពាម មិនឱ្យបុគ្គលិក-កម្មកររធ្វើសកម្មភាពអ្វីដែល អាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណី ទាំងនោះ	✓	✓
					សហការជាមួយអាជ្ញាធរ និងសហគមន៍ មូលដ្ឋាន ដើម្បីរៀបចំពិធីបុណ្យតាមបែប ប្រពៃណីរបស់ជនជាតិដើមភាគតិច	✓	✓
					សហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដីធ្លី ដែលប្រជាជននៅតែអះអាងថាមិនទាន់បានដោះស្រាយ (រួមមាន៖ ដីសហគមន៍ជនជាតិ ដើមភាគតិច គ្រឹង និងដី ចម្ការវិលដុំ និងដី បម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ)		✓
សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន							
▪ ដើម្បីគាំទ្រដល់ការអនុវត្ត ប្រភេទគ្រឿងចក្រ នឹងម៉ាស៊ីនដែលនឹងត្រូវធ្វើចរាចរណ៍នៅលើ និងជុំវិញតំបន់គម្រោងមានដូចជា៖ រថយន្តធំ ចំនួន៥៦ និងម៉ូតូចំនួន១០០គ្រឿង ត្រាក់ទ័រ	▪ ការបើករលឿនពេក ការធ្វេសប្រហែសរបស់អ្នកបើកបរយោនយន្តរបស់ក្រុមហ៊ុន និងភាព មានកម្រិតនៃចំណេះដឹងអំពីច្បាប់ចរាចរណ៍របស់ប្រជាជនមូលដ្ឋានអាចបង្ក		✓		ធ្វើការផ្សព្វផ្សាយជាដំណឹងឲ្យបានមុនទៅកាន់អាជ្ញាធរមូលដ្ឋាន អំពីការចល័តគ្រឿងចក្រ ឬគ្រឿងម៉ាស៊ីនដែលត្រូវប្រើក្នុងពេលដំណើរការគម្រោង	✓	

២០គ្រឿង អេស្កាវ៉ាទ័រចំនួន១០គ្រឿង ប៊ូលឌីសរ១០គ្រឿង គ្រាក់ទ័រគៀរ-រុញ ៨គ្រឿង សាសរ៥គ្រឿង ម៉ាស៊ីនCORE VENEER ៥គ្រឿង ម៉ាស៊ីនដាំស្រូវ១០គ្រឿង និងម៉ាស៊ីនប្រមូលផលស្រូវ ៥គ្រឿង។ ▪ នៅឆ្នាំទី១ បុគ្គលិកកម្មករក្នុងស្រុកដែលរួមមានបុគ្គលិកកម្មករបច្ចេកទេស និងអ្នកគ្រប់គ្រងប្រមាណជា៧២នាក់ និងកម្មករគ្មានជំនាញចំនួន១០០នាក់នឹងត្រូវបានជ្រើសរើស។ ▪ នៅឆ្នាំទី៥ បុគ្គលិកបច្ចេកទេស និងអ្នកគ្រប់គ្រងនឹងកើនដល់៥៩០នាក់ ខណៈដែលកម្មករគ្មានជំនាញនឹងអាចកើនដល់ ១១០០នាក់។ ▪ ពីឆ្នាំទី៦ ដល់ឆ្នាំទី១០ ក្រុមហ៊ុននឹងត្រូវការបុគ្គលិកបច្ចេកទេសនិងអ្នកគ្រប់គ្រងរហូតដល់ ៦៤៤ នាក់ និងកម្មករគ្មានជំនាញ១៤០០នាក់	ឲ្យមានគ្រោះថ្នាក់ចរាចរណ៍ទៅដល់ប្រជាជន មូលដ្ឋាន ▪ បុគ្គលិក-កម្មករគម្រោងដែលជាជនចំណូលថ្មីអាចរស់នៅមិនចុះសម្រុងនឹងប្រជាជនមូលដ្ឋានដែលជាជនជាតិដើមភាគតិច ដែលអាចនឹងឈានទៅបង្កជាជម្លោះ និងអំពើហឹង្សានានា ▪ បុគ្គលិក-កម្មករគម្រោង អាចនាំមកនូវ វប្បធម៌មិនល្អ ដូចជាការសេពគ្រឿងញៀន ការលេងល្បែងស៊ីសង ចោរកម្ម ជម្ងឺឆ្លង ពេស្យាចារ និងករណីរំលោភសេពសន្តវៈ (ពីបុគ្គលិក-កម្មករលើប្រជាជន និង/ឬពីប្រជាជនលើបុគ្គលិក-កម្មករ)។ ▪ អាចកើតមាននូវវប្បធម៌មិនល្អ ដូចជាការសេពគ្រឿងញៀន ការលេងល្បែងស៊ីសង ចោរកម្ម ជម្ងឺឆ្លង ពេស្យាចារ និងករណីរំលោភសេពសន្តវៈ (ពីបុគ្គលិក-កម្មករលើប្រជាជន និង/ឬពីប្រជាជន លើបុគ្គលិក-កម្មករ)។				ណែនាំឱ្យអ្នកបើកបរគោរពច្បាប់ចរាចរណ៍ និងពិន័យធ្ងន់ធ្ងរ ប្រសិនបើមិនគោរពច្បាប់ ហើយការមិនគោរពច្បាប់ធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍	✓	✓
					ធ្វើការផ្សព្វផ្សាយជាចំណោះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងសុវត្ថិភាពចរាចរណ៍	✓	✓
					ជ្រើសរើសបុគ្គលិក-កម្មករក្នុងមូលដ្ឋាន ឲ្យអស់លទ្ធភាពមុននឹងសម្រេចជ្រើសរើសអ្នកតំបន់ផ្សេង	✓	✓
					បញ្ចូលក្នុងបទបញ្ជាផ្ទៃក្នុងនូវបំរាមពាក់ព័ន្ធនឹងគ្រឿងញៀន អំពើហឹង្សាជាមួយប្រជាជនមូលដ្ឋាន និង ករណីចោរកម្ម ពេស្យាចារ រំលោភសេពសន្តវៈ	✓	✓
					សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យ និងតាមដានបុគ្គលិក-កម្មករ ដែលជាជនចំណូលថ្មី ដើម្បីធានាថាពួកគេមិនពាក់ព័ន្ធនឹងគ្រឿងញៀន បង្កហឹង្សាជាមួយប្រជាជនមូលដ្ឋាន និងបង្កឲ្យមានករណីចោរកម្ម ពេស្យាចារ សេពសន្តវៈ	✓	✓
					មានផែនការត្រួតពិនិត្យសុខភាពបុគ្គលិក-កម្មករជាប្រចាំ និងបណ្តុះបណ្តាលពួកគាត់អំពីបញ្ហានៃជម្ងឺឆ្លង ការបង្ការជម្ងឺឆ្លងនានា និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ។ល។	✓	✓
					គាំទ្រដល់បេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន	✓	✓

សុខភាព សុវត្ថិភាព និងសុខមាលភាពបុគ្គលិក-កម្មករ							
▪ នៅឆ្នាំទី១ បុគ្គលិកកម្មករក្នុងស្រុកដែលរួមមានបុគ្គលិកកម្មករបច្ចេកទេស និងអ្នកគ្រប់គ្រង ប្រមាណជា៧២នាក់ និងកម្មករគ្មានជំនាញ ចំនួន១០០នាក់នឹងត្រូវបានជ្រើសរើស ▪ នៅឆ្នាំទី៥ បុគ្គលិកបច្ចេកទេស និងអ្នកគ្រប់គ្រង នឹងកើនដល់៥៩០នាក់ ខណៈដែលកម្មករគ្មានជំនាញនឹងអាចកើនដល់ ១១០០នាក់ ▪ ពីឆ្នាំទី៦ ដល់ឆ្នាំទី១០ ក្រុមហ៊ុននឹងត្រូវការបុគ្គលិកបច្ចេកទេស និងអ្នកគ្រប់គ្រងរហូតដល់ ៦៤៤ នាក់ និងកម្មករគ្មានជំនាញ១៤០០នាក់	▪ ការរស់នៅច្រើនគ្នាក្នុងលំនៅដ្ឋានមិនមានស្តង់ដាត្រឹមត្រូវអាចនឹងបង្កនូវផលប៉ះពាល់ដល់សុខភាពដោយអាចងាយឆ្លងមេរោគនានា ▪ បុគ្គលិកនិងកម្មករគម្រោង ក៏នឹងប្រឈមមុខខ្លាំងនឹងជំងឺគ្រុនចាញ់ ▪ ការបញ្ជាគ្រឿងចក្រ និងរៀបចំដីដាំដុះ និងថែទាំដំណាំ ដោយគ្មានបច្ចេកទស អាចនឹងបង្កគ្រោះថ្នាក់ដល់បុគ្គលិកនិងកម្មករគម្រោង។ ▪ ការប្រើប្រាស់ថ្នាំពុលកសិកម្ម ដោយគ្មានការអនុវត្ត យន្តការសុវត្ថិភាព និងកង្វះការណែនាំអំពីហានិភ័យអាចនឹងបង្កនូវផលប៉ះពាល់ដល់សុខភាពបុគ្គលិក និងកម្មករគម្រោង។		✓		ផ្តល់លំនៅដ្ឋានសម្រាប់ស្នាក់នៅ ក្នុងកម្រិតស្តង់ដាកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់ស្តីពីការងារ	✓	✓
					ផ្តល់នូវការបណ្តុះបណ្តាលអំពីការទប់ស្កាត់ការកើតជម្ងឺគ្រុនចាញ់ និងផ្តល់មុងជ្រលក់ថ្នាំដល់បុគ្គលិក-កម្មករ	✓	✓
					ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសបញ្ជាគ្រឿងចក្រ និងវិធានសុវត្ថិភាពក្នុងការការពារគ្រោះថ្នាក់ក្នុងពេលបំពេញការងារ និងការពារផលប៉ះពាល់ពីថ្នាំគីមីកសិកម្ម	✓	✓
					ផ្តល់ឱ្យបុគ្គលិក-កម្មកនូវឧបករណ៍សុវត្ថិភាពស្របតាមបទដ្ឋានកំណត់ (ដូចជា ស្បែកជើងកវែង ម៉ាស់ការពារមុខ ស្រោមដៃ ខោអាវសម្រាប់ស្លៀកពាក់ពេលបាញ់ថ្នាំ)		✓
					អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាពបុគ្គលិក-កម្មករ ជាពិសេសពាក់ព័ន្ធនឹង ជម្ងឺគ្រុនចាញ់ និងជម្ងឺដែលបង្កឡើងដោយ សារផលប៉ះពាល់នៃថ្នាំគីមីកសិកម្ម		✓
					រៀបចំឱ្យមានស្លាកសញ្ញាបង្ហាញ និងណែនាំនៅទីតាំងស្តុកថ្នាំពុលកសិកម្ម អំពីគ្រោះថ្នាក់ដែលអាចបណ្តាលមកពីថ្នាំពុលកសិកម្ម និងវិធីសាស្ត្រណែនាំអំពីការលាយថ្នាំ		✓
					មិនអនុញ្ញាតឲ្យបុគ្គលិក-កម្មករដែលគ្មាន ភារកិច្ច ឬដែលមិនពាក់ឧបករណ៍ការពារ ចូលទីតាំងស្តុកថ្នាំគីមីកសិកម្ម និងដីកសិកម្ម		✓

Draft

					រៀបចំទីតាំងស្តុកថ្នាំគីមីកសិកម្ម និងជីកសិកម្ម ទៅតាមលក្ខណៈបច្ចេកទេស ដោយការ ពារមិនឲ្យប៉ះពាល់ទឹក លេចជ្រាបចូលក្នុងដី ហុយតាមខ្យល់ ឬត្រូវកំដៅ និងត្រូវមាន ឧបករណ៍ការពារអគ្គិភ័យ និងខ្យល់ចេញចូលល្អ		✓
					លាយតាមស្តង់ដារបច្ចេកទេសនូវថ្នាំកសិកម្ម តាមការណែនាំនៅលើសំបកថ្នាំ នៅទីតាំងរួមមួយក្បែរទីតាំងស្តុកថ្នាំ ដែលធានានូវសុវត្ថិភាពមិនប៉ះពាល់ដល់បរិស្ថាន និងសុខភាពមនុស្ស មុនចែកចាយបន្តឲ្យកម្មករប្រើប្រាស់		✓
					ប្រមូលមកវិញនូវធុងបាញ់ថ្នាំរបស់កម្មករ ដើម្បីរក្សាទុកនៅតាមទីតាំងរួម ដោយមិន អនុញ្ញាតឲ្យកម្មករយកទៅរក្សាទុកតាមផ្ទះ របស់ខ្លួន ដែលអាចធ្វើឲ្យប៉ះពាល់ដល់ សុខភាពសមាជិកគ្រួសារ និងខ្លួនឯង		✓
					ផ្តល់នូវបរិក្ខាសង្គ្រោះបឋម និងណែនាំអំពី វិធីសាស្ត្រសង្គ្រោះបឋម ដល់បុគ្គលិក-កម្មករ មុនពេលចាប់ផ្តើមបំពេញការងារ	✓	
					មានបន្ទប់ព្យាបាលបឋមសម្រាប់ជួយសង្គ្រោះបុគ្គលិក-កម្មករ នៅពេលមានកើតជម្ងឺ ឬមានគ្រោះថ្នាក់ក្នុងពេលបំពេញការងារ		✓
					ផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារដល់គ្រប់បុគ្គលិក-កម្មករ ក្រោមរូបភាពបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)	✓	✓

Draft

៦. ការចូលរួមពីសាធារណជន

ការពិគ្រោះយោបល់បានធ្វើឡើងតាមរយៈកិច្ចពិភាក្សាជាលក្ខណៈបុគ្គល និងជាក្រុមជាមួយ អង្គការសង្គមស៊ីវិលពាក់ព័ន្ធនៅមូលដ្ឋាន អាជ្ញាធរឃុំ-ភូមិ សហគមន៍ ប្រជាជនរស់នៅក្នុងភូមិពាក់ព័ន្ធ និងបណ្តាមន្ទីរជំនាញ ព្រមទាំងតាមរយៈការស្ទង់មតិប្រជាជនក្បែរតំបន់គម្រោង (ចំនួន ៣១៨គ្រួសារ)។ លទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈ និងការស្ទង់មតិប្រជាជនដែលរស់នៅក្បែរតំបន់គម្រោង បង្ហាញថា ទោះជាគម្រោង អភិវឌ្ឍន៍របស់ក្រុមហ៊ុនមិនទាន់បានដំណើរការក្តី ក៏គម្រោងនេះមានបញ្ហាពាក់ព័ន្ធទៅនឹងដីស្រែចំការ (ពិសេស ចំការរិលជុំ) ដីព្រៃសហគមន៍ដែលប្រជាជនអាស្រ័យផល ដីព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ព្រៃអារក្ស និងផ្នូរដូនតារបស់ជនជាតិដើមភាគតិចជាច្រើន។កិច្ចពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានបានបង្ហាញថា មូលហេតុ ចំបងដែលនាំឲ្យមានបញ្ហាទំនាស់ដីធ្លីរវាងប្រជាជននិងក្រុមហ៊ុនរួមមាន៖ (១) ការមិនទាន់មានកម្មសិទ្ធិដីធ្លីស្រប ច្បាប់ច្បាស់លាស់របស់ប្រជាជន (សម្រាប់ប្រភេទដីខ្លះដែលពួកគាត់ធ្លាប់អាស្រ័យផលដូចជា៖ ដីចំការរិលជុំ ដីផ្នូរដូនតា ព្រៃអារក្ខ និងដីបំរុងទុកសម្រាប់កូនចៅជំនាន់ក្រោយ) ខណៈដែលក្រុមហ៊ុនបានទទួលសិទ្ធិ ពីរាជរដ្ឋាភិបាលសម្រាប់វិនិយោគលើដីទាំងនោះ និង(២)ក្រុមហ៊ុននៅមិនទាន់ចាប់ផ្តើមដំណើរការ ទើបដីរបស់ ក្រុមហ៊ុននៅទំនេរក្នុងខណៈដែលប្រជាជនមួយចំនួនពុំមានដីធ្លីសម្រាប់ធ្វើស្រែចំការ ដូច្នេះទើបពួកគាត់ចូលរុករាន ដើម្បីប្រកបរបរចិញ្ចឹមជីវិត។ បញ្ហាប្រឈមដែលមិនគួរមើលរំលង គឺកង្វះខាតដីធ្លីសម្រាប់ធ្វើស្រែចំការនាពេល បច្ចុប្បន្ន និងដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយនាពេលអនាគត ដែលជាក្តីបារម្ភដ៏ធំធេងរបស់ប្រជាជន។ ការអះអាងនេះ ផ្ទុយពីការអះអាងរបស់ក្រុមហ៊ុន និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត ដែលបញ្ជាក់ថា បញ្ហាទំនាស់ដីធ្លីត្រូវបានបញ្ចប់ក្រោមកិច្ចដំណើរការរាស់វែង និងចុះបញ្ជីដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុននេះជាដីឯកជនរបស់រដ្ឋ។

លទ្ធផលនៃការស្ទង់មតិតាមគ្រួសារបង្ហាញថា ប្រជាជនក្នុងតំបន់សិក្សាមិនមានជំហររួម ឬទស្សនៈ ដូចគ្នាអំពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន អេស ខេ ផ្លែនថេសិនទេ ដោយអ្នកដែលសម្តែងការគាំទ្រ មានរហូត ដល់ជាង ពាក់កណ្តាល ក្នុងនោះ ២៦% គាំទ្រដោយគ្មានលក្ខខណ្ឌ ៣០% គាំទ្រដោយមានលក្ខខណ្ឌ តែ២៤%ប៉ុណ្ណោះដែលមិនគាំទ្រ និង២០%មិនមានយោបល់។ លក្ខខណ្ឌដែលបានលើកឡើងដោយអ្នកគាំទ្រ ប្រមាណជា៣០% នោះមានដូចជា៖ (១) ការកំណត់ព្រំប្រទល់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ (២) ការផ្តល់អាទិភាព របស់ក្រុមហ៊ុនក្នុងការជ្រើសរើសប្រជាជនក្នុងតំបន់មកធ្វើការ (៣) ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនក្នុងការមិនប៉ះពាល់ ដីប្រជាជន ដីសហគមន៍ និងដីអារក្សអ្នកតា ជាដើម។ លទ្ធផលនេះស្នើឡើងថា ដំណាក់កាលធ្វើការឈូសឆាយ ក្រុមហ៊ុនត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការដោះស្រាយផលប៉ះពាល់ដែលនៅសេសសល់ ជាពិសេសដី សហគមន៍ និងផលប៉ះពាល់ជាលក្ខណៈសមូហភាពផ្សេងទៀត។

៧. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន-សង្គមសំខាន់ៗ ត្រូវបានរៀបចំជាផែនការការពារបរិស្ថានចំនួន ៨ កម្មវិធីបំពាក់បំប៉ន និងកម្មវិធីត្រួតពិនិត្យបរិស្ថាន ដើម្បីធានានូវការទទួលខុសត្រូវ និងធនធានសម្រាប់អនុវត្តសំដៅបញ្ចៀស កាត់បន្ថយ ស្តារឡើងវិញ និង/ឬប៉ះប៉ូវ នូវផលប៉ះពាល់បរិស្ថាន-សង្គមអវិជ្ជមាន ដែលបានកំពុង ឬនឹងកើតឡើងដោយសារកិច្ចដំណើរការគម្រោងវិនិយោគនេះ។ ផែនការការពារបរិស្ថានទាំង៨នេះ រួមមាន៖

- ផែនការ១៖ ការដោះស្រាយវិវាទដីធ្លីជាមួយប្រជាជន និងសហគមន៍មូលដ្ឋាន
- ផែនការ២៖ ការគ្រប់គ្រងការឈូសឆាយ សាងសង់ និងដាំដុះ
- ផែនការ៣៖ ការលើកកម្ពស់សុខមាលភាពបុគ្គលិក-កម្មករ

- ផែនការ៤៖ ការគ្រប់គ្រងសំណល់ និងប្រភពបំពុលផ្សេងៗ
- ផែនការ៥៖ ការគ្រប់គ្រងការប្រើប្រាស់ដី និងថ្នាំគីមីកសិកម្ម
- ផែនការ៦៖ ការរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន និងលើកកម្ពស់សុខមាលភាពសង្គម
- ផែនការ៧៖ ការចូលរួមការពារ និងស្តារឡើងវិញនូវធនធានធម្មជាតិ
- ផែនការ៨៖ ការគ្រប់គ្រងបញ្ហាទូទៅ

កម្មវិធីបណ្តុះបណ្តាលដល់បុគ្គលិក/កម្មករ ត្រូវផ្តោតលើប្រធានបទសំខាន់ៗដូចជា៖

- ការប្រើប្រាស់នូវគ្រឿងចក្រ គ្រឿងយន្ត ម៉ាស៊ីន និងឧបករណ៍សម្ភារផ្សេងទៀត
- ការអនុវត្តនូវក្រមប្រតិបត្តិ ឬគោលការណ៍សុវត្ថិភាពនៅក្នុងកសិដ្ឋាន ដូចជាការប្រើប្រាស់នូវសម្ភារការពារសុវត្ថិភាព (PPE) ការប្រុងប្រយ័ត្នក្នុងពេលបំពេញការងារ ការត្រួតពិនិត្យនូវលក្ខខណ្ឌសុវត្ថិភាពនៅកន្លែងធ្វើការ ការទុកដាក់សម្ភារ ការទុកដាក់និងប្រើប្រាស់ថ្នាំគីមីកសិកម្ម។ល។
- ការអនុវត្តនូវនីតិវិធីសង្គ្រោះបឋម ដើម្បីជួយជនរងគ្រោះករណីមានឧប្បត្តិហេតុនានាកើតឡើង
- ការអនុវត្តនូវនីតិវិធីក្នុងការទប់ស្កាត់អំពើចោរកម្មដែលអាចកើតមានឡើងពេលប្រតិបត្តិគម្រោង
- ការរក្សាអនាម័យស្អាតក្នុងកន្លែងធ្វើការ ដោយប្រមូលទុកដាក់សំណល់ ញែកទៅតាមប្រភេទកំណត់ ប្រមូលយកទៅស្តុកទុកនៅឃ្លាំងស្តុកទុក និងដឹកសំណល់ទៅចោលនៅទីលានដែលអនុញ្ញាតដោយស្ថាប័នមានសមត្ថកិច្ច
- ការយល់ដឹងអំពីច្បាប់ចរាចរណ៍ផ្លូវគោក ដោយផ្តោតលើការកំណត់ល្បឿនយានយន្តក្នុងតំបន់ទីប្រជុំជនក្រុង តំបន់ក្រៅទីប្រជុំជន និងតំបន់ជនបទ ការប្រើប្រាស់ស៊ីផ្លេ ការចត ការឈប់ និងការត្រួតពិនិត្យអំពីលក្ខណៈសុវត្ថិភាពរបស់យានយន្ត
- ការរក្សាភាពស្ងៀមស្ងាត់នៅក្នុងកន្លែងសម្រាក ឬផ្ទះស្នាក់នៅក្នុងកសិដ្ឋាន
- ការបង្ការជំងឺឆ្លង និងការថែរក្សាសុខភាព ដោយមិនត្រូវប្រើប្រាស់គ្រឿងស្រវឹងច្រើន និងជៀសឆ្ងាយពីគ្រឿងញៀន និងត្រូវជួយតាមដាន ណែនាំ និងរាយការណ៍អំពីការអនុវត្តមិនល្អរបស់បុគ្គលិក/កម្មករដែលមានជាប់ពាក់ព័ន្ធនឹងអំពើល្បែងស៊ីសង ការសេពគ្រឿងញៀន និងសកម្មភាពដទៃទៀតពាក់ព័ន្ធនឹងការបង្កការខូចខាតសណ្តាប់ធ្នាប់សាធារណៈ។

កម្មវិធីត្រួតពិនិត្យបរិស្ថាន ត្រូវបានរៀបចំឡើងដើម្បីធានានូវការត្រួតពិនិត្យ និងតាមដានបម្រែបម្រួលគុណភាពទឹក (លើដី និងក្រោមដី) និងគុណភាពដី ព្រមទាំងតាមដានប្រភពបំពុលខ្យល់ និងការរំខានដោយសំឡេង សំដៅទប់ស្កាត់ការបំពុលលើសពីកម្រិតស្តង់ដារកំណត់ និងបង្កឲ្យមានបម្រែបម្រួលគុណភាពបរិស្ថានដែលមិនអាចស្តារឡើងវិញបាន និង/ឬប៉ះពាល់ដល់សុខភាព សុវត្ថិភាពសាធារណៈ។ កម្មវិធីត្រួតពិនិត្យបរិស្ថាននឹងត្រូវអនុវត្តដោយម្ចាស់គម្រោងផ្ទាល់ ក្រោមការត្រួតពិនិត្យ ឃ្លាំមើលពីស្ថាប័នជំនាញដែលពាក់ព័ន្ធ។ ក្រុមហ៊ុនម្ចាស់គម្រោង នឹងធ្វើរបាយការណ៍ជូនក្រសួងបរិស្ថានរៀងរាល់ ៦ខែម្តង ដើម្បីរាយការណ៍ពីលទ្ធផលនៃការវាយតម្លៃលើសកម្មភាពគម្រោង និងឥទ្ធិពលគម្រោងលើធនធានបរិស្ថាន និងសង្គម ក្នុងតំបន់។ របាយការណ៍នេះ នឹងផ្តល់ជាមូលដ្ឋានដល់ក្រសួងពាក់ព័ន្ធ ក្នុងការចុះអង្កេតតាមដាន និងផ្តល់អនុសាសន៍កែលម្អតាមបទពិសោធន៍បច្ចេកទេស ឲ្យបានទាន់ពេលវេលាក្នុងករណីមានភាពមិនប្រក្រតីកើតឡើង។

ថវិកាបន្ថែមដែលក្រុមហ៊ុនចាំបាច់ត្រូវបម្រុងទុកដើម្បីធានាការអនុវត្តផែនការការពារបរិស្ថាន កម្មវិធីបំពាក់បំប៉ន និងត្រួតពិនិត្យបរិស្ថានចាប់ពីពេលបច្ចុប្បន្ន (ឆ្នាំ២០១៧ ឬឆ្នាំទី១) រហូតដល់បញ្ចប់ការវិនិយោគ (រយៈ

ពេលសរុប ៥០ឆ្នាំ) មានចំនួនសរុប ៣.០៣៨.០០០ ដុល្លារអាមេរិក សម្រាប់រយៈពេលវិនិយោគ ៥០ឆ្នាំនេះ ឬជាមធ្យមប្រមាណ ៦០.៧៦០ ដុល្លារអាមេរិក/ឆ្នាំ។

ទោះជាក្រុមហ៊ុនខិតខំបញ្ចៀស កាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន និងធ្វើការអប់រំ-បណ្តុះបណ្តាលយ៉ាងណាក្តី ក៏គម្រោងនេះនឹងបន្សល់នូវផលប៉ះពាល់មួយចំនួនដល់សហគមន៍មូលដ្ឋាន និងបរិស្ថាននៅតំបន់នោះដោយមិនអាចចៀសវាងបាន ឬ ដែលអាចកាត់បន្ថយមកត្រឹមកម្រិតតិចតួចប៉ុណ្ណោះ។ ក្រុមហ៊ុនបានលើកផែនការដើម្បីជួយស្តារបរិស្ថានឡើងវិញ និងប៉ះប៉ូវផលប៉ះពាល់មួយចំនួនរួចហើយនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។ សកម្មភាពដែលនឹងជួយស្តារបរិស្ថានឡើងវិញ ត្រូវចំណាយថវិកាជាមធ្យមប្រមាណ ២០០០ដុល្លារ/ឆ្នាំ ឬ ១.០០០.០០០ ដុល្លារក្នុងរយៈពេល ៥០ឆ្នាំនៃការវិនិយោគ។ សកម្មភាពដែលនឹងជួយអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ត្រូវចំណាយថវិកាជាមធ្យមប្រមាណ ១៤.០០០ ដុល្លារ/ឆ្នាំ ឬ ៧០០.០០០ ដុល្លារក្នុងរយៈពេល ៥០ឆ្នាំនៃការវិនិយោគ។ ក្រុមហ៊ុននឹងផ្តល់ជូនបន្ថែមនូវថវិកាចំនួន **២.០០០ដុល្លារ/ឆ្នាំ (១.០០០ដុល្លារ/ឆ្នាំ សម្រាប់មូលនិធិបរិស្ថាន និង ១.០០០ដុល្លារ/ឆ្នាំ សម្រាប់មូលនិធិសង្គម)** សម្រាប់ក្រសួងបរិស្ថាន យកទៅចាត់ចែងប្រើប្រាស់ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។ ក្រុមហ៊ុននឹងបង់ចូលមូលនិធិបរិស្ថាន និងសង្គមនេះ ចាប់ពីឆ្នាំ ២០១៨ តទៅ។

៨. ផែនការគ្រប់គ្រងបរិស្ថាន

ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន នឹងត្រូវបានធ្វើឡើងដោយម្ចាស់គម្រោងផ្ទាល់ ដែលម្ចាស់គម្រោងត្រូវជ្រើសរើសបុគ្គលិកដែលមានជំនាញ និងចំណេះដឹងផ្នែកបរិស្ថាន ដើម្បីជួយក្នុងការអនុវត្តការងារនេះ។ ក្នុងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននេះដែរ ក៏តម្រូវឱ្យមានការចុះត្រួតពិនិត្យជាទៀតទាត់ពីសំណាក់ស្ថាប័នមានសមត្ថកិច្ចដើម្បីធានានូវការអនុវត្តវិធានការកាត់បន្ថយ ឬផែនការគ្រប់គ្រងស្របតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ និងដើម្បីធ្វើការកែតម្រូវនូវការអនុវត្តដែលមិនទាន់បានល្អ។

ជារួម សមាសភាពនៃក្រុមការងារអនុវត្តផែនការគ្រប់គ្រងបរិស្ថាន មានដូចជា៖

- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នថ្នាក់ក្រោមជាតិ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទខេត្ត
- មន្ទីរបរិស្ថានខេត្ត
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត
- មន្ទីរធនធានទឹក និងឧតុនិយមខេត្ត
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- មន្ទីរសុខាភិបាលខេត្ត
- អាជ្ញាធរដែនដី (ខេត្ត ស្រុក ឃុំ)

៩.ការវាយតម្លៃសេដ្ឋកិច្ចនិងតម្លៃបរិស្ថាន

តាមការប៉ាន់ស្មាន ក្រុមហ៊ុននឹងទទួលបានប្រាក់ចំណេញសុទ្ធ (Net Profit) ចាប់ពីឆ្នាំទី១០ ចំនួន ១.១៥៥.៨១០ ដុល្លារអាមេរិក។ ទឹកប្រាក់ចំណេញសុទ្ធ នឹងកើនឡើងជាបន្តបន្ទាប់រហូតដល់ចំនួនខ្ពស់បំផុតនៅឆ្នាំទី១៣ ចំនួន ៧.៩៦៣.៣០៣ដុល្លារអាមេរិក។ ទឹកប្រាក់ចំណេញសុទ្ធនឹងថយចុះបន្តិចបន្តិចពីចំនួន ៧.៧៨៣.៣០៣ ដុល្លារអាមេរិក នៅឆ្នាំទី១៤ មកត្រឹម ៧.៥៨៣.៣០៣ ដុល្លារអាមេរិក នៅឆ្នាំទី២០។ ប៉ុន្តែក្រុមហ៊ុន នឹងត្រូវចំណាយសម្រាប់ការខាតរហូត ដល់ឆ្នាំទី៩៖ ទឹកប្រាក់ចំនួន ៣.៦៩៩.២៦៧ ដុល្លារអាមេរិក គឺជាការខាតបង់នៅឆ្នាំទី១, ទឹកប្រាក់ចំនួន ៥.៥៣៩.១០៣ ដុល្លារអាមេរិក ជាទឹកប្រាក់ខាតនៅ ឆ្នាំទី២ ទឹកប្រាក់ខាតបង់នៅឆ្នាំទី៣ មានទំហំធំរហូតដល់ ៨.៨០២.២៨១ ដុល្លារអាមេរិក។ ទឹកប្រាក់ខាតបង់ មានការថយចុះជាបន្តបន្ទាប់នៅឆ្នាំទី៤-៩ ប្រមាណពី ៤.៩៣៩.១៤៣ ដុល្លារអាមេរិក នៅឆ្នាំទី៤ មកត្រឹម ៣៤៥.៨៤៣ ដុល្លារអាមេរិក នៅឆ្នាំទី៩។ ផ្អែកតាមការវិភាគសេដ្ឋកិច្ចនៅក្នុងផែនការមេដូចបង្ហាញក្នុងតារាងខាងលើ លំហូរសាច់ប្រាក់ (ចំណេញ-ខាត) របស់ក្រុមហ៊ុន (ដោយកំណត់យកអត្រាអបហារ ឬ Discounted Rate ១២%) អាចបង្កើតជាតម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value ឬ NPV) សរុបប្រមាណ ៧.៥៥៨.៩៤៧ ដុល្លារអាមេរិក (ឬជាមធ្យមប្រមាណ ៣៧៧.៩៤៧ ដុល្លារអាមេរិក/ឆ្នាំ) ក្នុងរយៈពេលឆ្នាំ២០ដំបូង។ ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំជាមធ្យម ច្បាស់ជានឹងកើនឡើងគួរឱ្យកត់ សម្គាល់ក្នុងរយៈពេលវិនិយោគដែលនៅសេសសល់ (ពីឆ្នាំទី២១ ដល់ ៥០) ពីព្រោះថ្លៃចំណាយ (ដូចជា សម្រាប់ហេដ្ឋរចនាសម្ព័ន្ធ គ្រឿងចក្រ ទព្វសំភារៈការិយាល័យ) នឹងថយចុះយ៉ាងខ្លាំង។

ផលប៉ះពាល់បរិស្ថានសំខាន់បំផុតនៃគម្រោងនេះ គឺការបាត់បង់ព្រៃឈើ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើដែលចម្បងរួមមាន៖ ផល-អនុផលព្រៃឈើ និងសេវាកម្មអភិរក្សទឹក។ លទ្ធផលនៃការសិក្សាបង្ហាញថា ការបាត់បង់សារៈប្រយោជន៍ដែលទទួលបានពីការប្រមូលផល-អនុផលព្រៃឈើដោយនិរន្តរភាព និងបម្រែបម្រួល សេវាកម្មអភិរក្សទឹក អាចធ្វើឱ្យខាតបង់សេដ្ឋកិច្ចក្នុងតម្លៃសរុបប្រមាណ ៣៥៩.៥៧៥ដុល្លារ/ឆ្នាំ (Opportunity Cost)។ ការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ជាទូទៅត្រូវការថវិកាជាច្រើន ដែលយើងមិនអាចធ្វើការប៉ាន់ស្មានបានក្នុងស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។ ជាក់ស្តែង ព្រៃឈើក្នុងតំបន់ការពារធម្មជាតិ ដែលត្រូវបានការពារដោយច្បាប់ និងមានថវិកា/ធនធានជាច្រើនសម្រាប់គ្រប់គ្រង ក៏នៅមិនទាន់អាចធានាបាននូវនិរន្តរភាពផង។ ម្យ៉ាងវិញទៀត ព្រៃឈើក្នុងតំបន់គម្រោងក្នុងពេលបច្ចុប្បន្ន ក៏បាននិងកំពុងទទួលរងនូវការកាប់រានធ្វើចំការពី សំណាក់ប្រជាជន និងជនឆ្លៀតឱកាសនានា។ ដូច្នេះ ព្រៃឈើក្នុងតំបន់គម្រោង ក៏ប្រហែលជាត្រូវបានកាប់បំផ្លាញ ឬធ្វើឱ្យសឹករេចរឹលតាមប្រការណាមួយដោយចៀសមិនរួច បើទោះជាមិនមានវត្តមានគម្រោងក៏ដោយ។ តម្លៃខាតបង់ដូចបានប៉ាន់ស្មានខាងលើ ក៏ប្រហែលជាបាត់បង់ជាមួយព្រៃឈើទាំងនោះដែរ ដោយមិនបានទាំង ផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ច (ដែលមានតម្លៃប្រមាណ ៣៧៧.៩៤៧ដុល្លារ/ឆ្នាំ) ពីគម្រោងវិនិយោគនេះ។ ការខូចខាតបរិស្ថាន ក៏ប្រហែលជាមានតម្លៃខ្ពស់ជាងតម្លៃប៉ាន់ស្មានខាងលើ ប្រសិនបើព្រៃឈើត្រូវបានកាប់បំផ្លាញ ហើយទុកដីចោលនៅទំនេរដោយគ្មានការដាំដុះ ក្នុងខណៈដែលគ្មានគម្រោង។

ប្រទេសកម្ពុជាមិនទាន់មានការដាក់ពន្ធទៅលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី (Payment for Ecosystem Services) នៅឡើយទេ។ បើទោះជាយ៉ាងនេះក្តី យើងមិនគួរបំភ្លេចចោលនូវផលប៉ះពាល់អវិជ្ជមាន ដែលបាននិងកំពុងបង្កឡើងដោយសកម្មភាពគម្រោងនេះនោះទេ។ ដើម្បីក្លាយជាក្រុមហ៊ុនមួយដែលមានការទទួលខុសត្រូវខ្ពស់ ក្រុមហ៊ុនអេស ខេ ផលេនថេសិន បានរៀបចំផែនការគាំទ្រដល់ការស្តារបរិស្ថានឡើងវិញ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន ព្រមទាំងបង់ថវិកាចូលមូលនិធិបរិស្ថាន និងសង្គម ចំនួន ២.០០០ដុល្លារ/ឆ្នាំ សម្រាប់ក្រសួងបរិស្ថាន យកទៅចាត់ចែងប្រើប្រាស់ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

១០. សន្និដ្ឋាន និងអនុសាសន៍

តាមរយៈការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ យើងរកឃើញថា គម្រោងវិនិយោគរបស់ក្រុមហ៊ុន អែសខេ ផ្លេនថេសិន ពិតជាអាចផ្តល់ប្រាក់ចំណេញដែលអាចជំរុញកំនើនសេដ្ឋកិច្ចជាតិ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋជនបទ។ ទោះជាយ៉ាងនេះក្តី ប្រតិបត្តិការ របស់គម្រោងអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់ និងជៀសមិនរួច ប៉ុន្តែអាចធ្វើការគ្រប់គ្រង និងកាត់បន្ថយបាន។ ដូច្នេះក្រុមហ៊ុនម្ចាស់គម្រោងត្រូវសហការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងបរិស្ថាន ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នជំនាញ និងអាជ្ញាធរ ពាក់ព័ន្ធនានា ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមផែនការគ្រប់គ្រងបរិស្ថាន ព្រមទាំងធ្វើការកែតម្រូវក្នុងករណីចាំបាច់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តផែនការនេះ។ ផលប្រយោជន៍ ដែលប្រជាជននឹងទទួលបានពីសកម្មភាព នានាក្រោមផែនការគ្រប់គ្រងបរិស្ថាន (ជាពិសេសមូលនិធិបរិស្ថាន-សង្គម) ពិតជានឹងអាច បង្កើនភាពសុខដុមរមណីយកម្មរវាងក្រុមហ៊ុន និងសហគមន៍មូលដ្ឋាន ក៏ដូចជាបង្កលក្ខណៈឲ្យ ក្រុមហ៊ុនសម្រេចគោលដៅចម្បង នៃការវិនិយោគនេះគឺ រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្មប្រកបដោយនិរន្តភាព និងជួយកាត់បន្ថយភាព ក្រីក្ររបស់ប្រជាជនមូលដ្ឋាន។

Draft

ជំពូកទី១
សេចក្តីផ្តើម

Draft

ជំពូកទី១៖ សេចក្តីផ្តើម

១.១ លក្ខណៈទូទៅ

ការអភិវឌ្ឍសេដ្ឋកិច្ចបែបកសិ-ឧស្សាហកម្មត្រូវបានជ្រើសរើសយកមកអនុវត្តដោយប្រទេសចំនួលមជ្ឈមមួយចំនួន ដូចជាប្រទេសម៉ាឡេស៊ី ប្រទេសថៃ និងប្រទេសមួយចំនួនទៀត។ ខណៈពេលដែលប្រទេសទាំងនោះបានក្លាយជាប្រទេសនាំមុខក្នុងការដាំដំណាំកសិឧស្សាហកម្ម គម្របព្រៃត្រូពិចមួយភាគធំត្រូវបានបំផ្លាញ ហើយការបង្កើនការដាំដុះដំណាំកសិឧស្សាហកម្ម អាចបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងច្រើនដល់បរិស្ថាន សង្គម និងវប្បធម៌ (Mawalagedarav and Oglesby 2012; Sumit, Ghosh, and Suresh 2014) ដើម្បីជាថ្នូរនៃការចំណេញផ្នែកសេដ្ឋកិច្ចបែបនេះ (Olaniyi*et al.* 2013) ។ ទោះជាមានអំណះអំណាងតាមរយៈការសិក្សាជាលក្ខណៈវិទ្យាសាស្ត្របែបនេះក្តី ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន នៅតែបន្តប្រកាន់យកគោលនយោបាយនេះ ដើម្បីឈានចាប់វិស័យឧស្សាហកម្មធនធ្ងន់នាពេលអនាគត និងដើម្បីបង្កើនឱកាសការងារ និងប្រាក់ចំណូលដល់ប្រជាជន ក៏ដូចជាការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលខ្លី-មធ្យមផងដែរ។

ដោយហេតុថាប្រទេសកម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមប្រទេសនានា ដែលបានចាត់ទុកវិស័យកសិ-ឧស្សាហកម្មជាវិស័យចាំបាច់ក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិនៅដំណាក់កាលដំបូងដែរនោះ កម្ពុជាបានយកចិត្តទុកដាក់ក្នុងការជ្រើសរើសវិធានការអភិវឌ្ឍន៍នានា ដែលជួយឲ្យប្រទេសអាចរក្សាតុល្យភាពការអភិវឌ្ឍ និងអភិរក្ស។ ជាក់ស្តែង ដើម្បីអភិវឌ្ឍវិស័យកសិឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជា ការពិភាក្សាវែកញែកតែងតែត្រូវបានធ្វើឡើងទៅលើបញ្ហាដែលនឹងជួបប្រទះមួយចំនួនដូចជា៖តើការខាតបង់ព្រៃឈើនិងការខូចខាតបរិស្ថានអាចត្រូវបានប៉ះប៉ូវដោយផលចំណេញសេដ្ឋកិច្ចដែលទទួលបានដែរឬទេ? តើផលប្រយោជន៍ដោយផ្ទាល់និងប្រយោលត្រូវបានផ្តល់ទៅដល់អ្នកណា? តើអ្នកណាជាអ្នកទទួលបានប្រយោជន៍ច្រើន? ហើយតើត្រូវមានគោលនយោបាយគ្រប់គ្រងបែបណាដើម្បីកាត់បន្ថយផលប៉ះពាល់ឱ្យនៅតិចបំផុតតាមរយៈបទពិសោធន៍ជាក់ស្តែងកន្លងមក។

ទន្ទឹមនឹងនេះផងដែរការបែងចែកភាគលាភពីអត្ថប្រយោជន៍សេដ្ឋកិច្ចដែលទទួលបានពីការអនុវត្តគោលនយោបាយនេះ គឺជាបញ្ហាចម្បងមួយទៀតដែលគួរលើកមកពិភាក្សា។ ក្រួសារប្រជាកសិករកម្ពុជាមិនទាន់មានលទ្ធភាពក្នុងការវិនិយោគលើវិស័យកសិឧស្សាហកម្មនៅឡើយទេ ពីព្រោះការអភិវឌ្ឍលើវិស័យនេះត្រូវការដើមទុនច្រើន និងបច្ចេកវិទ្យាទំនើបដើម្បីទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ដែលជាហេតុនាំឱ្យការវិនិយោគភាគច្រើនគឺជាក្រុមហ៊ុនបរទេសដែលមានមូលធនច្រើន។ បន្ថែមពីលើនេះ គម្រោងនីមួយៗត្រូវការដីដាំដុះទំហំធំ និងតែងតែអភិវឌ្ឍនៅលើដីព្រៃដែលមិនទាន់ឈូសឆាយ ដើម្បីឱ្យការដាំដុះមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច ដែលជាហេតុធ្វើឱ្យការអភិវឌ្ឍកសិឧស្សាហកម្មអាចបណ្តាលឱ្យមានផលប៉ះពាល់បរិស្ថានយ៉ាងខ្លាំង។

ដូចនេះការវាយតម្លៃហេតុ/ផលប៉ះពាល់បរិស្ថាននិងសង្គម គឺជាតម្រូវការចាំបាច់បំផុត ដើម្បីធ្វើបច្ចុប្បន្នភាពគម្រោងវិនិយោគ វាយតម្លៃហេតុប៉ះពាល់ដែលអាចកើតឡើងនាពេលអនាគត កំណត់វិធានការកាត់បន្ថយសមស្របនានា និងរៀបចំផែនការគ្រប់គ្រងដែលចាំបាច់ដើម្បីអនុវត្ត។ ដើម្បីធ្វើការវិភាគឲ្យបានគ្រប់ជ្រុងជ្រោយ ការវាយតម្លៃពេញលេញនេះនឹងធ្វើការសិក្សាលម្អិតទៅលើបញ្ហារូបសាស្ត្រ (ឧ. ដោយមានការជ្រើសរើសសំណាកដី និងសំណាកទឹកបន្ថែមពីសំណាកដែលបានសិក្សារួចហើយនៅក្នុងរបាយការការវាយតម្លៃហេតុ/ផលប៉ះពាល់បរិស្ថាននិងសង្គមបឋម) ដើម្បីផ្ទៀងផ្ទាត់ និងប្រៀបធៀបពីបម្រែបម្រួលធនធានរូបសាស្ត្រក្នុងតំបន់គម្រោង។ ការសិក្សាលើកត្តា

ជីវសាស្ត្រ ក៏នឹងត្រូវបានសិក្សាឡើងវិញផងដែរ ដែលក្នុងនោះមានបម្រែបម្រួលគម្របព្រៃ សត្វព្រៃ និងមច្ឆជាតិ ដោយសារតែការបម្លែងព្រៃឱ្យទៅជាចំការដំណាំកៅស៊ូ ដូង អាកាស្យា និងកាកាវជាដើមនោះ។ ដោយហេតុថា បម្រែបម្រួលនានាអាចនឹងធ្វើឱ្យប៉ះពាល់ដល់បរិស្ថានរស់នៅ និងជីវភាពរបស់ប្រជាជន (ជាពិសេសសជនជាតិដើមភាគតិចដែលធ្លាប់អាស្រ័យផល-អនុផលព្រៃឈើ) ក៏ដូចជាអាចនាំឲ្យពួកគាត់ប្រឈមនឹងការបាត់បង់អត្តសញ្ញាណប្រពៃណី វប្បធម៌ នៅពេលដែលពួកគាត់ត្រូវសម្របខ្លួនទៅនឹងស្ថានភាពថ្មី ការសិក្សានេះនឹងធ្វើការវាយតម្លៃពេញលេញ និងវិភាគបន្ថែមទៅលើបម្រែបម្រួលវប្បធម៌ ប្រពៃណី និងទំនៀមទំលាប់ផងដែរ។

លើសពីនេះ ដើម្បីឱ្យការវាយតម្លៃនេះមានលក្ខណៈស៊ីជម្រៅ និងប្រើប្រាស់បានក្នុងបរិប៉ទតំបន់គោលដៅ ការវិភាគសេដ្ឋកិច្ច និងតម្លៃនៃការខូចខាតបរិស្ថានដោយប្រើប្រាស់វិធីសាស្ត្រ Value Transfer (Bander 2013) ក៏នឹងត្រូវផ្តោតជាពិសេស ដើម្បីវាយតម្លៃពីផលចំណេញ-ខាត និងការបង្ខិលតម្លៃមិនមែនបរិស្ថាន និងបរិស្ថាននានាឱ្យទៅជាឯកតាសាច់ប្រាក់(Monetary Value)។ ជាលទ្ធផល ការធ្វើផែនការគ្រប់គ្រងបរិស្ថានដែលរួមមានមានការកំណត់នូវទឹកប្រាក់សម្រាប់ជាសំណងប៉ះប៉ូវដល់ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់គម្រោង និងសម្រាប់ការកំណត់មូលនិធិបរិស្ថាន-សង្គម នឹងត្រូវបានចងក្រងឡើងតាមរយៈវិធីសាស្ត្រនេះ។

១.២. គោលបំណងនៃការសិក្សា

ដើម្បីបំពេញតម្រូវការច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ឆ្នាំ១៩៩៦) និងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ឆ្នាំ១៩៩៩) ក៏ដូចជារួមចំណែកក្នុងការគ្រប់គ្រងហេតុ-ផលប៉ះពាល់បរិស្ថាន និងសង្គម (បញ្ចៀស កាត់បន្ថយ ស្តារឡើងវិញ ប៉ះប៉ូវ) ក្រុមហ៊ុនម្ចាស់គម្រោងបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងជូនក្រសួងបរិស្ថាន ហើយក្រសួងក៏បានឯកភាពជាគោលការណ៍លើរបាយការណ៍នេះ កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១១ (លិខិតលេខ ៤៥២ សជណ ប.ស្ត)។ ទន្ទឹមនឹងនេះ ក្រសួងបរិស្ថាន ក៏បានតម្រូវឱ្យក្រុមហ៊ុនម្ចាស់គម្រោង រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។ ជាការឆ្លើយតប ក្រុមហ៊ុនម្ចាស់គម្រោង បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន អ ស៊ី ប៊ី ស៊ី ស៊ី (RCBCC Co., Ltd.) ដែលជាក្រុមហ៊ុនទីប្រឹក្សាឯករាជ្យ ដើម្បីបំពេញការងារនេះ។

កម្មវត្ថុនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះរួមមាន៖

- សិក្សា និងវាយតម្លៃមិតអំពីទិន្នន័យមូលដ្ឋាននៃធនធានបរិស្ថានក្នុងតំបន់ ដែលរួមមាន ធនធានបរិស្ថានរូបសាស្ត្រ ធនធានបរិស្ថានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម
- វាយតម្លៃ និងកំណត់នូវស្ថានភាពបរិស្ថាន និងសេដ្ឋកិច្ច-សង្គម ក្នុងតំបន់ដែលទទួលរងនូវផែលប៉ះពាល់ឲ្យបានច្បាស់លាស់ ពិសេសវាយតម្លៃអំពីផលប៉ះពាល់ដល់ប្រជាជនមូលដ្ឋាន
- ពិគ្រោះយោបល់ជាមួយប្រជាជន និងសហគមន៍ដែលនៅក្បែរតំបន់គម្រោង អាជ្ញាធរមូលដ្ឋាន (ភូមិ និងឃុំ) មន្ទីរដំនាញពាក់ព័ន្ធក្នុងខេត្ត (មន្ទីរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, មន្ទីរបរិស្ថាន, មន្ទីរកសិកម្ម, ខណ្ឌរដ្ឋបាលព្រៃឈើ, ខណ្ឌរដ្ឋបាលជលផល, មន្ទីរធនធានទឹក និងឧតុនិយម) និងអង្គការមិនមែនរដ្ឋាភិបាលនានា

- វាយតម្លៃនូវហេតុ-ផលប៉ះពាល់បរិស្ថាន និងសង្គមសំខាន់ៗឱ្យបានលម្អិត ព្រមទាំងកំណត់ និងរៀបចំនូវវិធានការគ្រប់គ្រងឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ដោយគិតគូរជាលំដាប់នូវវិធានការបញ្ចៀស កាត់បន្ថយ ស្តារឡើងវិញ និងប៉ះប៉ូវ
- រៀបចំផែនការគ្រប់គ្រងបរិស្ថានមួយ ដែលអាចយកមកអនុវត្តបាន ហើយដែលយ៉ាងហោចណាស់ត្រូវដាក់បញ្ចូលក្នុងកម្មវិធីការងារ អ្នកទទួលខុសត្រូវអនុវត្តន៍ តម្រូវការថវិកាសម្រាប់អនុវត្តន៍កម្មវិធីការងារ
- វិភាគសេដ្ឋកិច្ច (ផលចំណេញ និងខាត ចំពោះបរិស្ថាន សេដ្ឋកិច្ច និងសង្គម) ដោយសារវត្តមានគម្រោងវិនិយោគនេះ និងប៉ាន់ស្មាននូវតម្លៃមូលនិធិបរិស្ថាន-សង្គម ឱ្យមានលក្ខណៈសមស្របទៅនឹងទំហំនៃការខូចខាតដែលបង្កឡើងដោយសារគម្រោង។

Draft

ជំពូកទី២

វិធីសាស្ត្រ និងទំហំនៃការសិក្សាទាយតម្លៃ

Draft

ជំពូកទី២៖ វិធីសាស្ត្រ និងចំហំនៃការសិក្សាវាយតម្លៃ

២.១. សេចក្តីផ្តើម

គម្រោងវិនិយោគសម្រាប់អភិវឌ្ឍន៍កៅស៊ូ ដំណាំដូង កាកាវ អាកាស្យាសេណោហ្គាល់ និងដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន (ខេមបូឌា) ភីធីអ៊ី អិលធីឌី [SK PLANTATION (CAMBODIA) PTE. LTD] មានទីតាំងស្ថិតនៅក្នុងឃុំត្រពាំងក្រហម ឃុំតឹន ស្រុកកូនមុំ និងឃុំហាតប៉ក ឃុំប៉ង់ និងឃុំក្នុកស្រុកវ៉ឺនសៃ ខេត្តរតនគិរី។ ទីតាំងគម្រោងនេះ ស្ថិតនៅក្នុងតំបន់ព្រៃឈើ និងមូលដ្ឋានដែលមានជនជាតិដើមភាគតិចរស់នៅ ដូច្នេះការអភិវឌ្ឍគម្រោងនេះនឹងនាំឱ្យមានការផ្លាស់ប្តូរនូវស្ថានភាពធនធានបរិស្ថាន និងសង្គមក្នុងតំបន់ក្នុងកម្រិតមួយដែលមិនអាចមើលរម្លងបាន។ ក្រុមហ៊ុនយកចិត្តទុកដាក់ក្នុងការថែរក្សាការពារបរិស្ថានទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ហើយការសិក្សានេះទាមទារនូវការសិក្សាស្វែងយល់អំពីស្ថានភាពច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃ និងសម្រាប់ម្ចាស់គម្រោងយកមកធ្វើជាមូលដ្ឋានក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន, ការវាយតម្លៃអំពីស្ថានភាពបច្ចុប្បន្ននៃធនធានបរិស្ថានធម្មជាតិ (រូបសាស្ត្រ និងជីវសាស្ត្រ) និងសេដ្ឋកិច្ច-សង្គម ក្នុង និងជុំវិញតំបន់គម្រោង, ការព្យាករណ៍អំពីហេតុប៉ះពាល់សំខាន់ៗ, ការកំណត់វិធានការបញ្ចៀស កាត់បន្ថយ ស្តារឡើងវិញ និង/ឬប៉ះប៉ូវ ផលប៉ះពាល់អវិជ្ជមាន, ការរៀបចំនូវផែនការគ្រប់គ្រងមួយច្បាស់លាស់ ដើម្បីធានានូវការអនុវត្តវិធានការទាំងនោះ, ការវាយតម្លៃអំពីតម្លៃសេដ្ឋកិច្ច ដែលត្រូវខាតបង់ដោយសារគម្រោង, និងការកំណត់នូវមូលនិធិបរិស្ថាន-សង្គម សម្រាប់ស្តារ គាំពារ និងលើកកម្ពស់គុណភាពបរិស្ថាន និងកម្រិតជីវភាពប្រជាជនមូលដ្ឋានឡើងវិញ។ វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ក្នុងការសិក្សាវាយតម្លៃពេញលេញនេះ មានបង្ហាញលម្អិតដូចខាងក្រោម។

២.២. ការស្វែងយល់អំពីច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងៗ

ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានធ្វើការសិក្សាស្វែងយល់ និងពិភាក្សា ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃអំពីផលប៉ះពាល់ និងលើកឡើងនូវវិធានការកាត់បន្ថយ ដែលធានាថារាល់សកម្មភាពរបស់គម្រោង នឹងមិនអនុវត្តខុសពីបញ្ញត្តិនៃច្បាប់ និងបទដ្ឋានគតិយុត្តដែលមានជាធរមាន។

ច្បាប់ បទបញ្ញត្តិ និងគោលនយោបាយជាតិ ដែលទាក់ទងទៅនឹងគម្រោងអភិវឌ្ឍន៍នេះ រួមមាន៖

- ច្បាប់៖ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ឆ្នាំ១៩៩៦), ច្បាប់ភូមិបាល (ឆ្នាំ២០០១), ច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ (ឆ្នាំ២០០១), ច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០២), ច្បាប់ដីធ្លី (ឆ្នាំ២០០៦), ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក (ឆ្នាំ២០០៧), និងច្បាប់ស្តីពីដីរសុវត្ថិភាព (ឆ្នាំ២០០៨), ច្បាប់ស្តីពីការងារ (ឆ្នាំ១៩៩៧), ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៣), ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំ កសិកម្មនិងដីកសិកម្ម (ឆ្នាំ២០១២), ច្បាប់ក្រមរដ្ឋប្បវេណី (ឆ្នាំ២០០៧), ច្បាប់ស្តីពីផ្លូវថ្នល់ (ឆ្នាំ២០១៤),- ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារ (ឆ្នាំ២០០២), ច្បាប់ចរាចរណ៍ផ្លូវគោក (ឆ្នាំ២០១៤), ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា ១៤៤ នៃច្បាប់ស្តីពីការងារ (ឆ្នាំ២០០៧)។

- លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់៖ អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ឆ្នាំ ១៩៩៩), អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (ឆ្នាំ១៩៩៩), អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (ឆ្នាំ ១៩៩៩), អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការ រំខានដោយសម្លេង (ឆ្នាំ២០០០), អនុក្រឹត្យស្តីពី

សម្បទានដីសេដ្ឋកិច្ច (ឆ្នាំ២០០៥), អនុក្រឹត្យស្តីពី ការកំណត់ប្រភេទផល ផលិតផលជលផល ដែលកំពុងរងគ្រោះថ្នាក់ (ឆ្នាំ២០០៩), អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (ឆ្នាំ២០០៣), អនុក្រឹត្យស្តីពីការ គ្រប់គ្រងដីរដ្ឋ (ឆ្នាំ ២០០៥), អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ (ឆ្នាំ២០០៧), និងអនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច (ឆ្នាំ២០០៨), អនុក្រឹត្យស្តីពី ការកំណត់ល្បឿនសម្រាប់យានជំនិះ (ឆ្នាំ២០១៤) បទបញ្ជាលេខ ០០១ បប របស់រាជរដ្ឋាភិបាលចុះថ្ងៃទី ៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច, គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (ឆ្នាំ ២០០៩), សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី (ឆ្នាំ២០០៩), ប្រកាសស្តីពីគោលការណ៍ណែនាំទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ (ឆ្នាំ២០០៩), ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៣), ប្រកាសអន្តរក្រសួងស្តីពីការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច (ឆ្នាំ២០១៤)។

២.៣. ការសិក្សាអំពីធនធានបរិស្ថានដែលមានស្រាប់

២.៣.១. ការកំណត់ទំហំសិក្សា

វិសាលភាពនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ ត្រូវបានធ្វើឡើងជាជំហានៗដូចខាងក្រោម ៖

- ជំហានទី១៖ ដែននៃការសិក្សា ត្រូវបានកំណត់ក្នុងរង្វង់ ៥ គីឡូម៉ែត្រជុំវិញតំបន់គម្រោង

- ជំហានទី២៖ ប៉ារ៉ាម៉ែត្រមួយចំនួន នឹងត្រូវបង្រួមមកត្រឹមដែនកំណត់ជាក់លាក់ថ្មីមួយ (ឧ.ភូគព្ភសាស្ត្រ ឋានលេខា កម្រិតជម្រាល ធនធានព្រៃឈើ ព្រមទាំងបញ្ហាទំនាស់ដីធ្លី ដែលត្រូវបានសិក្សាតែក្នុងទីតាំងគម្រោង) ឱ្យស្របទៅតាមទំហំនៃផលប៉ះពាល់ជាក់ស្តែង និងភាពលម្អិតនៃលទ្ធផលដែលចង់បាន។

ដែនកំណត់នៃការសិក្សាសម្រាប់ធនធាននីមួយៗ មានបង្ហាញលម្អិតដូចតទៅ៖

២.៣.២. ធនធានបរិស្ថានរូបសាស្ត្រ

ការសិក្សាលើបរិស្ថានរូបសាស្ត្រ ត្រូវបានធ្វើឡើងក្នុងគោលបំណងស្វែងយល់អំពីបម្រែបម្រួលស្ថានភាពធនធានរូបសាស្ត្រនៅក្នុងទីតាំងគម្រោង ព្រមទាំងទីតាំងមួយចំនួននៅជុំវិញបរិវេណទីតាំងគម្រោងដែលអាចទទួលរងនូវផលប៉ះពាល់ទាំងផ្ទៃមាន និងអរូបីមាន ក្នុងកំឡុងពេលសាងសង់គម្រោង ដំណើរការគម្រោង និងពេលបញ្ចប់គម្រោង។ យោងតាមគោលបំណងខាងលើ យើងបានធ្វើការសិក្សាវិភាគទៅលើធនធានរូបសាស្ត្រដែលមានស្រាប់នៅក្នុងតំបន់ជាប់ពាក់ពន្ធ័ រួមមានទីតាំងគម្រោងផ្ទាល់ និងបរិវេណ ៥គីឡូម៉ែត្រជុំវិញគម្រោង។ ដំណើរការនៃការសិក្សានេះ ត្រូវបានធ្វើឡើងដោយពឹងផ្អែកលើប្រភពព័ត៌មានសំខាន់ៗ ០២ គឺ ព័ត៌មានបន្ទាប់បន្សំ (តាមរយៈឯកសារដែលទទួលបានពីស្ថាប័ននានា) និងព័ត៌មានបឋមដែលបានមកពីការចុះសិក្សាប្រមូលទិន្នន័យដោយក្រុមការងារយើងផ្ទាល់។ ចំពោះវិធីសាស្ត្រដែលប្រើប្រាស់ក្នុងដំណើរការសិក្សានេះ គឺមានភាពចម្រុះ និងប្រែប្រួលអាស្រ័យទៅលើកត្តា ឬ ប៉ារ៉ាម៉ែត្រដែលត្រូវវិភាគដែលមានជារួមដូចជា៖

(១) ភូគព្ភសាស្ត្រ ឋានលេខា សណ្ឋានដី ការហូរច្រោះ ប្រភេទដី និងគុណភាពដី

(២) អាកាសធាតុ រួមមាន សីតុណ្ហភាព និងរបបទឹកភ្លៀង

(៣) គុណភាពខ្យល់ កម្រិតសំឡេង និងរំញ័រ

(៤) ប្រព័ន្ធជលសាស្ត្រ បរិមាណ និងគុណភាពទឹកលើដី និងក្រោមដី។

សេចក្តីលម្អិតអំពីវិធីសាស្ត្រនៃការវិភាគសម្រាប់កត្តានីមួយៗ មានចែងនៅក្នុងកថាខណ្ឌខាងក្រោម។

Draft

២.៣.២.១. ធនធានសាស្ត្រ

ក្នុងការសិក្សាអំពីភូគព្ភសាស្ត្រ យើងបានធ្វើការវិភាគទៅលើប៉ារ៉ាម៉ែត្រសំខាន់ៗមួយចំនួនដូចជា៖ ប្រភេទសិលាមេ និងស័កនៃសិលាមេដែលជាកស្តុតាងមួយបង្ហាញពីការកកើតដី និងធនធានរ៉ែនៅក្នុងទីតាំងគម្រោង ក៏ដូចជាតំបន់ជុំវិញទីតាំងគម្រោង។

ការសិក្សានេះ ត្រូវបានធ្វើឡើងដោយពឹងផ្អែកលើផែនទីភូគព្ភសាស្ត្រ (Geological map) ឆ្នាំ២០០២ ដែលរៀបចំឡើងដោយសមាគមសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ដោយឡែកចំពោះវិធីសាស្ត្រក្នុងការវិភាគ និងទាញយកព័ត៌មានពីផែនទីដែលមានស្រាប់នេះ ត្រូវបានធ្វើឡើងដោយបច្ចេកវិទ្យាកុំព្យូទ័រតាមរយៈកម្មវិធី ArcGIS10.0។ បន្ថែមលើនេះ យើងបានធ្វើការផ្ទៀងផ្ទាត់ឡើងវិញចំពោះព័ត៌មានដែលទទួលបានពីផែនទីខាងលើ ដោយធ្វើការចុះពិនិត្យជាក់ស្តែងនៅក្នុងអំឡុងពេលសិក្សា។

២.៣.២.២. សណ្ឋានដី/ថាន់លេខា និងទីជម្រាល

នៅក្នុងផ្នែកនេះ យើងបានធ្វើការវិភាគទៅលើលក្ខណៈសណ្ឋានដី និងរយៈកម្ពស់នៃផ្ទៃដីនៅក្នុង និងក្បែរទីតាំងគម្រោង។ ដំណើរការនៃការវិភាគ ត្រូវបានធ្វើឡើងដោយផ្អែកលើទិន្នន័យមួយចំនួនរួមមាន ផែនទីរយៈកម្ពស់ដី (Contour map) ដែលជាទិន្នន័យមានស្រាប់រៀបចំដោយ JICA ក្នុងឆ្នាំ២០០២ និងទិន្នន័យគោលដែលទទួលបានពីការចុះវាស់វែង និងពិនិត្យផ្ទាល់ភ្នែកនៅក្នុងអំឡុងពេលសិក្សា។ ដោយពឹងផ្អែកទៅលើទិន្នន័យទាំងពីរខាងលើ យើងបានរៀបចំផែនទីលម្អិតបង្ហាញពីស្ថានភាពដើមនៃសណ្ឋានដី ទីតាំង និងកម្រិតជម្រាលនៃផ្ទៃដីនៅក្នុងទីតាំងគម្រោង ព្រមទាំងបរិវេណជុំវិញទីតាំងគំរោង។ ដោយឡែកចំពោះផែនទីដែលបង្ហាញពីស្ថានភាពទីជម្រាលត្រូវបានយកទៅប្រើប្រាស់រួមជាមួយព័ត៌មានផ្សេងៗទៀត ដើម្បីកំណត់រកភាពសឹករេចរឹលនៃស្រទាប់ដីផ្នែកខាងលើដែលអាចនឹងកើតមានឡើង។ នៅក្នុងការសិក្សានេះ យើងក៏បានប្រើប្រាស់ឧបករណ៍ និងសម្ភារជំនួយមួយចំនួនដូចជា GPS, PDF Maps និងម៉ាស៊ីនថតរូប។

២.៣.២.៣. ចំណាត់ថ្នាក់ប្រភេទដី និងគុណភាពដី

ការសិក្សាអំពីចំណាត់ថ្នាក់ប្រភេទដី និងគុណភាពដី ត្រូវបានធ្វើឡើងក្នុងគោលបំណងស្វែងយល់អំពីចរិកលក្ខណៈនៃដីដែលមាននៅក្នុងទីតាំងគម្រោង។ ក្នុងដំណើរការនៃការសិក្សានេះ យើងបានធ្វើការវិភាគទៅលើកត្តាដែលបង្ហាញពីលក្ខណៈរូបនៃដីដូចជា៖ ប្រភេទដី វាយនភាពរបស់ដី(ភាគរយនៃខ្សាច់ ល្បាប់ និងឥដ្ឋរបស់ប្រភេទដីនីមួយៗ) ទម្រង់នៃដី និងកម្រិតភាពសើមនៃដី។ បន្ថែមលើនេះ យើងក៏បានវិភាគលើប៉ារ៉ាម៉ែត្រមួយចំនួនដែលជាកត្តាបង្ហាញពីកម្រិតគុណភាពដី (លក្ខណៈគីមីដី)នៃដី) នៅក្នុងទីតាំងគម្រោង។ ការកំណត់ចំណាត់ថ្នាក់ប្រភេទដីនិងគុណភាពដីនៅក្នុងដំណាក់កាលចាប់ផ្តើមគម្រោងមានសារៈសំខាន់ណាស់ ដើម្បីបង្កើតទិន្នន័យគោលសម្រាប់ធ្វើការផ្ទៀងផ្ទាត់ និងតាមដានកម្រិតនៃផលប៉ះពាល់គុណភាពដីនៅកំឡុងពេលដំណើរការគម្រោង។

ការកំណត់ចំណាត់ថ្នាក់ប្រភេទដីនៅក្នុងតំបន់គម្រោង ត្រូវបានធ្វើឡើងតាមរយៈការវិភាគលើទិន្នន័យបន្ទាប់បន្សំ ដូចជាឯកសារស្រាវជ្រាវពីប្រភេទដីនៅក្នុងប្រទេសកម្ពុជា របស់លោក D. Crocker, 1962 និងផែនទីបែងចែកប្រភេទដី (Soil type) របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)។ ចំពោះការសិក្សាពីវាយនភាពរបស់ដី សំណើមដី និងគុណភាពដី ត្រូវបានធ្វើឡើងតាមរយៈការអង្កេតផ្ទាល់ និងការយកសំណាកដីមកវិភាគនៅមន្ទីពិសោធន៍ក្រសួងបរិស្ថាន។ ទីតាំងយកសំណាកដី ត្រូវបានកំណត់យកដោយផ្អែកលើកត្តាពីរយ៉ាង៖ ទី១-ស្ថានភាពជាក់ស្តែងនៃប្រភេទដីដែលមានក្នុងទីតាំងគម្រោង (៣ប្រភេទដី៖ Acid Lithosols, Grey hydromorphics, និង Plinthite podzolsយោងតាមផែនទីប្រភេទដីរបស់ JICA ឆ្នាំ២០០២)

និងទី២- ទីតាំងអនុតំបន់នៃគម្រោង (៤អនុតំបន់) ដែលជាដែនកំណត់សកម្មភាពផ្សេងៗនៃគម្រោង។ សំណាកដី ចំនួន ៥ ដែលតំណាងឱ្យគ្រប់ប្រភេទដី និងស្ថិតនៅគ្រប់អនុតំបន់របស់គម្រោង ត្រូវបានជ្រើសរើសយកមកធ្វើការវិភាគ (តារាង២.១ និង ផែនទី២.៣)។

តារាង២.១៖ ចំណុចនិយាមកាទីតាំងយកសំណាកដី និងប៉ារ៉ាម៉ែត្រដែលត្រូវសិក្សា


ល.រ	ឈ្មោះសំណាក	ចំណុចនិយាមកា		ប៉ារ៉ាម៉ែត្រដែលត្រូវវិភាគ
		អាប់ស៊ីស(X)	អរដោណេ(Y)	
1	SS1-1	678072	1514980	-វាយតាពរបស់ដី -ទម្រង់របស់ដី (profile) -សំណើមដី -កត្តាគីមីដីរ:
2	SS2-1	680729	1523234	
3	SS3-1	692579	1534321	
4	SS3-2	684469	1527495	
5	SS3-3	698273	1540001	

<u>សម្គាល់៖</u>

- Datum: WGS 1984
- ទីតាំងយកសំណាកដីត្រូវបានបែងចែងតាមប្រភេទដី និងទីប្រជុំទម្ងន់របស់អនុតំបន់ Zone I, II , III និង IV រួមមាន៖
  - ✓ សំណាកដី SS1-1 គឺប្រភេទដី Plinthite podzols នៅត្រង់ចំណុចទីប្រជុំទម្ងន់ Zone I
  - ✓ សំណាកដី SS2-1 គឺប្រភេទដី Acid Lithosols នៅត្រង់ចំណុចទីប្រជុំទម្ងន់ Zone II
  - ✓ សំណាកដី SS3-2 និង SS3-3 គឺប្រភេទដី Grey hydromorphics ដែលស្ថិតនៅត្រង់ប្រជុំទម្ងន់នៃផ្នែកទាំងពីររបស់ Zone III
  - ✓ សំណាកដី SS3-3 គឺប្រភេទដី Grey hydromorphics នៅត្រង់ចំណុចទីប្រជុំទម្ងន់នៃ Zone II


Draft

ផែនទី២.១៖ ប្រភេទដី ទីតាំងយកសំណាកដី ទីតាំងពិនិត្យសំណឹកនិងការហូរច្រោះដី



- ការយកសំណាកដី ត្រូវបានធ្វើឡើងដោយប្រើវិធីសាស្ត្រ (D. Crocker, 1962) ដូចខាងក្រោម៖
  1) រៀបចំទីតាំងយកសំណាក (quadrangle) ដោយកំណត់យកផ្ទៃដីទំហំ ១ម៉ែត្រ បួនជ្រុងនៅទីតាំងយកសំណាក
  2) សម្អាតដីស្រទាប់លើប្រមាណ ១សម - ៣សម ឱ្យស្អាតដោយប្រើប្រាស់ចបដីក
  3) ចាប់យកសំណាកដីពីត្រង់ចំណុចកែងទាំង៤ និងត្រង់ចំណុចប្រសព្វនៃអង្កត់ទ្រូងរបស់ការ៉េដែលបានកំណត់ខាងលើ (សូមមើលរូបភាព៤.៣.២) ដោយប្រើប្រាស់ដែកខួង (Soil Probe) ខួងយកដីនៅជម្រៅប្រហែល ១០សម ទៅ ៤០សម
  4) លាយសំណាកដីដែលចាប់យកពីចំណុចទាំង ៥ខាងលើបញ្ចូលគ្នា ហើយបែងចែកជា ៤ ផ្នែក បន្ទាប់មករើសយកមួយផ្នែក (ចំណុះ ២គ.ក្រ) ធ្វើការវេចខ្ចប់ទុកក្នុងថង់ប្លាស្ទិកស្អាត ដោយមានភ្ជាប់ជាមួយលេខសម្គាល់នៃសំណាកដីសម្រាប់យកមកធ្វើការវិភាគនៅមន្ទីរពិសោធន៍។

រូបភាព២.១៖ វិធីសាស្ត្រយកសំណាក់ដី



- ឧបករណ៍ដែលចាំបាច់សម្រាប់ប្រើប្រាស់ក្នុងការសិក្សាពីគុណភាពដីនេះ មានដូចជា៖ ដែកខួង (ប្រវែង ១,៥ម៉ែត្រ ដែលមានផ្ទៃខួងទំហំអង្កត់ផ្ចិត ១,២៥ សម) ចបដីកសម្រាប់ជំរះស្មៅផ្នែកខាងលើ ប៉ែលមូលដងខ្លី ខ្សែជុំមូល សៀវភៅកត់ត្រា ស្បោងសម្រាប់ខ្ចប់សំណាកដី(១០គ.ក្រ) ម៉ែត្រសម្រាប់វាស់ ចបកាប់ដី ម៉ែត្រក្រិត GPS និងម៉ាស៊ីនថត។
- ការវិភាគគុណភាពដី ត្រូវបានធ្វើឡើងនៅមន្ទីរពិសោធន៍នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា លើប៉ារ៉ាម៉ែត្រដូចខាងក្រោម៖

តារាង២.២៖ ប៉ារ៉ាម៉ែត្រវិភាគដី

ល.រ	ប៉ារ៉ាម៉ែត្រ	ខ្នាត	ស្តង់ដារ	វិធីសាស្ត្រវិភាគ
1	pH	-	-	3110 pH Meter
2	Organic matter	%	-	Fixed and Volatile Solids Ignited at 550 °C
3	Copper	mg/kg dry	-	Atomic absorption spectrophotometry
4	Zinc	mg/kg dry	<140	Atomic absorption spectrophotometry
5	Lead	mg/kg dry	<85	Atomic absorption spectrophotometry
6	Arsenic	mg/kg dry	<15	Atomic absorption spectrophotometry
7	Total nitrogen	%	-	Kjeldahl Buchi System
8	Phosphorus	mg/L	-	Test-Kite, HACH DR-850

Draft

9	Nitrites	mg/L	-	Test-Kite, HACH DR-850
10	Ammonia	%	-	Test-Kite, HACH DR-850
11	Cadmium	ug/g dry	-	Atomic absorption spectrophotometry
សំគាល់៖ ស្តង់ដារ គឺប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ដែលអនុញ្ញាឱ្យបោះបង់ចោល(២០១៥)				

២.៣.២.៤ សំណឹក និងកំណកដី (erosion and deposition)

ការសិក្សាអំពីសំណឹក និងកំណកដី ត្រូវបានធ្វើឡើងក្នុងគោលបំណងស្វែងយល់ពីទីតាំងដែលអាចប្រឈមនឹងបញ្ហាសំណឹក ឬ កំណកដីដោយសារបុព្វហេតុផ្សេងៗ។ ការសិក្សានេះ ត្រូវបានធ្វើឡើងដោយផ្អែកលើទិន្នន័យមួយចំនួនដូចជា៖ ផែនទីស្ថានភាពទីជម្រាល ផែនទីប្រភេទដី និងរបាយទឹកភ្លៀង ដែលសុទ្ធសឹងជាព័ត៌មានបន្ទាប់បន្សំដែលទទួលបានពីស្ថាប័ននានា ជាពិសេសទិន្នន័យដែលរៀបចំឡើងដោយ JICA ឆ្នាំ២០០២។

ការកំណត់ទីតាំងសម្រាប់សិក្សាពីសំណឹក និងកំណកដី ត្រូវបានធ្វើឡើងដោយយកកម្រិតជម្រាលនៃដីជាមូលដ្ឋាន។ តំបន់ដែលមានជម្រាលខ្ពស់ គឺជាតំបន់ដែលងាយរងនូវសំណឹក ដូច្នេះវាគឺជាតំបន់ដែលមានលក្ខណៈសមស្របសម្រាប់ធ្វើការសិក្សា។ តាមរយៈផែនទីចំណាត់ថ្នាក់ទីជម្រាល យើងឃើញថានៅក្នុងទីតាំងគម្រោងកម្រិតជម្រាលមានសភាពប្រែប្រួលពី ០ ទៅ ១០ភាគរយ។ កន្លែងដែលមានជម្រាលខ្ពស់ចំនួន ០៥កន្លែង ត្រូវបានកំណត់យកជាទីតាំងដើម្បីធ្វើការអង្កេតមើលសំណឹក និងកំណកដីក្នុងដំណើរការនៃការសិក្សានេះ។ ទីតាំងដែលបានជ្រើសរើសសម្រាប់ការសិក្សានេះ មានបង្ហាញនៅលើផែនទី២.៣ខាងលើ។

ការវិភាគពីសំណឹកដី និងកំណកដី ត្រូវបានធ្វើឡើងតាមបែប Dynamic ដែលជាការវិធីសាស្ត្រវិភាគដោយផ្អែកទៅលើផែនទីដែលបង្ហាញសណ្ឋាននៃសំណឹក (erosion feature) និងកត្តាដែលមានឥទ្ធិពលទៅលើសំណឹកទាំងនោះរួមមាន៖ ប្រភេទដី ការហូរច្រោះនៃទឹក ប្រវែងនៃទីជម្រាល ជំហាននៃទីជម្រាល ការប្រើប្រាស់ដី និងគម្របដី ជាដើម (Morgan, 2005)។ ការវិភាគនេះ ត្រូវបានធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

1) ដំណាក់កាលទី១៖ ស្វែងរក និងសិក្សាទៅលើព័ត៌មានដែលមានស្រាប់ទាក់ទងទៅនឹងការហូរច្រោះ និងកំណកដីនៅក្នុងតំបន់គម្រោង សិក្សាអំពីទ្រឹស្តីដែលបង្កឲ្យមានសំណឹកដី និងកំណកដី ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយស្ថានភាពជាក់ស្តែងនៃសំណឹក និងកំណកដីដែលមានស្រាប់នៅក្នុង និងជុំវិញតំបន់គម្រោង។
2) ដំណាក់កាលទី២៖ ចុះពិនិត្យ និងផ្ទៀងផ្ទាត់ជាក់ស្តែងពីស្ថានភាពសំណឹកដី និងកំណកដីនៅក្នុង និងជុំវិញតំបន់គម្រោង តាមរយៈការអង្កេតផ្ទាល់ និងការសម្ភាសន៍ជាមួយប្រជាពលរដ្ឋ។
3) ដំណាក់កាលទី៣៖ វិភាគទិន្នន័យ និងព័ត៌មានដែលប្រមូលបាន ដើម្បីរៀបចំជារបាយការណ៍ និងធ្វើផែនទីបែងចែកចំណាត់ថ្នាក់ប្រភេទសំណឹកដីទៅតាមតារាងចំណាត់ថ្នាក់សំណឹកដី។

២.៣.២.៥. អាកាសធាតុ

ការសិក្សាអំពីកត្តាអាកាសធាតុ គឺដើម្បីស្វែងយល់ពីស្ថានភាពសីតុណ្ហភាព និងរបបទឹកភ្លៀង ព្រមទាំងបម្រែបម្រួលដែលកើតមាននៅក្នុងតំបន់គម្រោង។ ការសិក្សានេះ ត្រូវបានធ្វើឡើងដោយការវិភាគទៅលើទិន្នន័យប្រវត្តិនៃស្ថានភាពអាកាសធាតុនៅក្នុងតំបន់សិក្សា ក្នុងកំឡុងពេល ០៥ឆ្នាំចុងក្រោយ (២០១១-២០១៦)។ ពត៌មានទាំងនេះ ទទួលបានពីក្រសួងធនធានទឹក និងឧតុនិយម។

២.៣.២.៦.១ គុណភាពខ្យល់

ការសិក្សាពីគុណភាពខ្យល់ ត្រូវពឹងផ្អែកលើលទ្ធផលដែលមានស្រាប់ ដែលទទួលបានពីការយកសំណាកខ្យល់រយៈពេល ២៤ម៉ោង កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ នៅក្បែរទីតាំងគម្រោង (និយាមកា៖ ០៧១២២៧១ / ១៥២៣៣៥០ នៅក្នុងភូមិជួយអំពិល ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី) ហើយការយកសំណាក និងការវិភាគគុណភាពខ្យល់ នឹងត្រូវធ្វើឡើងដោយមន្ត្រីជំនាញនៃមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។ លទ្ធផលនៃគុណភាពខ្យល់ដែលទទួលបាន នឹងត្រូវប្រៀបធៀបនឹងកម្រិតស្តង់ដារគុណភាពខ្យល់ដែលកំណត់នៅក្នុងអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ (សម្រាប់ប៉ារ៉ាម៉ែត្រ CO, NO2, SO2, និង TSP) និងស្តង់ដាររបស់អង្គការសុខភាពពិភពលោក (WHO) ឆ្នាំ២០០៥ (សម្រាប់ប៉ារ៉ាម៉ែត្រ PM10 និង PM2.5)។

២.៣.២.៦.២ កម្រិតសំឡេង

ការសិក្សាពីកម្រិតសំឡេង ត្រូវបានធ្វើឡើងក្នុងរយៈពេល ២៤ម៉ោង នៅក្នុងទីតាំងគម្រោង (និយាមកា ៖ ០៦៧៧៥៧៩/១៥១០២៦៨) ដោយក្រុមការងារយើងផ្ទាល់។ កម្រិតសំឡេង គិតជា dB(A) ត្រូវបានវាស់ដោយឧបករណ៍ NTi Audio XL2 ដែលទទួលស្គាល់ដោយISO/IEC 17025។ ចំពោះ លទ្ធផលវាស់កម្រិតសំឡេងដែលទទួលបាន នឹងត្រូវវិភាគធៀបនឹងកម្រិតកំណត់ស្តង់ដារសំឡេងអតិបរមា ដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ដែលកំណត់នៅក្នុងអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។

តារាង២-៣៖ ការវិភាគកម្រិតសំឡេង

ល.រ	កម្រិតសំឡេង (គិតជា dB)	ស្តង់ដារកម្រិតសំឡេង (គិតជា dB)
1	ពីម៉ោង 6:00 – 18:00	60
2	ពីម៉ោង 19:00 – 22:00	50
3	ពីម៉ោង 00:00 – 5:00	45

២.៣.២.៦.៣ កម្រិតរំញ័រ

ចំណែកឯការវាស់កម្រិតរំញ័រ គឺត្រូវបានធ្វើឡើងក្នុងរយៈពេល ២៤ម៉ោង នៅក្នុងទីតាំងគម្រោង (និយាមកា៖ ០៦៧៧៥៧៩/១៥១០២៦៨) ដោយក្រុមការងារយើងផ្ទាល់ដូចគ្នានឹងសំឡេងដែរ ហើយរញ្ជែរ គឺគិតជា mm/s^2 ត្រូវបានធ្វើឡើងដោយប្រើប្រាស់នូវឧបករណ៍ Instantel Micromate ដែលទទួលស្គាល់ដោយ National Institute of Standards and Technology, NationalResearch Council of Canada)។ សម្រាប់ប្រទេសកម្ពុជាមិនទាន់មានស្តង់ដារំញ័រទេ ដូច្នេះកម្រិតរញ្ជែរនឹងវិភាគដោយប្រៀបធៀបជាមួយស្តង់ដារកម្រិតរញ្ជែររបស់ប្រទេសជប៉ុន ដែលកំណត់អំពីកម្រិតនៃរញ្ជែរដែលអាចមានផលជាអវិជ្ជមានចំពោះសំណង់លំនៅដ្ឋាន។

តារាង២-៤៖ ការវិភាគកម្រិតរំញ័រ

ល.រ	កម្រិតរំញ័រ (គិតជា dB)	ស្តង់ដារកម្រិតរំញ័រ (គិតជា dB)
1	ពីម៉ោង 6:00 – 18:00	65
2	ពីម៉ោង 19:00 – 5:00	60

២.៣.២.៧. ជលសាស្ត្រ និងគុណភាពទឹក

ក. ប្រព័ន្ធផ្លូវទឹក


គោលបំណងនៃការសិក្សាពីប្រព័ន្ធផ្លូវទឹក គឺដើម្បីស្វែងយល់ពីវត្តមាននៃប្រភពទឹកដែលមាននៅក្នុងទីតាំងគម្រោង បរិវេណជុំវិញគម្រោង និងស្ថានភាពទូទៅនៃប្រភពទឹកទាំងនោះដែលមានដូចជា៖ ប្រភព ប្រវែង ទទឹង

(ទំហំ) ជម្រៅ ទិសដៅទឹកហូរ លទ្ធភាពនៃការផ្គត់ផ្គង់ទឹក ស្ថានភាពនៃការប្រើប្រាស់បច្ចុប្បន្ន គុណភាពទឹក និងទំនាក់ទំនងជាមួយប្រភពទឹកផ្សេងៗទៀតដែលមាននៅក្បែរ ឬក្នុងតំបន់គម្រោង។ ការស្វែងយល់អំពីព័ត៌មានទាំងនេះ មានសារៈសំខាន់ណាស់ក្នុងការរៀបចំទិន្នន័យគោលសម្រាប់ធ្វើការវិភាគ តាមដានពីបម្រែបម្រួលប្រភពទឹកទាំងគុណភាព និងបរិមាណ (ផលប៉ះពាល់) ដែលអាចនឹងកើតមានឡើងក្នុងកំឡុងពេលដំណើរការគម្រោង។

តាមរយៈផែនទីប្រព័ន្ធផ្លូវទឹករបស់JICA ឆ្នាំ២០០២ និងព័ត៌មានដែលទទួលបានពីការចុះពិនិត្យ និងពិភាក្សាជាមួយប្រជាពលរដ្ឋដែលរស់នៅក្បែតំបន់គម្រោងផ្ទាល់ ក្រៅពីទន្លេសេសាន នៅក្នុងតំបន់គម្រោងមានប្រព័ន្ធផ្លូវទឹកសំខាន់ៗចំនួន ០៧ (អូរក្នុំ អូរតាង ពាមមាត់អូរ អូតាឡាត អូរជរិក អូរកន្សែង និងអូរស្វាយរៀង) ដែលជាប់ពាក់ព័ន្ធ និងចាំបាច់ត្រូវធ្វើការសិក្សា (ផែនទី២.៤)។ ក្នុងការសិក្សានេះ យើងបានដើរពិនិត្យមើលស្ថានភាពផ្លូវទឹកនីមួយៗ ចាប់ពីក្បាលផ្លូវទឹក រហូតដល់ទន្លេសេសាន ដោយមានឧបករណ៍ជំនួយដូចជា៖ GPS, PDF maps, ម៉ាស៊ីនថត, និងម៉ែត្រវាស់។ ការសម្ភាសន៍ជាមួយប្រជាជនដែលរស់នៅតាមដងអូរនីមួយៗ ក៏ត្រូវបានធ្វើឡើងដែរ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានឡើងវិញ។

Draft

ផែនទី២.២៖ ទីតាំងអង្គតប្រព័ន្ធផ្លូវទឹក



Cord	X	Y	Name	ឃុំភូមិ
WW1	688837	1533464	ពាមមាត់អូរ	ពាមមាត់អូរ
WW2	693251.2	1533574	ពាមមាត់អូរ	
WW3	689911	1527338	អូរជីត	អូរជីត
WW4	685494	1530596	អូរជីត	
WW5	690630	1529137	អូរកន្ទែង	អូរកន្ទែង
WW6	688145	1531654	អូរកន្ទែង	
WW7	690327	1538776	អូរភ្លឺ	អូរភ្លឺ
WW8	694805	1540810	អូរភ្លឺ	
WW9	666595	1515547	អូរស្វាយរបែង	អូរស្វាយរបែង
WW10	667281.5	1515069	អូរស្វាយរបែង	
WW11	690235	1537280	អូរតាវ	អូរតាវ
WW12	695379	1535491	អូរតាវ	
WW13	679698	1524422	អូរតាឡាត	អូរតាឡាត
WW14	681987.1	1521221	អូរតាឡាត	

ខ. គុណភាពទឹក

គោលបំណងចម្បងនៃការសិក្សាពីគុណភាពទឹក គឺដើម្បីកំណត់នូវស្ថានភាពបច្ចុប្បន្ននៃគុណភាពទឹកទាំងទឹកលើដី និងទឹកក្រោមដី ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ធ្វើឯកផ្ទាត់ និងតាមដានបម្រែបម្រួលគុណភាពទឹកក្នុងកំឡុងពេលដំណើរការគម្រោង។ ក្នុងការសិក្សាពីបញ្ហាគុណភាពទឹក យើងបានយកសំណាកទឹកនៅតាមដងអូរពាក់ព័ន្ធ (ទឹកលើដី) និងសំណាកទឹកអណ្តូង (ទឹកក្រោមដី) មកវិភាគនៅមន្ទីរពិសោធន៍។ ចំពោះទឹកលើដី យើងបានធ្វើការអង្កេតនៅទីតាំងយកសំណាក និងតំបន់លើខ្សែទឹកអំពីកត្តាដែលអាចនាំឱ្យមានបម្រែបម្រួលគុណភាពទឹកក្នុងពេលបច្ចុប្បន្ន។ ស្រដៀងគ្នានេះដែរ ចំពោះទឹកអណ្តូង យើងបានធ្វើការអង្កេតស្ថានភាពទូទៅនៅជុំវិញ និងក្បែរទីតាំងយកសំណាក ដើម្បីកំណត់ពីកត្តាដែលអាចមានឥទ្ធិពលលើគុណភាពទឹក។

ខ១. ទឹកលើដី

សំណាកទឹកលើដីចំនួន ៧ ត្រូវបានយកនៅតាមដងអូរនីមួយៗ ដោយផ្អែកទៅលើផែនទីរយៈកម្ពស់ដី ទិសដៅទឹកហូរ និងស្ថានភាពជាក់ស្តែងនៃប្រភពទឹកនីមួយៗធៀបនឹងទីតាំងគម្រោង (ផែនទី២.៤)។ ដើម្បីងាយស្រួលក្នុងការស្វែងរកទីតាំងយកសំណាកទឹក យើងបានប្រើប្រាស់កម្មវិធី PDF Maps នៅក្នុងទូរស័ព្ទដៃ (smart phone) ដោយធ្វើការបញ្ចូលផែនទីទីតាំងគម្រោង និងចំណុចនិយាមកានៃទីតាំងដែលត្រូវយកសំណាកទឹក ហើយភាពជាក់លាក់នៃទីតាំងដែលត្រូវយកសំណាក ត្រូវបានធ្វើឯកផ្ទាត់ដោយឧបករណ៍ GPS-62SC និង GPS-76CSX ដែលមានកម្រិតលម្អៀងប្រមាណ ៣ម៉ែត្រ។

ការយកសំណាកទឹក ត្រូវបានធ្វើឡើងដោយគោរពតាមគោលការណ៍ណែនាំរបស់ មន្ទីរពិសោធន៍ នៃក្រសួងបរិស្ថាន។ សំណាកទឹកលើដីត្រូវបានយកដោយប្រើប្រាស់នូវវិធីសាស្ត្រ ដូចខាងក្រោម៖

- ដបសំណាកទឹក គឺប្រើប្រាស់ដបទឹកបរិសុទ្ធដែលមិនទាន់បានប្រើប្រាស់ប្រភេទ ចំណុះ១,៥លីត្រ ចំនួន ១ដប និង ០,៥លីត្រ ចំនួន១ដប សម្រាប់យកសំណាកទឹកក្នុងមួយទីតាំង (ដបចំណុះ០,៥លីត្រ សម្រាប់យកសំណាកទឹកដោយមិនឲ្យមានអុកស៊ីសែននៅក្នុងដប)
- មុនពេលយកសំណាកទឹក ត្រូវលាងដបដាក់សំណាកជាមួយនឹងទឹកសំណាកយ៉ាងតិច០៣ដង
- ការយកសំណាក ត្រូវឈរប្រឈមនឹងខ្សែទឹករួចយកទឹកដែលស្ថិតនៅខាងមុខកន្លែងដែលឈរ ព្រមទាំងជ្រមុជដបក្នុងជម្រៅផ្ទៃទឹក
- ត្រូវសរសេរលេខកូដភាគសំណាក កាលបរិច្ឆេទ និងម៉ោងប្រមូលភាគសំណាកឲ្យច្បាស់លាស់លើដប ភាគសំណាកចំណុះ ១,៥លីត្រ ដោយប្រើប្រាស់ហ្វឺតលុបមិនចេញ។ ចំណាំ៖ ការសរសេរដោយទឹកប៉ិចទំនងជារលុប ឬប្រតាកខ្លាំង។
- អង្កេតពិនិត្យតំបន់យកសំណាកទឹកដូចជាទ្រង់ទ្រាយស្ថានភាពជុំវិញប្រភពទឹក ស្ថានភាពទឹក (ពណ៌ និងក្លិន) និងសីតុណ្ហភាព។ ជាមួយគ្នានេះ ការសម្ភាសន៍ ក៏ត្រូវបានអនុវត្តផងដែរចំពោះប្រជាជនដូនយកសំណាកទឹក ដើម្បីយល់ដឹងអំពីឈ្មោះប្រភពទឹក និងការប្រើប្រាស់របស់វា
- យកសំណាកទឹកដែលបានយករួច ដាក់នៅក្នុងធុងទឹកកកដែលមានសីតុណ្ហភាពថេរ ៤^{o}C រួចដឹកជញ្ជូនទៅមន្ទីរពិសោធន៍ មិនឲ្យលើសពី៤២ម៉ោងឡើយ។

តារាង២-៥៖ ប៉ារ៉ាម៉ែត្រវិភាគទឹកលើដី

ល.រ	ប៉ារ៉ាម៉ែត្រ	ខ្នាត	ស្តង់ដារ	វិធីសាស្ត្រវិភាគ
1	pH	-	-	-

2	Do	mg/L	2.0-7.5	Method MAJI meter
3	TSS	mg/L	25-100	Method 2540 D
4	Cl^-	mg/L	NV	Method 4500-Cl F
5	BOD_5	mg/L	1.0-10	Method 5210 B
6	COD_{Mn}	mg/L	NV	Method JIS K 0102
7	TN	mg/L	0.1-0.6	Method JIS K 0102 45
8	TP	mg/L	0.005-0.05	Method JIS K 0102 46
9	As	mg/L	>0.01	Method Digital Arsenator
10	Cr6	mg/L	NV	Method 3060 A
11	Fe total	mg/L	NV	Method Photometer S7000
12	Hg-total	mg/L	<0.005	Method Metalyser HM1003
13	Total Coliform	MPN/100ml	>5000	Method NF T90-413

សម្គាល់៖

1-ការយកសំណាក ការក្សាទុក និងការដឹកជញ្ជូនសំណាកទឹកមកមន្ទីរពិសោធន៍ ក្រុមហ៊ុន (គម្រោង) អនុវត្តដោយខ្លួនឯង

2- Standards កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិរក្សជីវៈចម្រុះនៅក្នុងទឹក និងសម្រាប់ការពារសុខភាពសាធារណៈ

3- LDL mean Lowest Detection Limit, ND Mean Not Detected (Lower than LDL). NV Mean No Value.

4- Parameters: Dissolved Oxygen (DO); Total Suspended (TSS); Chloride (CL); Biochemical Oxygen demand (BOD)5; Chemical Oxygen demand (COD)Mn; Total Nitrogen (TN); Total Phosphorus (TP); Arsenic (As); Chromium Hexavalent (Cr6); Iron (Fe-total); Mercury (Hg-total); Total Coliform

ខ២. ទឹកក្រោមដី (ទឹកអណ្តូង)

សំណាកទឹកក្រោមដីចំនួន ៣ ត្រូវបានយកពីអណ្តូងទឹកដែលមាននៅក្បែរទីតាំងគម្រោង (ផែនទី២.៤) ទៅវិភាគនៅមន្ទីរពិសោធន៍។ ការសម្ភាសន៍ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ត្រូវបានអនុវត្តជាដំបូងមុននឹងឈានទៅកំណត់ទីតាំងយកសំណាកទឹកក្រោមដី។ ការសម្ភាសន៍នេះ គឺធ្វើឡើងដើម្បីស្វែងយល់ថា តើមានអណ្តូងទឹកនៅក្នុង/ក្បែរតំបន់គម្រោងដែរឬទេ ហើយអណ្តូងមួយណាដែលត្រូវបានប្រើប្រាស់ច្រើនជាងគេក្នុងជីវភាពប្រចាំថ្ងៃ។ បន្ទាប់ពីកំណត់ទីតាំងយកសំណាកទឹក ឧបករណ៍ GPS ត្រូវបានប្រើប្រាស់សម្រាប់សម្គាល់ទីតាំងយកសំណាកទឹក។ ការយកសំណាកទឹក ត្រូវបានអនុវត្តតាមវិធីសាស្ត្ររបស់មន្ទីរពិសោធន៍ នៃក្រសួងបរិស្ថានដូចខាងក្រោម៖

- ដបសំណាកទឹក គឺប្រើប្រាស់ដបទឹកបរិសុទ្ធដែលមិនទាន់បានប្រើប្រាស់ប្រភេទ ចំណុះ១,៥ល ចំនួន១ដប និង ០,៥ល ចំនួន១ដប សម្រាប់យកសំណាកទឹកក្នុងមួយទីតាំង (ដបចំណុះ០,៥ល សម្រាប់យកសំណាកទឹកដោយមិនឲ្យមានអុកស៊ីសែននៅក្នុងដប)
- សប់អណ្តូងស្នប់ឲ្យចេញទឹកឲ្យបានគ្រប់គ្រាន់ ដោយធានាថា ទឹកសំណាកនោះ គឺអាចតំណាងឲ្យគុណភាពទឹកក្រោមដីដែលបានយក
- មុនពេលយកសំណាកទឹក ត្រូវលាងដបជាក់សំណាកជាមួយនឹងទឹកសំណាកយ៉ាងតិច០៣ដង
- ត្រងយកទឹកដែលចេញពីក្បាលអណ្តូងស្នប់ដែលចេញក្នុងកំឡុងពេលសប់
- សម្គាល់ឈ្មោះទីតាំង និងពេលវេលានៅលើដបសំណាកឲ្យបានត្រឹមត្រូវ
- អង្កេតពិនិត្យតំបន់យកសំណាកទឹកដូចជាឆ្នាំកសាង មុខកាត់ ជម្រៅ ស្ថានភាពជុំវិញប្រភពទឹក ស្ថានភាពទឹក(ពណ៌ និងក្លិន) សីតុណភាព និងការប្រើប្រាស់របស់វា តាមរយៈការសម្ភាសន៍អ្នកជួនយកសំណាកទឹក/ម្ចាស់អណ្តូង

- យកសំណាកទឹកដែលបានយករួចដាក់នៅក្នុងធុងទឹកកកដែលមានសីតុណ្ហភាពថេរ ៤°C រួចដឹកជញ្ជូនទៅមន្ទីរពិសោធន៍មិនឲ្យលើស៤២ម៉ោង។

តារាង២-៦៖ ប៉ារ៉ាម៉ែត្រវិភាគទឹកក្រោមដី

ល.រ	ប៉ារ៉ាម៉ែត្រ	ខ្នាត	ស្តង់ដា	វិធីសាស្ត្រវិភាគ
		Unit	CNDWQS	
1	pH	mg/L	6.5-8.5	Method MAJI meter
2	Turbidity	mg/L	<5.0	Method 2540 D
3	Dissolved Oxygen (DO)	mg/L	NV	Method 4500-Cl F
4	Total Hardness (as CACO3)	mg/L	<300	Method 5210 B
5	Chloride (Cl-)	mg/L	<250	Method JIS K 0102
6	Arsenic (As)	mg/L	<0.05	Method JIS K 0102 45
7	Iron (Fe-total)	mg/L	<0.3	Method JIS K 0102 46
8	Total Nitrogen (TN)	mg/L	NV	Method Digital Arsenator
9	Total Phosphorus (TP)	mg/L	NV	Method 3060 A
10	Total Coliform	mg/L	100	Method Photometer S7000

សម្គាល់៖


1-ការយកសំណាក ការក្សាទុក និងការដឹកជញ្ជូនសំណាកទឹកមកមន្ទីរពីសោធន៍ ក្រុមហ៊ុន (គម្រោង) អនុវត្តដោយខ្លួនឯង

2- CNDWQS ស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា

3- LDL mean Lowest Detection Limit, ND Mean Not Detected (Lower than LDL). NV Mean No Value

Draft

ផែនទី២.៣៖ ទីតាំងយកសំណាកទឹកលើដី និងទឹកក្រោមដី



២.៣.៣. ធនធានជីវសាស្ត្រ

គោលបំណងចម្បងនៃការសិក្សាក្នុងផ្នែកនេះ គឺដើម្បីបង្ហាញអំពីស្ថានភាពប្រព័ន្ធអេកូឡូស៊ី (ទីជម្រកធម្មជាតិ) ក្នុងតំបន់ និងធនធានជីវៈចម្រុះ ដែលមានដោយកម្រ ជិតផុតពូជ និងរងការគំរាមកំហែង ដែលការពារដោយច្បាប់ជាតិ បញ្ជីក្រហមរបស់អង្គការ IUCN (IUCN Red List) និងចំណាត់ថ្នាក់នៃអនុញ្ញាអន្តរជាតិ CITES។ ការសិក្សាវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់ទិន្នន័យដែលមានស្រាប់ គួបផ្សំនឹងការសិក្សានៅទីវាលជាក់ស្តែងលើបម្រែបម្រួលធនធានគម្របព្រៃឈើ ការធ្វើសារពើភ័ណ្ឌព្រៃឈើ ការដើរអង្កេតប្រភេទសត្វព្រៃ មច្ឆជាតិ និងធនធានជលផល ព្រមទាំងការសម្ភាសន៍ និងពិភាក្សាជាមួយប្រជាជនមូលដ្ឋាន (អ្នកមានចំណេះដឹងសមរម្យ និងចាស់ទុំនៅក្នុងភូមិក្បែរទីតាំងគម្រោង) និងតំណាងស្ថាប័នមានសមត្ថកិច្ច។ ក្នុងការសិក្សានេះ ក្រុមការងារបានជួបសម្ភាសន៍ និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធសរុបចំនួន ៦០នាក់ (ស្រី ៦នាក់) ដូចមានសង្ខេបក្នុង**ឧបសម្ព័ន្ធ៧.១**។ ព្រមទាំងកម្រងសំណួរសម្រាប់ការពិភាក្សាមានបង្ហាញក្នុង**ឧបសម្ព័ន្ធ៧.១**។

ការសិក្សាអំពីស្ថានភាពបច្ចុប្បន្ននៃធនធានសត្វព្រៃ មច្ឆជាតិ និងជលផលអាចចាត់ទុកជាការវាយតម្លៃផលប៉ះពាល់ជាបណ្តុំ ព្រោះសត្វព្រៃ មច្ឆជាតិ និងធនធានជលផល (ខុសពីរុក្ខជាតិ និងព្រៃឈើ) អាចធ្វើការ បម្លាស់ទីបានឆ្ងាយ (អាចឆ្ងាយជាងទីតាំងដែលបានសិក្សាទៀតផង)។ ម្យ៉ាងវិញទៀត ស្ថានភាពបច្ចុប្បន្ននៃធនធានសត្វព្រៃ មច្ឆជាតិ និងជលផលក្នុងតំបន់ ត្រូវបានកំណត់ដោយបណ្តុំនៃកត្តា/ហេតុប៉ះពាល់ជាច្រើន ជាពិសេសការបាត់បង់ព្រៃឈើ (រួមទាំងព្រៃតាមមាត់អូរ) គម្រោងវិនិយោគនានា និងសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់ (រួមទាំងការទន្ទ្រានយកដីធ្វើកម្មសិទ្ធិ ការបរបាញ់ ការនេសាទរបស់ប្រជាជន)។

២.៣.៣.១. តំបន់ការពារធម្មជាតិ និងអតិរក្សជីវៈចម្រុះ

ប្រព័ន្ធអេកូឡូស៊ីក្នុង និងជុំវិញតំបន់សិក្សា (ធនធានបរិស្ថានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងអន្តរអំពើរវាងធនធានទាំងនេះ) អាចបែងចែកជាពីរសំខាន់ៗគឺ៖ ប្រព័ន្ធអេកូឡូស៊ីលើគោក និងប្រព័ន្ធអេកូឡូស៊ីក្នុងទឹក។ ប្រព័ន្ធអេកូឡូស៊ីទាំងនេះជាប្រភពនៃធនធានជីវៈចម្រុះ ដែលមានសារប្រយោជន៍ផ្នែកបរិស្ថាន និងសម្រាប់ការរស់នៅរបស់មនុស្ស។ តំបន់ជាច្រើនត្រូវបានរាជរដ្ឋាភិបាលដាក់បញ្ចូលជាតំបន់ការពារធម្មជាតិ និងអភិរក្សជីវៈចម្រុះ។ នៅក្នុងការសិក្សានេះ យើងបានធ្វើការវិភាគទិន្នន័យដែលមានស្រាប់ តាមប្រព័ន្ធ ArcView GIS ដើម្បីលើកយកបង្ហាញពីតំបន់ការពារធម្មជាតិ និងអភិរក្សជីវៈចម្រុះទាំងនោះ ព្រមទាំងធ្វើការពិភាក្សាអំពីទំនាក់ទំនងនៃតំបន់ទាំងនោះ ទៅនឹងទីតាំងគម្រោងអភិវឌ្ឍន៍នេះ។

២.៣.៣.២. ធនធានព្រៃឈើ

ក. គម្របព្រៃឈើ

ការសិក្សាអំពីបម្រែបម្រួលគម្របព្រៃឈើ ត្រូវបានធ្វើឡើងតាមរយៈការវិភាគភាពត្រួតស៊ីគ្នា នៃផែនទីគម្របព្រៃឈើឆ្នាំ២០០២ ២០០៦ និងឆ្នាំ២០១០ (GIS Database) របស់រដ្ឋបាលព្រៃឈើលើទីតាំងគម្រោង។ ក្រុមការងារសិក្សាក៏បានធ្វើបច្ចុប្បន្នភាពនៃធនធានគម្របព្រៃឈើដែលមានក្នុងទីតាំងគម្រោង តាមរយៈការចុះអង្កេតជាក់ស្តែងនៅក្នុងទីតាំងគម្រោងផ្ទាល់ (ខែធ្នូ ឆ្នាំ២០១៦) និងការពិភាក្សាជាមួយអ្នកពាក់ព័ន្ធនានាដូចបង្ហាញសង្ខេបក្នុងតារាង២.២ ខាងលើ។

Draft

ខ. ធនធានឈើឈរ

ការសិក្សាអំពីធនធានឈើឈរដែលមាននៅក្នុងទីតាំងគម្រោង ត្រូវបានធ្វើឡើងតាមរយៈការចុះធ្វើសារពើភ័ណ្ឌព្រៃឈើនៅក្នុងទីតាំងគម្រោងផ្ទាល់ ដោយក្រុមការងាររបស់រដ្ឋបាលព្រៃឈើ។ សារពើភ័ណ្ឌព្រៃឈើនេះ ត្រូវបានធ្វើឡើង ក្នុងខែមីនា ឆ្នាំ២០១៦ ដើម្បីប៉ាន់ស្មានចំនួនដើម ប្រភេទឈើ និងមាឌឈើ ដែលមាននៅក្នុងព្រៃស្រោង (៥៤៩,១១ ហិកតា) ព្រៃពាក់កណ្តាលស្រោង (៣៩៣,១៦ ហិកតា) និងព្រៃល្បោះ (៥២១៦,៣២) ដែលជាកម្មវត្ថុនៃការធ្វើអាជីវកម្មទាំងស្រុង មុនអនុញ្ញាតឱ្យក្រុមហ៊ុនឈូសឆាយ និងដាំដុះ។ ទំហំផ្ទៃដីព្រៃឈើទាំងបីប្រភេទដែលមាននៅក្នុងទីតាំងគម្រោងនេះ គឺជាលទ្ធផលនៃចុះកំណត់ព្រំប្រទល់ប្រភេទព្រៃនីមួយៗក្នុងពេលប្រតិបត្តិការការងារសារពើភ័ណ្ឌ។ សារពើភ័ណ្ឌព្រៃឈើ ត្រូវបានធ្វើឡើងតាមគោលការណ៍ណែនាំរបស់រដ្ឋបាលព្រៃឈើ (ឆ្នាំ២០១១) ដូចខាងក្រោម៖

ខ១. ការគណនាចំនួនឡូតិ៍គំរូត្រូវដាក់តាំង

ចំនួនឡូតិ៍គំរូត្រូវដាក់តាំងក្នុងតំបន់សារពើភ័ណ្ឌ ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$N = \frac{S \times SI}{s}$$

ដែល - S ផ្ទៃដីសរុបក្នុងស្រទាប់ព្រៃនីមួយៗ គិតជាហិកតា

- SI កម្រិតជម្រើសតាមអង្កត់ផ្ចិតនីមួយៗ

- s ទំហំឡូតិ៍-អនុឡូតិ៍នីមួយៗ គិតជាហិកតា

ខ២. ការគណនាគម្លាតរវាងខ្សែវាស់រាប់

គំលាតរវាងខ្សែវាស់រាប់ ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

D= ៣0/0,២ = ១៥0 ម៉ែត្រ

ដែល - D: ចំងាយរវាងខ្សែវាស់រាប់ គិតជាម៉ែត្រ

- SI: កំរិតជម្រើស ដែលកំណត់យក ២0%

- ៣0ម: ជាទទឹងឡូតិ៍គំរូ

ខ៣. ការគណនាគម្លាតរវាងអនុឡូតិ៍

គំលាតរវាងអនុឡូតិ៍គំរូ (អនុឡូតិ៍ដែលមានទំហំ ៣0 ម៉ែត្រ x ២៥ម៉ែត្រ និង ៣0 ម៉ែត្រ x ៥0ម៉ែត្រ) ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$IG = \sqrt{S/N}$$

ដែល - IG: ចន្លោះរវាងក្រឡាក្រត្រង្គ (គិតជាម៉ែត្រ)

- S : ផ្ទៃដីសរុបតាមស្រទាប់ព្រៃនីមួយ (គិតជាម៉ែត្រការ)

- N : ចំនួនអនុឡូតិ៍គំរូ


ជាលទ្ធផល ឡូតិ៍-អនុឡូតិ៍គំរូសរុបចំនួន ៦៧៩ (តារាង២.៧) ត្រូវបានដាក់តាំង ដើម្បីធ្វើការសិក្សាវាយតម្លៃធនធានព្រៃឈើ។

Draft

តារាង២.៧៖ ចំនួនឡូត៍-អនុឡូត៍ដែលបានដាក់តាំងតាមប្រភេទព្រៃនីមួយៗ

អង្គត់ផ្ចឹត	ទំហំឡូត៍-អនុឡូត៍	ព្រៃស្រោង	ព្រៃពាក់កណ្តាលស្រោង	ព្រៃល្បោះ	ឡូត៍-អនុឡូត៍សិក្សាសរុប
5-14 ស.ម	30ម x 25ម	28	34	252	**314**
15-30 ស.ម	30ម x 50ម	9	9	33	**51**
>30 ស.ម	30ម x 250ម	28	34	252	**314**
សរុបឡូត៍-អនុឡូត៍គំរូ		**65**	**77**	**537**	**679**

រូបភាព២.២៖ ប្លង់ឡូត៍-អនុឡូត៍គំរូសម្រាប់សិក្សាសារព័ន្ធរុក្ខជាតិ




ខ៤. ការកំណត់ទីតាំងឡូត៍គំរូ៖ ទីតាំងឡូត៍គំរូ ត្រូវបានកំណត់ដូចខាងក្រោម៖

- ស្វែងរកទីតាំងឡូត៍នៅលើទីវាល ទៅតាមចំណុចគោលដែលបានកំណត់នៅលើផែនទីទុកជាមុន
- ប្រើប្រាស់ខ្សែម៉ែត្រ សម្រាប់វាស់ទំហំ និងកំណត់ព្រំប្រទល់ឡូត៍-អនុឡូត៍គំរូ
- លាបថ្នាំពណ៌តាមបណ្តោយព្រំប្រទល់ ដែលបានកំណត់ កាប់ឆ្ការ ឬមានប្រលោះដោយធម្មជាតិ។

ផែនទី២.៤ បង្ហាញអំពីទីតាំង និងរបាយឡូត៍-អនុឡូត៍ ដែលបានធ្វើសារពើភ័ណ្ឌព្រៃឈើនៅក្នុងទីតាំងគម្រោង។ សារពើភ័ណ្ឌព្រៃឈើនេះ មិនបានធ្វើឡើងនៅផ្នែកខាងជើងនៃទីតាំងគម្រោងនោះទេ ដោយសារក្នុងផ្នែកនោះមិនមានព្រៃឈើ។

ផែនទី២.៤៖ ទីតាំង និងរបាយឡូត៍-អនុឡូត៍ ក្នុងការពើសារពើភ័ណ្ឌព្រៃឈើក្នុងទីតាំងគម្រោង



ចំនួនឡូត៍ក្នុងការធ្វើសារពើភ័ណ្ឌព្រៃឈើ				សរុប
ប្រភេទព្រៃ	ព្រៃស្រោង	ព្រៃពាក់កណ្តាលស្រោង	ព្រៃល្បោះ	
ចំនួនឡូត៍	២៨	៣៤	២៥២	៣១៤

ខ៥. វិធីសាស្ត្រក្នុងការវាស់រាប់

ប៉ារ៉ាម៉ែត្រក្នុងការវាស់រាប់ រួមមាន៖ អង្កត់ផ្ចឹត(D ១.៣០ ម៉ែត្រ), កម្ពស់ (H មែកទី១) ចំនួនដើមឈើ និងប្រភេទឈើទៅតាមគុណភាព។ គោលការណ៍វាស់រាប់ មានដូចតទៅ៖

- **ប្រភេទឈើ៖** ធ្វើការកត់ត្រាគ្រប់ប្រភេទឈើទាំងអស់ ដែលមានដំណុះនៅក្នុងឡូត៍-អនុឡូត៍ដែលបានតំណត់ ដោយធ្វើការបែងចែកទៅតាមចំណាត់ថ្នាក់ប្រភេទឈើ យោងតាមប្រកាសលេខ ០៨៩ ប្រក.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីប្រភេទឈើដាប់ក្នុងលំដាប់ថ្នាក់
- **អង្កត់ផ្ចឹត៖** ធ្វើការវាស់ និងរាប់ គ្រាប់ប្រភេទឈើទាំងអស់ដែលមានទំហំអង្កត់ផ្ចឹតចាប់ពី ៥សង់ទីម៉ែត្រឡើងទៅ ដោយធ្វើការវាស់អង្កត់ផ្ចឹតរបស់ដើមឈើត្រឹមកម្ពស់ ១,៣០ម៉ែត្រ ឬពីលើព្រឹង ០,៦៥ ម៉ែត្របន្ថែមទៀត ក្នុងករណីដើមឈើនោះមានព្រឹងខ្ពស់ជាង ១,៣០ម៉ែត្រ។
- **កម្ពស់៖** ប៉ាន់ស្មាន់កម្ពស់ដើមឈើទាំងអស់ យកត្រឹមមែកទីមួយ ចុះមកក្រោមត្រឹម ១,៣០ម៉ែត្រ គ្រប់ប្រភេទឈើទាំងអស់ ដែលមានអង្កត់ផ្ចឹងចាប់ពី ៥ សង់ទីម៉ែត្រឡើងទៅ។

ខ៦. ការកំណត់គុណភាពឈើឈរ

ការវាយតម្លៃគុណភាពឈើសម្រាប់ដើមឈើនីមួយៗ ត្រូវបានផ្តល់ជាចំណាត់ថ្នាក់ដូចខាងក្រោម៖


- **គុណភាពA ៖** ដើមឈើដែលអាចផ្តល់ឈើហ៊ុបដោយគ្មានការខូចខាត
- **គុណភាពB ៖** ដើមឈើដែលអាចផ្តល់ឈើហ៊ុបមានការខូចខាតតិចតួចអាចយកទៅប្រើប្រាស់បាន
- **គុណភាពC ៖** ដើមឈើមិនអាចផ្តល់ឈើហ៊ុប ដែលប្រើប្រាស់បាននៅក្នុងរោងចក្រអារឈើ ឬឧស្សាហកម្មក្តាបន្ទះ ពីព្រោះមានការខូចខាតច្រើន ឬដើមឈើមិនអាចយកទៅធ្វើអ្វីបាន (អុស)។

ខ៧. ឧបករណ៍ប្រើប្រាស់សម្រាប់វាស់វែងឈើ


- វាស់ទំហំអង្កត់ផ្ចិត៖ ខ្សែម៉ែត្រវាស់អង្កត់ផ្ចឹត (Diameter tap)
- វាស់កម្ពស់៖ Sunnto Clinometer សម្រាប់វាស់កម្ពស់ដើមឈើ
- ក្រដាស់កត់ត្រាទិន្នន័យដែលបានរៀបចំរួចដែលមានកំណត់នូវ ប៉ារ៉ាម៉ែត្រឈើ ទៅតាមទំហំឡូត៍-អនុឡូត៍ ដូចជា៖ ប្រភេទឈើ ចំនួនដើមឈើ កម្ពស់ និងអង្កត់ផ្ចឹតឈើ ។

ខ៨. វិធីសាស្ត្រវាស់អង្កត់ផ្ចិតដើមឈើ

គោលការណ៍សម្រាប់ឈើពាណិជ្ជកម្មដែលមានអង្កត់ផ្ចឹតធំជាង ៥ស.ម ចំណុចវាស់អង្កត់ផ្ចឹតគឺនៅកម្ពស់ ១,៣ម៉ែត្រពីនីវ៉ូដី ប៉ុន្តែវាអាស្រ័យទៅតាមស្ថានភាពដី និងលក្ខណៈដើមឈើដែលដុះ។ ដូច្នេះ របៀបវាស់អង្កត់ផ្ចឹតគឺដូចរូបខាងក្រោម៖



ករណីចំណុចវាស់អង្កត់ផ្ចឹតនៅកម្ពស់ ១,៣ម៉ែត្រពីនីវូដីនៅពីលើចំពាមនោះ ចំណុចវាស់អង្កត់ផ្ចឹតត្រូវធ្វើការវាស់វែងចំនួន ០២លើក និងគិតជាឈើចំនួន ០២ដើម។ ករណីដើមឈើមានព្រឹង ចំណុចវាស់អង្កត់ផ្ចឹត ត្រូវកែលទៅផ្នែកខាងលើព្រឹង ៦៥សង់ទីម៉ែត្រ។



ខ៩.ការចាត់តាំងការងារអនុវត្តន៍ជាក់ស្តែងលើទីវាល

ខ៩.១ សមាសភាពក្រុមរៀបចំព្រំប្រទល់ និងបើបប្រឡោះព្រៃ

មានសមជិកចំនួន ៥នាក់ក្នុងនោះ៖

- ១ នាក់ (អ្នកបច្ចេកទេស) ប្រធានក្រុមជាអ្នកប្រើប្រាស់ឧបករណ៍ GPS និងកាន់ត្រីវិស័យតំរង់ទិស
- ២ នាក់ (កម្មករ/សមាជិក/អ្នកភូមិ) ជាអ្នកត្រាយបើកប្រឡោះព្រៃ
- ២ នាក់ (កម្មករ/សមាជិក/អ្នកភូមិកម្មករ) ជាអ្នកទាញខ្សែម៉ែត្រវាស់ចំងាយបោះបង្គោល វាយផ្លាក និងលាបថ្នាំពណ៌

ខ៩.២ សមាសភាពក្រុមវាស់រាប់ មានសមាជិកចំនួន ៧នាក់ក្នុងនោះ

- ១ នាក់ (អ្នកបច្ចេកទេស) ប្រធានក្រុមដឹកនាំក្រុម និងកត់ត្រាលទ្ធផលវាស់រាប់
- ២ នាក់ (អ្នកបច្ចេកទេស) វាស់អង្កត់ផ្ចឹត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និងហៅឈ្មោះឈើ
- ២ នាក់ (កម្មករ/សមាជិក/អ្នកភូមិកម្មករ) ត្រាយព្រៃ លាបថ្នាំសំគាល់ ធ្វើព្រំប្រទល់ឡូត៍ និងអនុឡូត៍
- ២ នាក់ (កម្មករ/សមាជិក/អ្នកភូមិកម្មករ) ជំនួយការវាស់អង្កត់ផ្ចឹត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និងហៅឈ្មោះឈើ (ជាអ្នកស្គាល់ឈ្មោះឈើច្បាស់លាស់)

ខ១០.ការវិភាគទិន្នន័យធនធានឈើ

ទិន្នន័យក្នុងសាលាកប័ត្រសម្រង់ពត៌មានដើមឈើ ត្រូវបានបញ្ចូលក្នុងកម្មវិធី Excel សំរាប់ធ្វើការប្រព្រឹត្តិទិន្នន័យ។ ការវិភាគទិន្នន័យប្រើប្រាស់សមីការមាឌឈើខាងក្រោមសំរាប់ធ្វើការគណនាមាឌឈើឈរ។

ខ១១.វិធានការកំណត់មាឌឈើ

ការកំណត់មាឌឈើឈរដោយប្រើសមីការមាឌតាមលំដាប់ថ្នាក់អង្កត់ផ្ចឹតតាមប្រភេទព្រៃដូចខាងក្រោម:

ប្រភេទឈើ	អង្កត់ផ្ចឹត (DBH)	ប្រភេទព្រៃ		
		ព្រៃស្រោង	ព្រៃពាក់កណ្តាលស្រោង	ព្រៃល្មោះ និងព្រៃផ្សេងៗ
Dipterocarp	<15cm	$V= 0.022+3.4*D^2$	$V= 0.03+4.8*D^2$	$V= 0.00849+4.097*D^2$
	>15cm	$V= 0.015+2.137*D^2 +0.513*D^2*L$	$V= -0.036+3.157*D^2 +0.334*D^2*L$	$V= -0.031+4.637*D^2 +0.135*D^2*L$
Non-dipterocarp	<15cm	$V= 0.03+2.8*D^2$	$V= 0.0083+4.3*D^2$	$V= 0.03+3.3*D^2$
	15-30cm	$V= 0.03+2.8*D^2$	$V= 0.0083+5.3*D^2$	$V= 0.03+3.55*D^2$
	> 30cm	$V= -0.0023+2.942*D^2 +0.262*D^2*L$	$V= 0.0295+5.256*D^2 +0.09047*D^2*L$	$V= -0.242+4.782*D^2 +0.269*D^2*L$

ប្រភព៖ រដ្ឋបាលព្រៃឈើ, ២០១០

ខ១២.ការប៉ាន់ស្មានជីវម៉ាស់នៅលើដី និងកាបូនស្តុក

ខ១២.១ ការប៉ាន់ស្មានជីវម៉ាស់

ការប៉ាន់ស្មានជីវម៉ាស់នៅលើដី(Above Ground Biomass) គឺអនុវត្តន៍តាមរូបមន្តរបស់លោក Brown ឆ្នាំ ១៩៩៧ ដែលបានបង្ហាញដូចខាងក្រោម៖

AGB = VOB x WD x BEF

ដែល - AGB ជាជីវម៉ាស់លើដី (Above Ground Biomass)

VOB មាឌឈើគិតទាំងសំបក

WD ដង់ស៊ីតេឈើ WD = 0,៥៧ (UNFCCC)

BEF មេគុណពង្រីក

- ចំពោះមេគុណពង្រីក មានរបៀបគណនាដូចខាងក្រោម៖

BEF =Exp { 3,213 – 0,506 x Ln(BV)} for BV < 190 t/ha

= 1,74 for BV >= 190 t/ha

(ដែលBV ជាជីវម៉ាស់របស់មាឌឈើ បានមកពីការធ្វើសារពើភ័ណ្ឌព្រៃឈើគិតជា t/ha) តាមឯកសារលោក Sakasi nophear បានបង្ហាញថា ជីវម៉ាស់ក្រោមដី (Bellow Ground Biomass) ស្មើនឹង ៣០%នៃជីវម៉ាស់ លើដី។

គ១២.២ ការប៉ាន់ស្មានកាបូនស្តុក

- ការគណនាបរិមាណកាបូនស្តុកនៅលើដើមឈើ ឬកំណើនកាបូននៅក្នុងព្រៃឈើគេប្រើប្រាស់រូបមន្ត៖

$C_{(above\ ground)} = AGB \times r_c$

- បរិមាណការបូនស្តុកក្នុងដើមឈើ(ផ្នែកខាងលើដី និងផ្នែកឫស)

$C_{(above\ ground)} = VOB \times WD \times BFF \times (1+0.30)$


- បរិមាណនៃ Co2 គណនាដោយរូបមន្ត (kakada.,2006)

$Co_2 = 44/12 \times AGB \times AGB \times r_c$

គ. ធនធានសត្វព្រៃ

ធនធានសត្វព្រៃក្នុងតំបន់គម្រោង (ប្រវត្តិ ស្ថានភាព ច្រករបៀង ទីជម្រក និងប្រភពចំណី) ត្រូវបានការសិក្សាតាមរយៈការសាកសួរព័ត៌មាននិងពិភាក្សាជាមួយតំណាងស្ថាប័នមានសមត្ថកិច្ច(រដ្ឋបាលព្រៃឈើ)និងប្រជាជនមូលដ្ឋានដែលមានចំណេះដឹងសមរម្យ ឬចាស់ទុំនៅក្នុងភូមិ (តារាង២.២)។ ការពិភាក្សាត្រូវបានធ្វើឡើងជាលក្ខណៈសម្ភាសន៍ជនបង្គោល (Key Informants) និងជាលក្ខណៈពិភាក្សាជាមួយក្រុមគោលដៅ (Focus Group Discussion)។ លើសពីនេះ យើងក៏បានចុះអង្កេតផ្ទាល់ដើម្បីពិនិត្យពីស្ថានភាពវត្តមានសត្វព្រៃដាក់ស្តែង តាមរយៈការមើលឃើញសត្វដោយផ្ទាល់ ឃើញដានដើង លាមក សម្រែក សំណាកសត្វ និងស្លាកស្នាមសម្គាល់ ផ្សេងៗ នៅក្នុង និងក្បែរទីតាំងគម្រោង កន្លែងដីច្រាប កន្លែងសត្វឆ្លងកាត់ កន្លែងប្រភពទឹករបស់សត្វ ដោយប្រើប្រាស់វិធីសាស្ត្រដើរដាច់ខ្សែត្រង់ស៊ិក (Transect Walk) កាត់ទទឹងដីគម្រោងចំនួន ១៣ត្រង់ស៊ិក ក្នុងចម្ងាយ ប្រមាណ ៤-៥ គ.ម ក្នុងមួយខ្សែ (ផែនទី២.៥)។ Camera trap ក៏ត្រូវបានប្រើប្រាស់សម្រាប់ថតយករូបភាពសត្វព្រៃដោយស្វ័យប្រវត្តិ។ ក្នុងការសិក្សានេះCamera trap ត្រូវដាក់នៅលើទីតាំងចំនួន០២កន្លែង ដែលមួយកន្លែងៗមានរយៈពេល ៥ថ្ងៃ (ទីតាំង១៖ ៦៩២០២៣/១៥៣៣៨៩០ និងទីតាំង២៖ ៦៨០៥៥៥/១៥២៤០០២) ដែលជាកន្លែងធ្លាប់មានវត្តមានសត្វឆ្លងកាត់ទៅមក(ផែនទី២.៥)។

ផែនទី២.៥៖ ទីតាំងសិក្សាធនធានសត្វព្រៃ និងមច្ឆជាតិ



Transect line	length(Meter)
Transect line1	5257
Transect line2	5105
Transect line3	5189
Transect line4	5087
Transect line5	5137
Transect line6	5071
Transect line7	5110
Transect line8	4940
Transect line9	5134
Transect line10	5073
Transect line11	5062
Transect line12	5068
Transect line13	5078

Fishery	X	Y
1	695177	1540088
2	694571	1536229
3	688671	1531190
4	692000	1529193
5	679249	1523242
Cameratrap	X	Y
1	692023	1533890
2	680555	1524002

ឃ. ធនធានមច្ឆជាតិ

ការប្រមូលព័ត៌មានស្តីអំពីធនធានមច្ឆជាតិ ត្រូវបានធ្វើឡើងតាមរយៈការជួបពិភាក្សាជាមួយតំណាងស្ថាប័នមានសមត្ថកិច្ច (រដ្ឋបាលជលផល) និងប្រជាជនមូលដ្ឋានដែលជាអ្នកនេសាទ (តារាង២.២) ដើម្បីកត់ត្រាអំពីប្រភេទមច្ឆជាតិ ស្ថានភាព និងផលនេសាទ ព្រមទាំងស្វែងយល់អំពីមូលហេតុដែលធ្វើឱ្យមានបម្រែបម្រួលធនធានមច្ឆជាតិនៅក្នុងតំបន់។ ឯកសារជំនួយស្មារតីស្តីអំពីប្រភេទមច្ឆជាតិ ត្រូវបានប្រើប្រាស់ក្នុងកិច្ចពិភាក្សា ដើម្បីកំណត់អត្តសញ្ញាណប្រភេទមច្ឆជាតិ។

ក្នុងដំណើរការសិក្សាអំពីធនធានមច្ឆជាតិ យើងក៏បានចុះធ្វើការសម្ភាសន៍ និងពិនិត្យមើលអំពីសកម្មភាពនេសាទរបស់ប្រជាពលរដ្ឋដោយផ្ទាល់នៅតាមដងទន្លេសេសាន និងអូរមួយចំនួនដែលមាននៅក្នុង និងក្បែរទីតាំងគម្រោង។ លើសពីនេះ យើងក៏បានចុះធ្វើការនេសាទដោយផ្ទាល់ជាមួយអ្នកនេសាទ ដោយប្រើប្រាស់ឧបករណ៍ដូចជា៖ សំណាញ់ មង សន្ទូច និងអ្ជូន នៅក្នុង និងក្បែរទីតាំងគម្រោងចំនួន ០៥កន្លែង ដែលស្ថិតនៅតាមដងទន្លេសេសាន និងអូរដែលមានដក់ទឹក ដូចមានបង្ហាញជូនក្នុងផែនទី២.៥ ខាងលើ។

ង. ឧបករណ៍ និងសម្ភារៈ ក្នុងការប្រើប្រាស់សម្រាប់ការសិក្សា

ជារួមនៅក្នុងដំណើរការនៃការសិក្សាទៅលើធនធានជីវសាស្ត្រនេះ យើងបានការប្រើប្រាស់ ឧបករណ៍ និងសម្ភារមួយចំនួនដូចជា៖

- ខ្សែម៉ែត្រវាស់អង្កត់ផ្ចឹត (Diameter tap)
- Sunnto Clinometer សម្រាប់វាស់កម្ពស់ដើមឈើ
- ក្រដាស់កត់ត្រាទិន្នន័យទាក់ទងនឹងប៉ាវ៉ាម៉ែត្រឈើ៖ ប្រភេទឈើ ចំនួនដើមឈើ កម្ពស់ និងអង្កត់ផ្ចឹតឈើ
- សៀវភៅមគ្គុទេសសម្រាប់អង្កេតសត្វ និងញែកអត្តសញ្ញាណប្រភេទសត្វនីមួយៗឱ្យបានច្បាស់ដៀសវាងការភាន់ច្រឡំ ឧ. សៀវភៅថនិកប្រទេសកម្ពុជា សៀវភៅប្រភេទត្រីទឹកសាបសំខាន់ៗនៅព្រះរាជាណាចក្រកម្ពុជា និងសៀវភៅសត្វស្លាបនៃប្រទេសកម្ពុជា។ល។
- ម៉ាស៊ីនថតរូប Digital សម្រាប់ថតយករូបភាពសត្វ និងសកម្មភាពសិក្សាស្រាវជ្រាវ
- Camera trap សម្រាប់ថតយករូបភាពសត្វព្រៃដោយស្វ័យប្រវត្តិ
- ឧបករណ៍នេសាទ ដូចជា សំណាញ់ មង សន្ទូច និងអ្ជូន
- ឧបករណ៍ប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ (GPS) សម្រាប់កំណត់ទីតាំងនៃវត្តមានសត្វ
- Worksheet (ជាក្រដាសតារាង) សម្រាប់កត់ត្រា និងបង្រួមទិន្នន័យនៅទីវាល
- ផែនទីសម្រាប់បង្ហាញពីទីតាំងភូមិសាស្ត្រនៃតំបន់សិក្សា ព័ត៌មានភូមិសាស្ត្រ ប្រភេទព្រៃ តំបន់ដីសើម ដែលទាក់ទងទៅនឹងទីជម្រកសត្វព្រៃ និងមច្ឆជាតិនៅក្នុងតំបន់
- កែវពង្រីកសម្រាប់អង្កេតសត្វ ជាពិសេសក្នុងចម្ងាយឆ្ងាយដែលយើងពុំអាចញែកអត្តសញ្ញាណសត្វបានដោយភ្នែកទទេ។
- ក្បួងសំនួរសម្រាប់ពិភាក្សាជាមួយ រដ្ឋបាលព្រៃឈើ និងជលផល។

២.៣.៤. ការសិក្សាធនធានសេដ្ឋកិច្ច-សង្គម

ការសិក្សាពីធនធានសេដ្ឋកិច្ច-សង្គម ផ្តោតសំខាន់ទៅលើប៉ារ៉ាម៉ែត្រ ដូចមានចែងក្នុងគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រសួងបរិស្ថាន (ឆ្នាំ២០០៩)។ ការសិក្សានេះបានផ្តោតសំខាន់លើ៖ លក្ខណៈប្រជាសាស្ត្រ ស្ថានភាពផ្ទះសម្បែង ការប្រើប្រាស់ដី ស្ថានភាពសេដ្ឋកិច្ច និងសុខុមាលភាពសង្គម (មុខរបរចំណូល-ចំណាយ) ការអប់រំ ការប្រើប្រាស់ថាមពល ការប្រើប្រាស់ទឹក សុខភាព និងអនាម័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្បត្តិវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា និងទេសចរណ៍។ ទិន្នន័យដែលមានស្រាប់ (ឧ. ព័ត៌មានស្តីពីស្ថានភាពឃុំ របាយការណ៍របស់មន្ទីរជំនាញពាក់ព័ន្ធដូចជា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាល ជាដើម) ត្រូវបានយកមកវិភាគ ដើម្បីកំណត់នូវប៉ារ៉ាម៉ែត្រមួយចំនួនដូចជា៖ លក្ខណៈប្រជាសាស្ត្រ ស្ថានភាពផ្ទះសម្បែង ការប្រើប្រាស់ដី ការអប់រំ ការប្រើប្រាស់ថាមពល ការប្រើប្រាស់ទឹក សុខភាព និងអនាម័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្បត្តិវប្បធម៌ ជំនឿ-សាសនា និងទេសចរណ៍។

លើសពីនេះទៀត ដើម្បីបំពេញភាពចន្លោះប្រហោងនៃទិន្នន័យដែលមានស្រាប់ យើងបានប្រមូលទិន្នន័យបឋមដូចខាងក្រោម៖

- ស្ថានភាពសេដ្ឋកិច្ច និងសុខុមាលភាពសង្គម (មុខរបរ ចំណូល-ចំណាយ)៖ បញ្ចូលសំណួរពាក់ព័ន្ធទៅក្នុងការអង្កេតតាមគ្រួសារ
- ស្ថានភាពនៃការប្រើប្រាស់ដី (ទំនាស់ដីធ្លី) និងការប្រើប្រាស់ធនធានធម្មជាតិ (អនុផលព្រៃឈើ ជលផល)៖ បញ្ចូលសំណួរពាក់ព័ន្ធទៅក្នុងកិច្ចប្រពិភាក្សាអំពីធនធានព្រៃឈើ និងមច្ឆជាតិ
- សម្បត្តិវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងជំនឿ-សាសនា៖ បញ្ចូលសំណួរពាក់ព័ន្ធទៅក្នុងការពិគ្រោះយោបល់ជាមួយអជ្ញាធរភូមិ-ឃុំ និងប្រជាជនមូលដ្ឋាន។


វិសាលភាពនៃការសិក្សាប្រែប្រួលទៅតាមចរិកលក្ខណៈនៃប៉ារ៉ាម៉ែត្រដែលត្រូវសិក្សា។ ជារួម ការកំណត់វិសាលភាព ត្រូវបានធ្វើជាដំហានៗដូចខាងក្រោម ៖

- **<u>ដំហានទី១៖</u>** វិសាលភាពនៃការសិក្សា ត្រូវបានកំណត់ក្នុងរង្វង់៥គីឡូម៉ែត្រជុំវិញតំបន់គម្រោង។ ក្នុងវិសាលភាពនេះ ភូមិ-ឃុំពាក់ព័ន្ធដែលត្រូវសិក្សា មានចំនួន ៣៦ភូមិ (ភូមិកាងណក ភូមិអ៊ីទូប ភូមិវ៊ឺនសៃ ភូមិថ្មី ភូមិកាចូនលើ ភូមិកាចូនក្រោម ភូមិវ៉ែង ភូមិវ៉ាយ ភូមិទៀមលើ ភូមិកាលែម ភូមិបានប៉ុង ភូមិបានវ៉ាង ភូមិប៉ាកកាឡាន ភូមិកំពង់ចាម ភូមិកុកឡាវ ភូមិកុកព្រៅ ភូមិកាឡែតាវ៉ាង ភូមិកាឡែសាពូន ភូមិទៀមក្រោម ភូមិហាតប៉ក់ ភូមិអ៊ីនប៉ាយ ភូមិឡាមប៉ា ភូមិតឺន ភូមិឡាអេង ភូមិតាហើយ ភូមិកាំបាក់ ភូមិ១,២,៣ ភូមិ១,២ ភូមិអូរភ្លេង ភូមិគហុកសិប ភូមិសាងគីម ភូមិរំពាត់ និង ភូមិតាឡាត) ដែលស្ថិតនៅក្នុងឃុំចំនួន ១០ (ឃុំវ៊ឺនសៃ ឃុំកាចូន ឃុំប៉ង់ ឃុំប៉ាកកាឡាន ឃុំកុំកុក ឃុំហាតប៉ក់ ឃុំតឺន ឃុំត្រពាំងក្រហម ឃុំត្រពាំងច្រេស ឃុំតាឡាត) ដូចបង្ហាញក្នុងផែនទី២.ស និងឧបសម្ព័ន្ធ។
- **<u>ដំហានទី២៖</u>** កិច្ចពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំទាំង១០ (តារាង២.៤) ដើម្បីកំណត់ពីភាពពាក់ព័ន្ធនឹងគម្រោងនៃភូមិ-ឃុំដែលបានជ្រើសរើសក្នុងដំហានទី១។ ឃុំតាឡាតថ្វីបើមិនស្ថិតនៅ

ក្នុងដែនកំណត់ ៥គ.ម ជុំវិញទីតាំងគម្រោងដូចកំណត់ក្នុងជំហានទី១ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចពិគ្រោះយោបល់ក្នុងជំហានទី២នេះដែរ ដោយសារឃុំតាឡាតកំពុងមានបញ្ហាដីធ្លីជាមួយគម្រោង ហើយស្ថិតនៅខ្សែទឹកខាងក្រោមនៃទន្លេសេសាន ដែលអាចនឹងទទួលរងផលប៉ះពាល់ពីគម្រោង ជាពិសេសពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក។ ជាលទ្ធផលភូមិចំនួន ១១ (ភូមិប៉ង់ ភូមិហ្វាំង ភូមិកាឡែសាពូន ភូមិកាឡែតាវ៉ាង ភូមិកុកឡាវ ភូមិកុកព្រៅ ភូមិទៀមក្រោម ភូមិហាតប៉ក់ ភូមិឡាំប៉ាក់ ភូមិតាឡាត និងភូមិរំពាត់) ដែលស្ថិតនៅក្នុងឃុំចំនួន ៤ (ឃុំប៉ង់ ឃុំភ្នំកុក ឃុំហាតប៉ក់ និងឃុំតាឡាត) ដូចបង្ហាញក្នុងតារាង២.៤ ត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ។

Draft

ផែនទី២.៦៖ ទីតាំងភូមិសាស្ត្រ និងផែនសិក្ខាសេដ្ឋកិច្ច-សង្គម



តារាង២.៧៖ អាជ្ញាធរមូលដ្ឋានដែលបានចូលរួមពិភាក្សាក្នុងការកំណត់ដែនសិក្សា

អាជ្ញាធរមូលដ្ឋាន	ចំនួនអ្នកចូលរួម	កាលបរិច្ឆេទ	ទីកន្លែង	ភូមិ-ឃុំពាក់ព័ន្ធសម្រាប់ការសិក្សា
មេឃុំវ៉ឺនសៃ ក្រុមប្រឹក្សាឃុំ និងមេភូមិ	៣ នាក់	14/05/2016	សាលាឃុំ	ឃុំវ៉ឺនសៃមិនពាក់ព័ន្ធនឹងតំបន់គម្រោង
មេឃុំត្រពាំងក្រហម មេឃុំត្រពាំងច្រេស	២ នាក់	26/04/2016	សាលាឃុំត្រពាំងក្រហម	ឃុំត្រពាំងក្រហម និងឃុំត្រពាំងច្រេស ស្ថិតនៅឆ្ងាយពីទីតាំងគម្រោង (១៥-២០គីឡូម៉ែត្រ) ហើយប្រជាជននៅក្នុងឃុំទាំងពីរនេះមិនមានរកអនុផលព្រៃឈើនៅក្នុងតំបន់គម្រោងទេ និងមិនមានពាក់ព័ន្ធនឹងគម្រោង SK Plantation នេះទេ
មេឃុំតឺន ប្រធានភូមិ និងអនុប្រធានភូមិ	៣ នាក់	25/04/2016	ផ្ទះលោកមេឃុំតឺន	ឃុំតឺនស្ថិតនៅឆ្ងាយពីទីតាំងគម្រោង (១៥-២០គីឡូម៉ែត្រ) ហើយប្រជាជននៅក្នុងឃុំទាំងពីរនេះមិនមានរកអនុផលព្រៃឈើនៅក្នុងតំបន់គម្រោងទេ និងមិនមានពាក់ព័ន្ធនឹងគម្រោង SK Plantation នេះទេ
មេឃុំកាចូន	១ នាក់	15/05/2016	សាលាឃុំកាចូន	ឃុំកាចូនមិនពាក់ព័ន្ធនឹងតំបន់គម្រោង
មេឃុំប៉ង់ ជំទប់ទី១ ប្រធាន និងអនុប្រធានភូមិប៉ង់ និងប្រធាននិងអនុប្រធានភូមិហ្វាំង	៦ នាក់	14/05/2016	សាលាឃុំប៉ង់	ឃុំប៉ង់ពាក់ព័ន្ធនឹងតំបន់គម្រោង
មេឃុំប៉ាកកាឡាន	១ នាក់	14/05/2016	សាលាឃុំប៉ាកកាឡាន	ឃុំប៉ាកកាឡានមិនពាក់ព័ន្ធនឹងតំបន់គម្រោង
មេឃុំភ្នំកុក ក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងអនុប្រធានភូមិទៀមក្រោម	៤ នាក់	25/04/2016	ផ្ទះលោកមេឃុំភ្នំកុក	ឃុំភ្នំកុកពាក់ព័ន្ធនឹងតំបន់គម្រោង
មេឃុំហាតប៉ក់ ជំទប់ទី១ ប្រធានភូមិហាតប៉ក់ និងប្រធានភូមិឡាំប៉ាក់	៤ នាក់	15/05/2016	សាលាឃុំហាតប៉ក់	ឃុំហាតប៉ក់ពាក់ព័ន្ធនឹងតំបន់គម្រោង

Draft

អាជ្ញាធរមូលដ្ឋាន	ចំនួនអ្នកចូលរួម	កាលបរិច្ឆេទ	ទីកន្លែង	ភូមិ-ឃុំពាក់ព័ន្ធសម្រាប់ការសិក្សា
មេឃុំតាឡាត មេភូមិ អនុភូមិ	១៥ នាក់	07/06/2016	សាលាឃុំតាឡាត	ឃុំតាឡាតពាក់ព័ន្ធនឹងតំបន់គម្រោង
មេឃុំរំពាត់ មេភូមិ អនុភូមិ ប្រធានសហគមន៍ អនុប្រធានសហគមន៍ និងសមាជិក	១៥ នាក់	07/06/2017	សាលាឆទៀនក្នុងភូមិរំពាត់	ឃុំរំពាត់ពាក់ព័ន្ធនឹងតំបន់គម្រោង

<u>ការកំណត់ទំហំសំណាកសម្រាប់ការអង្កេតតាមគ្រួសារ៖</u>

ការកំណត់សំណាកគំរូសម្រាប់ការសិក្សានេះ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រ Stratified Random Sampling (Keller, 2005) ដើម្បីផ្តល់ឱកាសស្មើៗគ្នា ដល់គ្រប់គ្រួសារក្នុងភូមិពាក់ព័ន្ធដែលបានជ្រើសរើស ក្នុងការទទួលបានការចូលរួមក្នុងការអង្កេតនេះ។ ជាដំបូងទំហំសំណាក ត្រូវកំណត់តាមវិធីសាស្ត្រកំណត់ទំហំសំណាកសរុប (Yamane, 1967) ដែលមានរូបមន្តដូចខាងក្រោម៖

$$n = \frac{N}{1+Ne^2}$$

ដោយ៖

- n ជាចំនួនសំណាកគំរូ (sample size)
- N ជាចំនួនគ្រួសារសរុប (population size)
- e ជាកម្រិតលម្អៀង(error limit)

ដោយកំណត់យកកម្រិតលម្អៀង e = 0,0៥ (កម្រិតជឿជាក់ ៩៥%) យើងទទួលបានទំហំសំណាកសរុបចំនួនគ្រួសារ ៣១៥ (ស្មើនឹង២១% នៃចំនួនគ្រួសារសរុបក្នុងភូមិទាំង១១)។ បន្ទាប់មកចំនួនសំណាកក្នុងភូមិនីមួយៗ ត្រូវបានកំណត់ដោយធ្វើការបែងចែកទំហំសំណាកសរុប ទៅតាមភាគរយនៃចំនួនគ្រួសារក្នុងភូមិនីមួយៗ ធៀបនឹងគ្រួសារសរុបក្នុងភូមិទាំង១១នោះ។ ជាចុងបញ្ចប់ ការជ្រើសរើសគ្រួសារតាមភូមិនីមួយៗមកធ្វើការសម្ភាសន៍ ត្រូវបានកំណត់ដោយប្រើវិធីសាស្ត្រជ្រើសរើសដោយចៃដន្យ (Random Sampling) ដោយកំណត់គំលាតស្មើៗគ្នា ពីសំណាកមួយទៅសំណាកមួយទៀត។ ក្នុងការចុះអង្កេតជាក់ស្តែង យើងទទួលបានចម្លើយពីតំណាងគ្រួសារចំនួន ៣១៨សំណាក (ដូចបង្ហាញក្នុងតារាង២.៥) លើសពីផែនការដែលបានកំណត់។

តារាង២.៨៖ ភូមិដែលត្រូវជ្រើសរើស និងទំហំសំណាកដែលបានសិក្សា

ស្រុក	ឃុំ	ភូមិ	ចំនួនគ្រួសារ	ចំនួនសំណាក
ស្រុកវ៉ឺនសៃ	ប៉ង់	ប៉ុង	២៣៦	៥០
		ហ្វាំង	៣៧២	៧៩
	ភ្នំកុក	កាឡៃ សាពូន	៤៥	១០

Draft

		កាឡៃ តាវ៉ាង	៩២	១៩
		ភ្នំកុកឡាវ	១០១	២១
		ភ្នំកុកព្រៅ	៧៦	១៦
		ទៀម ក្រោម	១១០	២៣
	ហាតប៉ក់	ហាត ប៉ក់	២១៥	៤៦
		ឡាំ ប៉ាក់	១៤	៣
ស្រុកសេសាន	តាឡាត	រំពាត់	៧៦	១៨
		តាឡាត	១៥០	៣៣
២ស្រុក	**៤ឃុំ**	**១១ភូមិ**	**១៤៨៧**	**៣១៨**

ការវិភាគទិន្នន័យ ត្រូវបានធ្វើឡើងដោយប្រើប្រាស់កម្មវិធី Microsoft Excel។ មុននឹងបញ្ចូលព័ត៌មានទៅក្នុងកម្មវិធី Microsoft Excel យើងបានធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីចៀសវាងការភ័ន្តច្រឡំ។ ព័ត៌មានក្នុងទម្រង់គុណវិស័យ ត្រូវបានយកមកបែងចែក និងធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទ បន្ទាប់មកយើងដាក់លេខកូដដោយកំណត់ទៅតាមប្រភេទនៃព័ត៌មាន រួចវាយបញ្ចូលទៅក្នុងប្រព័ន្ធ Microsoft Excel។ ជាចុងក្រោយយើងបកស្រាយ និងពិពណ៌នាទិន្នន័យដោយបង្កើតជាតារាង ក្រាហ្វិច តាមរយៈការវិភាគជាភាគរយ និងវិធានស្ថិតិ។

២.៤. ការចូលរួមពីសាធារណជន

គោលបំណងសំខាន់នៃកិច្ចពិគ្រោះយោបល់នេះ គឺដើម្បីស្រាវជ្រាវពីផលប៉ះពាល់ជាក់ស្តែងពីសកម្មភាពគម្រោងដែលគ្រោងនឹងអនុវត្តន៍(ពិសេសផលប៉ះពាល់ដីធ្លីរបស់ប្រជាជន) និងបង្កើននូវភាពចម្រុះនៃអ្នកពាក់ព័ន្ធ ក៏ដូចជាទទួលយកនូវគំនិតយោបល់អំពីក្តីបារម្ភ និងបញ្ហាដែលអាចកើតមានដោយសារគម្រោង និងដំណោះស្រាយនានាដែលឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកពាក់ព័ន្ធ។ ការពិគ្រោះយោបល់នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រសម្ភាសន៍ពាក់កណ្តាលផ្លូវការ (Semi-structure interview) និងកិច្ចពិភាក្សាជាមួយក្រុមគោលដៅ (Focus Group Discussion) ដូចខាងក្រោម៖

- ការពិគ្រោះយោបល់ដាច់ដោយឡែកពីគ្នាជាមួយអាជ្ញាធរឃុំចំនួន៧ (ឃុំវ៉ឺនសៃ កាចូន ប៉ង់ ប៉ាកកាឡាន ភ្នំកុក ហាតប៉ក់ តាឡាត) ដែលការពិគ្រោះយោបល់នេះ ត្រូវបានធ្វើឡើងរួមគ្នាជាមួយការសិក្សាធនធានសេដ្ឋកិច្ច-សង្គម និងដីវិសោស្ត្រខាងលើ
- ការពិគ្រោះយោបល់ដាច់ដោយឡែកពីគ្នាជាមួយមេភូមិ សហគមន៍ជនជាតិដើមភាគតិច និងប្រជាជន នៅក្នុងភូមិចំនួន ៩ (ភូមិប៉ង់ ភូមិហ្វាំង ភូមិកាឡៃសាពូន ភូមិកាឡៃតាវ៉ាង ភូមិទៀមក្រោម ភូមិហាតប៉ក់ ភូមិឡាំប៉ាក់ ភូមិតាឡាត និងភូមិរំពាត់)
- ការស្ទង់មតិប្រជាជនក្នុងតំបន់ ត្រូវបានធ្វើឡើងជាមួយតំណាងគ្រួសារចំនួន ៣១៨។ សំណួរពាក់ព័ន្ធនឹងការស្ទង់មតិនេះ (ការគាំទ្រចំពោះគម្រោង និងសំណូមពរ) ត្រូវបានដាក់បញ្ចូលទៅក្នុងការអង្កេតតាមគ្រួសារនៃការសិក្សាផ្នែកសេដ្ឋកិច្ច-សង្គមខាងលើ។

- កិច្ចពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលពាក់ព័ន្ធនៅមូលដ្ឋាន៖ អង្គការ SCW, អង្គការ NTFP, អង្គការទន្លេបី, អង្គការICSO, អង្គការសមាគមខ្មែរលើ (HA), និងអង្គការ DPA។
- ការពិភាក្សាដាច់ដោយឡែកជាមួយតំណាងស្ថាប័នជំនាញពាក់ព័ន្ធសំខាន់ៗ ដែលរួមមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តតេនគិរី ផ្នែករដ្ឋបាលព្រៃឈើវ៉ឺនសៃ និងផ្នែករដ្ឋបាលជលផលវ៉ឺនសៃ និងទន្លេសេសាន។ កិច្ចពិភាក្សាផ្តោតសំខាន់លើដំណើរការនៃការចុះបញ្ជីដីសម្បទានរបស់ក្រុមហ៊ុនជាដីឯកជនរបស់រដ្ឋ បញ្ហាទំនាស់ដីធ្លីជាមួយប្រជាជននិងដំណោះស្រាយ បញ្ហាព្រៃឈើ និងជលផល ព្រមទាំងដើម្បីស្វែងយល់ពីទស្សនៈ ក្តីកង្វល់ និងសំណូមពររបស់ស្ថាប័នជំនាញចំពោះការវិនិយោគនេះ។
- កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត ដែលដឹកនាំដោយតំណាងគណៈអភិបាលខេត្តតេនគិរី ក្រោមការសម្របសម្រួលរបស់មន្ទីរបរិស្ថានខេត្ត និងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធដូចខាងក្រោម៖
  - មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ជំនាញព្រៃឈើ និងជំនាញជលផល)
  - មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
  - មន្ទីរធនធានទឹក និងឧតុនិយម
  - មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
  - មន្ទីរផែនការ
  - មន្ទីរសុខាភិបាល
  - មន្ទីររ៉ែ និងថាមពល
  - មន្ទីរទេសចរណ៍
  - មន្ទីរសាធារណៈការ និងដឹកជញ្ជូន
  - មន្ទីរអភិវឌ្ឍន៍ជនបទ
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - អង្គការមិនមែនរដ្ឋាភិបាល (NGO) ដែលពាក់ព័ន្ធ
  - តំណាងគណៈអភិបាលស្រុក វ៉ឺនសៃ (ខេត្តតេនគិរី)
  - សហគមន៍ជនជាតិដើមភាគតិច។

២.៥. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន វិធីសាស្ត្រក្នុងការកំណត់ និងវិធានការកាត់បន្ថយ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានធ្វើឡើងដោយពិចារណាលើហេតុប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល។ ការវាយតម្លៃនេះ ក៏បានកំណត់នូវទំហំ ឬ កម្រិត និងរយៈពេលនៃផលប៉ះពាល់ផងដែរ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ ត្រូវបានធ្វើឡើងក្នុង ០៣ដំណាក់កាលគឺ ដំណាក់មុនប្រតិបត្តិ (មុនសាងសង់ និងសាងសង់) ការឈូសឆាយ កំណត់ព្រំប្រទល់ បោះបង្គោល ផ្លូវចូលការដ្ឋាន។ល។ ដំណាក់កាលប្រតិបត្តិ និងដំណាក់កាលបញ្ចប់គម្រោង។

វិធីសាស្ត្រក្នុងការវាយតម្លៃមួយចំនួនដូចខាងក្រោម ត្រូវបានប្រើប្រាស់៖

Draft

- Matrices៖ ជាតារាងដែលបង្ហាញអំពីទំនាក់ទំនងរវាងរាល់សកម្មភាពរបស់គម្រោង និងរាល់ធនធានបរិស្ថាន និងសង្គម ដែលអាចទទួលរងការប៉ះពាល់។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ជាដំបូងគេ ដើម្បីកំណត់អំពីហេតុប៉ះពាល់ (វិជ្ជមាន ឬអវិជ្ជមាន) ចំពោះធនធានបរិស្ថាន និងសង្គម ដោយមានការបញ្ជាក់អំពីកម្រិតនៃផលប៉ះពាល់ផលដែរ។

- Overlay៖ ជាការវាយតម្លៃដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានភូមិសាស្ត្រ (GIS) ដែលព័ត៌មានភូមិសាស្ត្រនានា (ដីធ្លីពាក់ព័ន្ធ ផ្លូវទឹក ទីជម្រាល គម្របព្រៃឈើ រូបភាពរបស់ Google Earth ។ល។) ត្រូវបានច្របាច់បញ្ចូលគ្នា ដើម្បីធ្វើការវាយតម្លៃពីភាពត្រួតស៊ីគ្នានៃសកម្មភាព ឬសមាសភាគបរិស្ថាន-សង្គម ដើម្បីព្យាករណ៍ពីផលប៉ះពាល់នានា ដែលបណ្តាលមកពីភាពត្រួតស៊ីគ្នានោះ។

- Checklist៖ ជាតារាងដែលបរិយាយអំពីធនធានបរិស្ថាន និងសង្គម ដែលអាចទទួលរងផលប៉ះពាល់ លក្ខណៈនៃហេតុ/ផលប៉ះពាល់ រួមផ្សំជាមួយនឹងការកំណត់អំពីទំហំ រយៈពេល និងការបរិយាយអំពីវិធានការកាត់បន្ថយចំពោះហេតុ/ផលប៉ះពាល់នីមួយៗ។

ការសិក្សានេះក៏បានគិតគូផងដែរអំពីបណ្តុំនៃហេតុប៉ះពាល់បរិស្ថានក្នុងតំបន់។ បណ្តុំនៃហេតុប៉ះពាល់គឺជាការសិក្សាអំពីបម្រែបម្រួលធនធានបរិស្ថាន ដែលបង្កឡើងដោយសកម្មភាពគម្រោង និងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចផ្សេងទៀតនៅក្នុងតំបន់។ ការវាយតម្លៃបណ្តុំនៃហេតុប៉ះពាល់នេះ ត្រូវបានធ្វើឡើងក្នុងទំហំផ្ទៃដីស្រុកចំនួនពី គឺស្រុកវើនសៃ និងស្រុកកូនមុំ។ បណ្តុំនៃហេតុប៉ះពាល់ចម្បងបំផុតដែលគួរឱ្យព្រួយបារម្ភ គឺការបាត់បង់ធនធានព្រៃឈើ និងបម្រែបម្រួលអវិជ្ជមាននៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី។ ការវាយតម្លៃបណ្តុំនៃហេតុប៉ះពាល់នេះ ត្រូវបានធ្វើឡើងដោយការវិភាគភាពត្រួតស៊ីគ្នារវាងផែនទីគម្របព្រៃឈើឆ្នាំ២០១០ (រដ្ឋបាលព្រៃឈើ) និងគម្របព្រៃឈើឆ្នាំ២០១៦ (Landsat 8)[1] ព្រមទាំងផែនទី ទីតាំងគម្រោងអភិវឌ្ឍន៍ផ្សេងទៀតដែលមាននៅក្នុង ស្រុកវើនសៃ និងស្រុកកូនមុំ។

២.៦. ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន គឺជាកម្មវិធីលម្អិតនៃការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម ដូចបានកំណត់នៅក្នុងដំពូកស្តីពីការវាយតម្លៃហេតុប៉ះពាល់ និងវិធានការកាត់បន្ថយខាងដើម ដោយលើកឡើងនូវគោលបំណង និងសកម្មភាពច្បាស់លាស់។ ក្នុងផែនការនេះ យើងក៏បានកំណត់ឱ្យបានច្បាស់អំពីការទទួលខុសត្រូវរបស់បុគ្គលិកគម្រោងចំពោះសកម្មភាពនីមួយៗ តម្រូវការថវិកា និងពេលវេលាសម្រាប់បំពេញការងារ ព្រមទាំងយន្តការត្រួតពិនិត្យតាមដានការអនុវត្តរបស់ស្ថាប័នមានសមត្ថកិច្ច។

ផែនការសកម្មភាពលម្អិត តម្រូវការថវិកា និងពេលវេលានៃការអនុវត្តសកម្មភាព ត្រូវបានកំណត់ដោយឈរលើមូលដ្ឋានសំខាន់ចំនួន ០៥ គឺ៖ ហេតុ/ផលប៉ះពាល់បរិស្ថាន-សង្គមដែលបានស្រាវជ្រាវរកឃើញ, ភាពអាចស្តារ ឬមិនអាចស្តារឡើងវិញបាននៃផលប៉ះពាល់ដែលអាចនឹងកើតឡើង, ទម្លាប់ល្អៗនៃការអនុវត្តវិធានការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យបរិស្ថាន, តម្រូវការជាក់ស្តែងនៅមូលដ្ឋាន, និងភាពអាចផ្គត់ផ្គង់/គាំទ្រជាថវិកាបានរបស់ក្រុមហ៊ុនម្ចាស់គម្រោង។

ផែនការគ្រប់គ្រងបរិស្ថាននេះ ក៏ត្រូវបានរៀបចំដោយបញ្ចូលនូវចំណុចគោលសំខាន់ៗដូចជា៖

[1] www.glovis.usgs.gov, Type of Land sat 8 OLI, Code: 125-50 and 125-51 (Date 14/04/2016)

Draft

- កម្មវិធីបណ្តុះបណ្តាល៖ ជាផែនការរបស់ក្រុមហ៊ុនដែលត្រូវធ្វើ ដើម្បីបង្កើនចំណេះដឹង និងប្រសិទ្ធភាពក្នុងការអនុវត្តការងារ ចំណេះដឹងអំពីការគ្រប់គ្រងការបំពុលបរិស្ថាន និងការថែរក្សាគុណភាពនៃការរស់នៅរបស់បុគ្គលិក កម្មករ និងសហគមន៍ជុំវិញ

- កម្មវិធីត្រួតពិនិត្យបរិស្ថាន

- កម្មវិធីស្តារបរិស្ថានឡើងវិញ និងអភិវឌ្ឍន៍មូលដ្ឋាន ក្នុងរូបភាពជាមូលនិធិបរិស្ថាន-សង្គម ដើម្បីប៉ះប៉ូវឬសងដល់ផលប៉ះពាល់បរិស្ថាន-សង្គមដែលនៅសេសសល់ (Residue Impact) បន្ទាប់ពីបានអនុវត្តផែនការគ្រប់គ្រងបរិស្ថាន

- ការចុះធ្វើអធិការកិច្ចរបស់ក្រសួង/ស្ថាប័នមានសមត្ថកិច្ច ដោយបញ្ចូលនូវ៖ សូចនាករ វិធីសាស្ត្រវាស់វែងនិងផ្ទៀងផ្ទាត់ និងស្ថាប័នដែលត្រូវចុះត្រួតពិនិត្យ។

២.៧. ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

ការវិភាគសេដ្ឋកិច្ច ត្រូវបានរៀបចំរួចរាល់ នៅក្នុងផែនការមេគម្រោងដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈលិខិតលេខ ៦២១៣ កសក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ ២០១៦។ ដូច្នេះ យើងបានលើកយកលទ្ធផលនៃការវិភាគសេដ្ឋកិច្ចនោះ បកបង្ហាញសង្ខេបនៅក្នុងជំពូកទី ៩។

ការវិភាគសេដ្ឋកិច្ចនោះ ត្រូវបានធ្វើឡើង ដោយប្រើប្រាស់តម្លៃនៅលើទីផ្សារ ដោយមិនទាន់បានគិតបញ្ចូលនូវថ្លៃខាតបង់ដោយសារផលប៉ះពាល់បរិស្ថាន-សង្គមដែលពុំមានតម្លៃនៅលើទីផ្សារនៅឡើយទេ។ លទ្ធផលនៃការសិក្សាក្នុងជំពូកទី៧ បង្ហាញថា ផលប៉ះពាល់អវិជ្ជមានសំខាន់បំផុតនៃគម្រោងវិនិយោគនេះ គឺការបាត់បង់ធនធានព្រៃឈើ និងផលប្រយោជន៍ទាំងផ្ទាល់ និងប្រយោល ដែលមនុស្សទទួលបានពីសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើ។ ការវាយតម្លៃជាសាច់ប្រាក់ នៃផលប្រយោជន៍ព្រៃឈើដែលបាត់បង់ដោយសារការប្រែក្លាយផ្ទៃដីព្រៃទៅជាផ្ទៃដីកសិកម្ម (ដំណាំកសិ-ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធក្រុមហ៊ុន) ក្នុងកិច្ចដំណើរការគម្រោងវិនិយោគនេះ ត្រូវបានធ្វើឡើងលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើតែចំនួន ០២ (ផល-អនុផលព្រៃឈោះ និងសេវាកម្មអភិរក្សទឹក) ទេ ដើម្បីចៀសវាងការរាប់ឌុប (Double Counting) ដែលជាជាបញ្ហាមួយនៃការជជែកវែកញែករវាងអ្នកវិទ្យាសាស្ត្រសិក្សាវាយតម្លៃសេដ្ឋកិច្ចនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី (Wallace, 2007)។ ការវាយតម្លៃនេះ ត្រូវបានពឹងផ្អែកលើវិធីសាស្ត្រផ្ទេរតម្លៃ Benefit Transfer ឬ Value Transfer (Brander, Brouwer, & Wagtendonk, 2013)។ វិធីសាស្ត្រផ្ទេរតម្លៃនេះ ត្រូវបានយកមកប្រើប្រាស់នៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសមួយចំនួនទៀត ហើយក៏ត្រូវបានបំផុសឱ្យយកមកប្រើប្រាស់ដោយកម្មវិធីបរិស្ថានពិភពលោក (UNEP) ដើម្បីបំពេញតម្រូវការព័ត៌មានសម្រាប់ធ្វើការសម្រេចចិត្តលើគម្រោងស្នើសុំមួយដែលមានផលប៉ះពាល់បរិស្ថាន-សង្គមគួរឱ្យកត់សម្គាល់។ ក្នុងការផ្ទេរតម្លៃ យើងមានជម្រើសចំនួន ០៣៖ Unit Value Transfer, Value Function Transfer, និង Meta-analytic Function Transfer។ ក្នុងការសិក្សានេះ យើងប្រើប្រាស់ Unit Value Transfer ដើម្បីផ្ទេរតម្លៃក្នុងមួយឯកតានៃ សេវាកម្មមួយពីទីតាំងសិក្សាកន្លងមក មកធ្វើការប៉ាន់ស្មានតម្លៃនៃសេវាកម្មនោះនៅទីតាំងដែលកំពុងសិក្សា (សេវាកម្មដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងវិនិយោគនេះ)។

ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ UNEP (Brander et al., 2013) យើងធ្វើការកែតម្រូវតម្លៃនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីព្រៃឈើទាំង០២នោះ ទៅតាមឆ្នាំសិក្សាដោយប្រើរូបមន្ត Eq.1 និង/ឬ ទៅតាម

ភាពខុសគ្នារវាងប្រាក់ចំណូលប្រជាជនក្នុងតំបន់សិក្សាកន្លងមក (ព្រោះការសិក្សាបឋមមួយចំនួន ធ្វើឡើងនៅប្រទេសផ្សេង) និងប្រាក់ចំណូលប្រជាជនក្នុងតំបន់កំពុងសិក្សា (ប្រទេសកម្ពុជា) ដោយប្រើប្រាស់រូបមន្ត Eq.2 ។ ការកែតម្រូវទៅតាមឆ្នាំសិក្សានេះ ត្រូវបានធ្វើឡើង ដោយហេតុថា អតិផរណាធ្វើឱ្យកម្រិតនៃតម្លៃជាទូទៅនៅក្នុងប្រទេសមួយមានការកើនឡើងទៅតាមពេលវេលា ដូច្នេះថវិកាក្នុងចំនួនណាមួយមានតម្លៃថោកជាងក្នុងពេលអនាគតនៅពេលប្រើប្រាស់សម្រាប់ទិញទំនិញអ្វីមួយ។ ការកែតម្រូវទៅតាមភាពខុសគ្នានៃប្រាក់ចំណូលត្រូវបានធ្វើឡើង ដោយហេតុថា តម្រូវការទំនិញ និងសេវាកម្មស្ទើរតែទាំងអស់ (រួមទាំងសេវាកម្មនៃមុខងារប្រព័ន្ធអេកូឡូស៊ី) ប្រែប្រួលទៅតាមប្រាក់ចំណូល។ ជាទូទៅ កាលណាប្រាក់ចំណូលកើនឡើង តម្រូវការក៏មានការកើនឡើងដែរ ហើយចំនួនទឹកប្រាក់ដែលមនុស្សស្ម័គ្រចិត្តចំណាយ (Willing-ness to pay – WTP) ដើម្បីទទួលបាន ឬចៀសវាងការបាត់បង់សេវាកម្មនោះ ក៏មានការកើនឡើងដែរ។

$$WTP'_p = WTP_s(\frac{D_p}{D_s}) \quad \text{(Eq.1)}$$

ដោយ៖

WTP'_p = តម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់សេវាណាមួយនៅឆ្នាំកំពុងសិក្សា

WTP_s = តម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់ណាមួយនៅឆ្នាំសិក្សាកន្លងមក

D_p = GDP deflator index នៅតំបន់សិក្សាក្នុងឆ្នាំកំពុងសិក្សា

D_s = GDPdeflator index នៅតំបន់សិក្សាក្នុងឆ្នាំសិក្សាកន្លងមក

$$WTP'_p = WTP_p(\frac{Y_p}{Y_s})^E \quad \text{(Eq.2)}$$

ដោយ៖

WTP'_p = តម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់សេវាណាមួយនៅតំបន់គម្រោងក្នុងឆ្នាំកំពុងសិក្សា

WTP_p = តម្លៃនៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់សេវាណាមួយនៅតំបន់សិក្សាកន្លងមក (តំបន់ផ្សេងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា) ក្នុងឆ្នាំកំពុងសិក្សា

Y_p = GDP per capita នៅតំបន់គម្រោងក្នុងឆ្នាំដែលតម្លៃនៃការស្ម័គ្រចិត្តចំណាយត្រូវសិក្សា

Y_s = GDP per capita នៅតំបន់សិក្សាកន្លងមកក្នុងឆ្នាំដែលតម្លៃនៃការស្ម័គ្រចិត្តចំណាយត្រូវបានសិក្សា

E = Income elasticity នៃការស្ម័គ្រចិត្តចំណាយដើម្បីបញ្ចៀសការបាត់បង់សេវា

ក្នុងការប៉ាន់ស្មានពីតម្លៃខូចខាតសេដ្ឋកិច្ចដោយសារការបាត់បង់ព្រៃឈើក្នុងដំណើរការគម្រោងនេះ យើងក៏បានគិតគូរពីផលចំណេញដល់សេដ្ឋកិច្ច (ចំណូលចូលរដ្ឋ) ដោយសារការធ្វើអាជីវកម្មធនធានឈើដែលមានក្នុងទីតាំងគម្រោង។ ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ចចំនួន ៦.០៥៩,២៧ ហិកតា សម្រាប់វិនិយោគដាំដំណាំកសិ-ឧស្សាហកម្មនេះ គឺជាជម្រើសមួយដែលជំរុញឱ្យមានការធ្វើអាជីវកម្មធនធានឈើឈរដែលមាននៅក្នុងទីតាំងនេះទាំងស្រុងដោយខានមិនបាន (ធ្វើអាជីវកម្មបានតែម្តងគត់) មុននឹងក្រុមហ៊ុនធ្វើការឈូសឆាយ និងដាំដុះ។ ការប៉ាន់ស្មានតម្លៃធនធានឈើដែលត្រូវធ្វើអាជីវកម្ម ត្រូវបានពឹងផ្អែកទាំងស្រុងលើលទ្ធផលនៃសារពើភ័ណ្ឌព្រៃឈើ ដូចបានរៀបរាប់ខាងលើ។

Draft

៣. ទម្រង់របាយការណ៍

របាយការណ៍នេះ ត្រូវបានចងក្រងឡើង ដោយអនុលោមតាមគោលការណ៍ណែនាំទូទៅស្តីពីការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ របស់ក្រសួងបរិស្ថាន (ឆ្នាំ២០០៩)។ បន្ទាប់ពីជំពូកទី១នេះ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះមាន៩ជំពូកទៀត ដូចខាងក្រោម៖

ជំពូកទី២៖ វិធីសាស្ត្រ និងទំហំនៃការសិក្សា

ជំពូកទី៣៖ ក្របខ័ណ្ឌច្បាប់

ជំពូកទី៤៖ ការពិពណ៌នាអំពីគម្រោង

ជំពូកទី៥៖ ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

- ធនធានរូបសាស្ត្រ
- ធនធានជីវសាស្ត្រ
- ធនធានសេដ្ឋកិច្ច-សង្គម

ជំពូកទី៦៖ ការចូលរួមពីសាធារណៈជន

ជំពូកទី៧៖ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

ជំពូកទី៨៖ ផែនការគ្រប់គ្រងបរិស្ថាន

ជំពូកទី៩៖ ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

ជំពូកទី១០៖ សន្និដ្ឋាន និងអនុសាសន៍

៤. ក្រុមសិក្ខាស្រាវជ្រាវ

ឈ្មោះ	ជំនាញ	តួនាទី
លោកស្រី រិត សំអុល	បណ្ឌិតបរិស្ថាន ជំនាញអភិបាលកិច្ចបរិស្ថាន និងអភិវឌ្ឍន៍សហគមន៍	ប្រធានក្រុមបច្ចេកទេសនិងប្រធានគម្រោង
លោកស្រី ហាក់ ដាណែត	បណ្ឌិតវិស្វកម្មបរិស្ថាន	ជំនាញការបច្ចេកទេស
លោក សឹង យីតា	បរិញ្ញាបត្រវិទ្យាសាស្ត្របរិស្ថាន	ជំនួយការបច្ចេកទេស
លោក ហៀន សំណាង	បរិញ្ញាបត្រវិទ្យាសាស្ត្រព្រៃឈើ	ជំនួយការបច្ចេកទេស
លោក នេត សុភានិត្យ	បរិញ្ញាបត្រព័ត៌មានវិទ្យា	ជំនួយការបច្ចេកទេស
លោក លឹម សុខនី	បរិញ្ញាបត្រផ្សព្វផ្សាយ និងអភិវឌ្ឍន៍ជនបទ	ជំនួយការបច្ចេកទេស
លោក កែវ ប៊ុនស្រៀង	បរិញ្ញាបត្រវិទ្យាសាស្ត្រព្រៃឈើ	ជំនួយការបច្ចេកទេស

Draft

ជំពូកទី៣
ក្រមខ័ណ្ឌច្បាប់

Draft

ជំពូកទី៣៖ ក្របខ័ណ្ឌច្បាប់

វត្តមានគម្រោងវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម របស់**ក្រុមហ៊ុន អេស ខេ ផ្លេន ថេសិន ខេមបូឌា** [SK Plantation (Cambodia) Pte. Ltd.] លើផ្ទៃដី ៦.៥០៩,២៧ហ.ត ស្ថិតក្នុងភូមិសាស្ត្រឃុំប៉ុង ឃុំហាត់ប៊ក ឃុំភ្នំកុក ស្រុកវ៉ឺនសៃ និងឃុំតឺន ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី អាចមានផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានដល់សហគមន៍មូលដ្ឋាន និងធនធានបរិស្ថានក្នុងតំបន់។ យោងតាមប្រភេទគម្រោង និងស្ថានភាពទីតាំងគម្រោង ម្ចាស់ក្រុមហ៊ុនវិនិយោគត្រូវធ្វើការពិនិត្យ និងអនុវត្តតាមច្បាប់ និងបទដ្ឋានគតិយុត្តក្រោមច្បាប់នានាដូចលើកមកបង្ហាញសង្ខេបក្នុងផ្នែកខាងក្រោម ដើម្បីគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់ទាំងនោះ និងដើម្បីផ្តល់ជាយន្តការគតិយុត្តក្នុងការដោះស្រាយនូវបញ្ហានានាដែលបង្កឡើងដោយសកម្មភាពគម្រោង។

៣.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា។ រាល់ច្បាប់ និងឯកសារគតិយុត្តទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញ បើពុំនោះសោត ច្បាប់ និងឯកសារគតិយុត្តទាំងនោះនឹងអធម្មនុញ្ញភាព។ ជំពូកទី ៥ អំពីសេដ្ឋកិច្ច មានមាត្រាចំនួន ២ ដែលត្រូវស្វែងយល់ ៖

មាត្រា ៥៩ ៖ រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានដូចជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។

មាត្រា ៦១ ៖ រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់លើនយោបាយ ទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេស ទំនើប និងប្រព័ន្ធឥណទាន។

៣.២. ច្បាប់ពាក់ព័ន្ធ

៣.២.១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស.រកម.១២៩៦.៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦។ ច្បាប់នេះមានគោលដៅ ៖ (១). ការពារ និងលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពប្រជាពលរដ្ឋដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល (២). វាយតម្លៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គម្រោងដែលបានស្នើឡើង (៣). ធានាឱ្យមានការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនៃធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា (៤). លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង (៥). បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់បរិស្ថាន។

ដើម្បីសម្រេចបាននូវគោលដៅខាងលើនេះ មាត្រាមួយចំនួននៃច្បាប់នេះបានចែងថា ៖

មាត្រា ៦ ៖ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬ សាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។ ការវាយតម្លៃនេះក៏ត្រូវបានអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។ បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន។ ប្រភេទ និងទំហំគម្រោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ត្រូវកំណត់ដោយអនុក្រឹត្យ [អនុក្រឹត្យលេខ ៧២ ខាងក្រោម] តាមសំណើរបស់ក្រសួង បរិស្ថាន។

មាត្រា ៧ ៖ ចំពោះរាល់ពាក្យស្នើសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៨ ៖ ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។ តំបន់ការពារធនធានធម្មជាតិមានជាអាទិ៍ ឧទ្យានជាតិ ជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាងត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

មាត្រា ៩ ៖ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើការសិក្សាស្រាវជ្រាវវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើធនធានធម្មជាតិ និងផ្តល់យោបល់ដូនក្រសួងពាក់ព័ន្ធ ដើម្បីធានាឱ្យធនធានធម្មជាតិដូចមានចែងក្នុងមាត្រា ៨ ត្រូវបានអភិរក្ស អភិវឌ្ឍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផលប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។

មាត្រា ១៣ ៖ ការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុលអាកាស ទឹក ដី ការរំខានដោយសំឡេង និងរំញ័រ ព្រមទាំងសំណល់សារធាតុពុល និងសារធាតុប្រកបដោយគ្រោះថ្នាក់ ត្រូវកំណត់ដោយអនុក្រឹត្យ [អនុក្រឹត្យលេខ ២៧, អនុក្រឹត្យលេខ៣៦, អនុក្រឹត្យលេខ ៤២] តាមសំណើរបស់ក្រសួងបរិស្ថាន។

មាត្រា ១៤ ៖ ក្រសួងបរិស្ថាននឹងសហការជាមួយក្រសួងដែលពាក់ព័ន្ធ ដើម្បីតម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងរោងចក្រ ប្រភពបំពុល តំបន់ឧស្សាហកម្ម ឬ តំបន់មានសកម្មភាពអភិវឌ្ឍន៍ធនធានធម្មជាតិនានា ៖

- តម្លើង ឬ ប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ
- ផ្តល់គំរូតាង និង
- រៀបចំ ឬ រក្សាទុក និងផ្ញើជូនពិនិត្យនូវកំណត់ត្រា និងរបាយការណ៍នានា។

Draft

៣.២.២. ច្បាប់ស្តីពីកិច្ចការពាររបៀបកកណ្តាវប្បធម៌ ឆ្នាំ១៩៩៦

ច្បាប់ស្តីពីកិច្ចការពាររបៀបកកណ្តាវប្បធម៌ ត្រូវបានប្រកាសដោយព្រះរាជក្រមលេខ.... ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦។ ច្បាប់នេះមានគោលដៅថែរក្សាការពាររបៀបកកណ្តាវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅ ប្រឆាំងនឹងការ បំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់។

មាត្រា ៤ ៖ តាមន័យនៃច្បាប់នេះ សម្បត្តិវប្បធម៌គឺរាល់ស្នាដៃរបស់មនុស្ស និងរាល់ផលិតផលរបស់ធម្ម ជាតិ ដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬ សាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តន៍របស់ អារ្យធម៌ ឬ របស់ធម្មជាតិ ហើយដែលកិច្ចការពារសម្បត្តិវប្បធម៌ទាំងនោះមប្រើប្រយោជន៍សាធារណៈ។

មាត្រា ៣៧ ៖ នៅពេលដែលកំពុងដំណើរការងារផ្សេងៗទៀត ហើយបានជួបប្រទះសម្បត្តិវប្បធម៌ដូចជា ប្រាសាទបាក់បែក វត្ថុបុរាណ សំណល់ផ្ទះសំបែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹត ឬ សម្បត្តិវប្បធម៌ដែល ទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬ ក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រដែល សិក្សាអតីតកាល ឬ មនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញសម្បត្តិទាំងនេះ និងម្ចាស់អចនលវត្ថុ ត្រូវតែបញ្ឈប់ ការងារ ឬ សកម្មភាព រួចរាយការណ៍ជាបន្ទាន់ជូនភ្នាក់ងារនគរបាលក្នុងតំបន់។ ភ្នាក់ងារនគរបាលនោះត្រូវបញ្ជូន របាយការណ៍នេះយ៉ាងប្រញាប់ជូនទៅអភិបាលខេត្ត ក្រុង។ អភិបាលខេត្ត ក្រុងត្រូវជូនព័ត៌មាននេះដល់អាជ្ញា ធរមានសមត្ថកិច្ចដើម្បីចាត់វិធានការចាំបាច់ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌ និងរមណីដ្ឋានវប្បធម៌នោះ។

៣.២.៣. ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

ច្បាប់ស្តីពីការងារបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខជស/រកម/០៣៩៧/០១ ចុះថ្ងៃ ទី១៣ ខែមីនា ឆ្នាំ១៩៩៧។

មាត្រា ១ ៖ ច្បាប់នេះគ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្ម ករនិយោជិត ដើម្បីយកមកអនុវត្តលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ ដោយ ទោះបីភាគីទាំងនោះមានសញ្ជាតិជាអ្វី ហើយស្នាក់នៅទីណាក៏ដោយ។

ច្បាប់នេះអនុវត្តចំពោះសហគ្រាស ឬ គ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា កសិកម្ម ដឹក ជញ្ជូនតាមផ្លូវគោក ឬ តាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ជាការបង្រៀនវិជ្ជាជីវៈ ឬ ជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬ នៃក្រុមប្រកេទណាក៏ដោយ។

មាត្រា ១២ ៖ វៀរលែងតែមានបទប្បញ្ញត្តិនៃច្បាប់ការងារនេះបញ្ជាក់ច្បាស់ ឬ អត្ថបទដទៃទៀតដែលមាន លក្ខណៈជាច្បាប់ ឬ ជាបទបញ្ជាដែលការពារស្ត្រី និងកូនក្មេង ក៏ដូចជាបទប្បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងការ ចូលមកក្នុងប្រទេស និងការស្នាក់នៅនៃជនបរទេសបញ្ជាក់ច្បាស់ គ្មាននិយោជកណាម្នាក់អាចយកបញ្ហា ៖

- ពូជសាសន៍
- ពណ៌សម្បុរ
- ភេទ
- ជំនឿ
- សាសនា

- គំនិតនយោបាយ
- ជាតិកំណើត
- ដើមកំណើតសង្គម
- ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬ ការធ្វើសកម្មភាពក្នុងសហជីព

ដើម្បីជាលេសធ្វើសេចក្តីសម្រេចអំពី ៖

- ការជួល
- ការកំណត់ និងការបែងចែកការងារ
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការដំឡើងថ្នាក់
- ការដំឡើងឋានន្តរសក្តិ
- ការផ្តល់កម្រៃ
- ការផ្តល់អត្ថប្រយោជន៍សង្គម
- វិន័យ ឬ ការផ្តាច់កិច្ចសន្យាការងារ។

ការបែងចែក ការបដិសេធន៍ ឬ ការព្រមទទួល ដែលផ្អែកទៅលើលក្ខណៈសម្បត្តិជាកំណត់ សម្រាប់មុខរបរណាមួយ មិនត្រូវចាត់ទុកជាការរើសអើងឡើយ។

មាត្រា ១១៣ ៖ ប្រាក់ឈ្នួល ត្រូវបើកឱ្យដោយផ្ទាល់ដៃទៅសាមីខ្លួនកម្មកររនិយោជិត លើកលែងតែកម្មករនិយោជិតព្រមបើកតាមវិធីផ្សេងៗទៀត។ ប្រាក់ឈ្នួលនេះត្រូវបើកជាប្រាក់លោហធាតុ ឬ ជាក្រដាស ដែលចាយជាផ្លូវច្បាប់ ទោះបីមានបទប្បញ្ញត្តិចែងផ្ទុយពីនេះក៏ដោយ។

មាត្រា ១១៦ ៖ ប្រាក់ឈ្នួលនៃកម្មករ ត្រូវបើកយ៉ាងហោចណាស់ពីរ (២) ដងក្នុងមួយខែ ដោយមានចន្លោះពេលយ៉ាងច្រើន ដប់ប្រាំមួយ (១៦) ថ្ងៃ។ ប្រាក់ឈ្នួលនៃនិយោជិតត្រូវបើកយ៉ាងហោចណាស់ មួយដង (១) ក្នុងមួយខែ។

ចំពោះការងារម៉ៅការ ឬ តាមបរិមាណផលិតផល ត្រូវបំពេញលើសពីដប់ប្រាំ (១៥) ថ្ងៃ កាលបរិច្ឆេទនៃការបើកប្រាក់ឈ្នួលអាចកម្រិតតាមការព្រមព្រៀងគ្នាបាន ប៉ុន្តែកម្មករត្រូវទទួលប្រាក់រំលស់ក្នុង ដប់ប្រាំ (១៥) ថ្ងៃ ម្តង ហើយត្រូវបានទទួលប្រាក់ឈ្នួលគ្រប់ចំនួនក្នុងសប្តាហ៍បន្ទាប់ពីថ្ងៃប្រគល់របស់ដែលធ្វើរួច។

មាត្រា ១១៧ ៖ ក្នុងករណីបើកប្រាក់យឺតយូរដោយគ្មានសមហេតុផល អធិការការងារត្រូវដាក់កំហិតដល់និយោជកឱ្យបើកប្រាក់ឈ្នួលឱ្យទៅកម្មករនិយោជិត ដោយកម្រិតរយៈពេលដែលត្រូវបើកប្រាក់ឈ្នួលនោះ។ កាលណាប្រាក់ឈ្នួលនោះមិនបានបើកក្នុងរយៈពេលដែលបានកម្រិតនោះទេ អធិការការងារត្រូវធ្វើកំណត់ហេតុ ហើយបញ្ជូនសំណុំរឿងនេះដោយឥតបង់សោហុយទៅតុលាការមានសមត្ថកិច្ចដែលអាចចាត់គ្រប់វិធានការរក្សាទ្រព្យសម្បត្តិទុកជាប្រយោជន៍កម្មករនិយោជិត ព្រមទាំងចាត់តាំងអភិបាលបណ្តោះអាសន្នមួយរូបផងក៏បាន។ បន្ទាប់មកអធិការការងារអាចប្តឹងចោទប្រកាន់គ្រប់បែបយ៉ាង ដើម្បីបង្ខំនិយោជកឱ្យបំពេញកាតព្វកិច្ចចំពោះកម្មករ និងនិយោជិតខ្លួន។

មាត្រា ១២៦ ៖ ការកាត់ប្រាក់ឈ្នួល ក្នុងគោលបំណងឱ្យអ្នកទទួលរកការងារឱ្យធ្វើ ទោះបីដោយចំពោះក្តី ឬ មិនចំពោះក្តី ឱ្យទៅនិយោជក អ្នកតំណាងនិយោជក ឬ អន្តរការីណាម្នាក់ ដូចជាភ្នាក់ងារទទួលជ្រើសរើសហត្ថពលករជាដើម ត្រូវហាមឃាត់។

មាត្រា ១៣២ ៖ និយោជក និងនាយកគ្រឹះស្ថានដែលមានប្រើកម្មករជាក្មេង ឬ កូនជាងអាយុតិចជាង ១៨ ឆ្នាំ ឬ ស្ត្រីឱ្យធ្វើការក្នុងនោះត្រូវមើលឱ្យមានកិរិយាមាយាទល្អ ហើយនឹងរក្សាការសមរម្យចំពោះសាធារណៈជនផង។ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងចំពោះការរំលោភខាងផ្លូវភេទគ្រប់ទ្រង់ទ្រាយទាំងអស់។

មាត្រា ១៣៧ ៖

១- អាយុអប្បបរមាអាចចូលធ្វើការជាកម្មកររនិយោជិតត្រូវបានកំណត់ត្រឹម ដប់ប្រាំ (១៥) ឆ្នាំ។

២- អាយុអប្បបរមារបស់កម្មកររនិយោជិតត្រូវកំណត់ដល់ ដប់ប្រាំបីឆ្នាំ ចំពោះមុខរបរ ឬ ការងារគ្រប់ប្រភេទ ដែលអាចធ្វើឱ្យខូចសុខភាព សន្តិសុខ ឬ សីលធម៌របស់មនុស្សពេញជំទង់ដោយសារតែលក្ខខណ្ឌ ឬ ប្រភេទរបស់មុខរបរ និងការងារទាំងនោះបង្កឡើង។ បែបផែននៃមុខរបរ ឬ ការងារដែលមានចែងក្នុងកថាខណ្ឌនេះ ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយ គណៈកម្មការប្រឹក្សាការងារ។

មាត្រា ១៨៨ ៖ កម្មកររនិយោជិតទាំងអស់ដែលជ្រើសរើសធ្វើពីកន្លែងធ្វើការ ហើយការណានិយោជកទទួលបន្ទុកដឹកនាំឱ្យមកកាន់ទីកន្លែងធ្វើការនោះ លុះចប់កិច្ចសន្យា ឬ ដល់ពេលឈប់សម្រាកត្រូវមានសិទ្ធិបានសោហ៊ុយធ្វើដំណើរត្រឡប់ទៅទីកន្លែងដែលគេជ្រើសរើសនោះវិញ។ សោហ៊ុយនេះត្រូវនិយោជកចេញឱ្យតាមលក្ខខណ្ឌដូចគ្នានឹងដំណើរមកកាន់កន្លែងធ្វើការដែរ។

ជំពូកទី៧ (១៩២ ដល់ ២២២ ខាងក្រោម) នៃច្បាប់បានចែងច្បាស់អំពីលក្ខខណ្ឌដោយឡែកនៃការងារក្នុងវិជ្ជាជីវៈខាងកសិកម្ម។ ដោយក្នុងនោះ មាត្រា ១៩២ បានកំណត់នូវប្រភេទនៃកម្មកររនិយោជិតក្នុងវិជ្ជាជីវៈខាងកសិកម្មថា គឺកម្មកររនិយោជិតដែលធ្វើការខាង ៖

- ចម្ការ
- អាជីវកម្មខាងកសិកម្ម " ដាំដំណាំ និង ចិញ្ចឹមសត្វ "
- អាជីវកម្មព្រៃឈើ
- អាជីវកម្មនេសាទ។

មាត្រា ២០៤ ៖ កម្មកររនិយោជិតធ្វើការទៀតទាត់ជាប់លាប់មួយកន្លែង មានសិទ្ធិត្រូវបានគេហាដ្ឋាននៅដោយឥតគិតថ្លៃ " គេហដ្ឋានធំ និង សាខា " ដែលនិយោជកផ្តល់ឱ្យក្នុងលក្ខខណ្ឌដូចមានកំណត់ក្នុងប្រកាសក្រសួង ទទួលបន្ទុកវិស័យការងារ។

មាត្រា ២០៥ ៖ គេហដ្ឋាន " តួផ្ទះធំ " ដែលនិយោជកផ្តល់ឱ្យកម្មកររនិយោជិត មានប្តី ប្រពន្ធ រស់នៅជួបជុំគ្រួសារ ត្រូវមានផ្ទៃក្រឡាអាចនៅបានជាអប្បបរមា មានទំហំម្តែបួន (២៤) ម៉ែត្រទ្វេគុណ។ គេហដ្ឋានដូចគ្នានេះនឹងផ្តល់ឱ្យកម្មកររនិយោជិតដែលនៅលើរភេទដូចគ្នា ចំនួនបួន (៤) នាក់យ៉ាងច្រើនរស់នៅក្នុងផ្ទះនីមួយៗ។

មាត្រា ២០៦ ៖ គេហដ្ឋានទាំងនេះត្រូវសង់តាមបទបញ្ជាអនាម័យ និងសុខភាពសាធារណៈ ដែលរាជការមានសមត្ថកិច្ចបានចេញឱ្យ។ ដើម្បីឱ្យបានគេហដ្ឋានដូចខាងលើនេះ សហគ្រាសទាំងឡាយត្រូវជួនល្អង់ និងកិន

ភាគនៃគំរូផ្ទៃមួយ ឬ ច្រើនទៅអធិការដ្ឋានការងារដែលក្រសួងនេះត្រូវឱ្យយោបល់ផ្ទាល់ រួចទើបបញ្ជូនទៅរដ្ឋអំណាចខេត្ត ក្រុងមានសមត្ថកិច្ច។

មាត្រា ២១០ ៖ ការផ្តល់ទឹកឱ្យកម្មករនិយោជិតប្រើប្រាស់តាមត្រូវការ ត្រូវឱ្យនិយោជកចាត់ចែងឱ្យមានគ្រប់ដ្ឋេវតាមលក្ខខណ្ឌដ៏សមរម្យបំផុត។

មាត្រា ២១២ ៖ ក្នុងករណីដែលទឹកនោះមានប្រភពគួរឱ្យសង្ស័យថាមានគ្រោះថ្នាក់ និយោជកត្រូវចាត់វិធានការចាំបាច់ ដោយសួរយោបល់ក្រុមពេទ្យសាធារណៈ (ដូចជាការសំអាតដោយដាំទឹកឱ្យឆ្អិន ឬការប្រើជាតិគីមីដើម្បីសំអាតទឹកនោះជាដើម)។

មាត្រា ២១៤ ៖ នៅក្នុងទីប្រជុំជននីមួយៗនៃកម្មករនិយោជិត ត្រូវតែមានបង្គន់អនាម័យ ដោយចំនួនយ៉ាងតិចស្មើនឹងមួយភាគបួននៃគេហដ្ឋាន។ បង្គន់អនាម័យនេះត្រូវសង់ឱ្យបានឆ្ងាយគួរសមពីគេហដ្ឋាន ហើយឱ្យមានដំបូលព្រមទាំងជញ្ជាំងបិទបាំងត្រឹមត្រូវ។ បង្គន់អនាម័យទាំងនោះត្រូវបិទកុំឱ្យធុំក្លិនមកក្រៅ ហើយថែទាំឱ្យមានអនាម័យជានិច្ច។

មាត្រា ២១៥ ៖ សម្រាមផ្ទះបាយ និងកាកសំណល់គ្រប់ប្រភេទត្រូវដាក់ក្នុងរណ្តៅឆ្ងាយពីផ្លូវទឹក ហើយលុបជិតរាល់ថ្ងៃ ឬ មួយដុតចោល។

មាត្រា ២២២ ៖ កាលណាក្នុងចម្ការមានក្មេងអាយុប្រាំមួយឆ្នាំពេញចំនួនយ៉ាងតិច ២០នាក់ ជាកូនកម្មករនិយោជិតធ្វើការជាប់លាប់ស្នាក់នៅនឹងចម្ការ និយោជកត្រូវសង់ហើយថែទាំឱ្យមានសាលាបឋមសិក្សានៅជិតគេហដ្ឋានកម្មករនិយោជិតទាំងនោះ ដោយមានចំនួនសមស្របតាមសេចក្តីត្រូវការ។

ជំពូកទី៨ ស្តីពីអនាម័យ និងសន្តិសុខនៃកម្មករនិយោជិត និង**ជំពូកទី៩** ស្តីពីគ្រោះថ្នាកការងារ នៃច្បាប់ស្តីពីការងារក៏មានមាត្រាមួយចំនួន ដែលគម្រោងត្រូវអនុវត្តតាមឱ្យបានត្រឹមត្រូវ។

មាត្រា ២២៩ ៖ គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការត្រូវរក្សាឱ្យបានស្អាត ហើយបង្ហាញថា មានលក្ខខណ្ឌអនាម័យ និងសភាពសុខសប្បាយជានិច្ច ឬ ជាទូទៅត្រូវឱ្យមានលក្ខខណ្ឌការងារជាចាំបាច់សម្រាប់សុខភាពរបស់កម្មករនិយោជិត។ ក្រសួងទទួលបន្ទុកវិស័យការងារ និងក្រសួងពាក់ព័ន្ធ ត្រូវរៀបចំធ្វើប្រកាសដើម្បីតាមដាន ត្រួតពិនិត្យ ការអនុវត្តមាត្រានេះ សម្រាប់ឱ្យអនុវត្តបាននៅគ្រប់គ្រឹះស្ថានដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃជំពូកនេះ ជាពិសេសដែលពាក់ព័ន្ធដល់ ៖

- គុណភាពនៃទីកន្លែងធ្វើការ
- ការបោសសំអាត
- ឋបនកិច្ចសុខាភិបាលដែលត្រូវមានសម្រាប់សេចក្តីត្រូវការរបស់បុគ្គលិក
- កេសជ្ជៈ និងអាហារ
- ការស្នាក់នៅជាយថាហេតុរបស់បុគ្គលិក
- ប៉ុស្តិ៍ការងារ និងការរៀបចំអាសនៈធ្វើការ
- វិធានការសម្រាប់ធ្វើឱ្យខ្យល់ចេញចូលបានស្រួល និងការសំអាតបរិយាកាសកន្លែងធ្វើការ
- ឧបករណ៍ការពារផ្ទាល់ខ្លួន និងសម្លៀកបំពាក់ការពារ
- ពន្លឺ និងសំឡេងក្នុងកន្លែងធ្វើការ។

មាត្រា ២៣០ ៖ គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការ ត្រូវរៀបចំយ៉ាងណាឱ្យមានការធានាសុវត្ថិភាពរបស់កម្មករនិយោជិត។ គ្រឿងម៉ាស៊ីន គ្រឿងយន្ត បរិធានសម្រាប់ការបញ្ជូន ឧបករណ៍តូចធំ និងម៉ាស៊ីន ត្រូវដាក់ និងរៀបចំក្នុងលក្ខខណ្ឌប្រសើរបំផុតនៃសន្តិសុខ។ ការចាត់ចែងការងារបច្ចេកទេសដែលប្រើប្រាស់សម្ភារឧបករណ៍តូចធំ ម៉ាស៊ីន ឬ ផលិតផលប្រើប្រាស់រួច ត្រូវទុកដាក់ឱ្យបានល្អ ដើម្បីធានាសន្តិសុខរបស់កម្មករនិយោជិត។

ប្រកាសដែលមានចែងក្នុងមាត្រា ២២៩ ក៏កំណត់ផងដែរនូវវិធានការសម្រាប់អនុវត្តមាត្រានេះ ពិសេសដែលពាក់ព័ន្ធដល់ ៖

- ហានិភ័យនៃការជ្រុះធ្លាក់
- ការប្តូរទីតាំងនៃវត្ថុធ្ងន់ៗ
- ការការពារម៉ាស៊ីន និងបរិស្ថានដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់
- វិធានការការពារដែលត្រូវចាត់ចែងឱ្យមានក្នុងករណីធ្វើការងារក្នុងកន្លែងចង្អៀត ឬ ស្ថានភាពការងារដាច់តែឯង
- ហានិភ័យនៃការហៀរចេញវត្ថុរាវ
- ការការពារអគ្គិភ័យ។

មាត្រា ២៣៨ ៖ សហគ្រាស និងគ្រឹះស្ថានដែលចង្អុលក្នុងមាត្រា១ នៃច្បាប់នេះត្រូវរៀបចំឱ្យមានការព្យាបាលបឋមសម្រាប់កម្មករនិយោជិតរបស់ខ្លួន។

មាត្រា ២៣៩ ៖ ក្រុមពេទ្យការងារត្រូវដឹកនាំដោយលោកគ្រូពេទ្យម្នាក់ ឬ ច្រើននាក់ដោយមាននាមជាគ្រូពេទ្យការងារដែលមានការកិច្ចការពារព្យាបាល កុំឱ្យខូចសុខភាពអ្នកធ្វើការដែលបណ្តាលមកពីការងាររបស់ពួកគេ ពិសេសឃ្លាំមើលលក្ខខណ្ឌអនាម័យការងារ គ្រោះថ្នាក់នៃជំងឺឆ្លង និងស្ថានភាពសុខភាពអ្នកជំងឺ។ សំណុំរឿងសុខភាពរបស់កម្មករនិយោជិត ដែលបុគ្គលិកពេទ្យការងារប្រមូលបាន គឺជាឯកសារសម្ងាត់ ហើយព័ត៌មានក្នុងសំណុំរឿងនេះ មិនអាចផ្តល់ឱ្យសហជីព ឬ តតិយជនណាមួយ ដើម្បីធ្វើការកត់សំគាល់លើកម្មករនិយោជិតបានទេ។ ក្នុងគោលបំណងសិក្សាស្រាវជ្រាវអំពីសុខភាពការងារ ឬ អំពីសុខភាពសាធារណៈ បម្រាមនេះមិនជាឧបសគ្គទេ ចំពោះការប្រើប្រាស់ទិន្នន័យ ដោយមិនបញ្ចេញឈ្មោះសាមីជន។ បទប្បញ្ញត្តិនៃកថាខណ្ឌខាងលើ មិនជំទាស់ដល់ការផ្តល់ព័ត៌មានឯកសារទាំងនោះដល់អធិការពេទ្យការងារ ឬ អធិការការងារដែលអាចពិនិត្យមើលនៅគ្រប់ពេលវេលាតាមការស្នើសុំ។

មាត្រា ២៤០ ៖ ក្រុមពេទ្យការងារ អាចមានជាពិសេសសម្រាប់សហគ្រាសនីមួយៗ ឬ មានក្រុមពេទ្យការងារមួយសម្រាប់សហគ្រាសច្រើន ប្រើប្រាស់រួមគ្នាតាមសារសំខាន់នៃសហគ្រាស។ សោហ៊ុយចំណាយក្នុងការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមពេទ្យការងារ ត្រូវនៅលើបន្ទុកនិយោជក។ ក្នុងករណីដែលក្រុមពេទ្យមួយបម្រើសហគ្រាសច្រើននោះ សោហ៊ុយត្រូវចេញតាមសមាមាត្រ នៃចំនួនកម្មករនិយោជិតក្នុងសហគ្រាសនីមួយៗ។

មាត្រា ២៤២ ៖ សហគ្រាស និងគ្រឹះស្ថានទាំងអស់ដែលមានចង្អុលក្នុងមាត្រា ២៣៨ នៃច្បាប់នេះ ហើយដែលមានប្រើកម្មករនិយោជិតយ៉ាងតិច ៥០ នាក់ ត្រូវតែមានក្នុងបរិវេណនៃគ្រឹះស្ថាន រោងជាង ឬ ការដ្ឋាននូវគិលានដ្ឋានអចិន្ត្រៃយ៍មួយ។ គិលានដ្ឋាននេះ ត្រូវមានពេទ្យកាន់កាប់ផ្ទាល់ ដោយមានគិលានុប្បដ្ឋាករ ឬ គិលានុប្បដ្ឋាយិការម្នាក់ ឬ ច្រើននាក់ជួយធ្វើការផង គិតទៅតាមចំនួនកម្មករនិយោជិត។ ក្នុងម៉ោងធ្វើការ ទាំងថ្ងៃទាំងយប់ ត្រូវមានគិលានុប្បដ្ឋាករ ឬ គិលានុប្បដ្ឋាយិការយ៉ាងតិចម្នាក់ នៅយាមប្រចាំការជាអចិន្ត្រៃយ៍។ គិលានដ្ឋានត្រូវមាន

សម្ភារ វត្ថុរំបុរបួស និងឱសថគ្រប់គ្រាន់ដើម្បីព្យាបាលកម្មករនិយោជិតជាបន្ទាន់ក្នុងករណីមានគ្រោះថ្នាក់ ឬមានជំងឺដែលបណ្តាលមកពីការងារ ឬ មានជំងឺក្នុងឱកាសធ្វើការងារនេះ។ សោហ៊ុយក្នុងការរៀបចំ និងការប្រព្រឹត្តទៅនៃគិលានដ្ឋាននេះត្រូវនៅក្នុងបន្ទុកនិយោជក។

មាត្រា ២៤៨ ៖ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬ ក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករនិយោជិត ឬ គ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬ នាយកសហគ្រាស ឬ ធ្លាក់លើសិស្សវិជ្ជាជីវៈ មានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ។ ម្យ៉ាងទៀតត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួន ធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬ វិលមកវិញដោយគ្មានឈប់ ឬ ដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬ ក្រៅពីការងារដែលគេតម្រូវឱ្យទៅ។ ជំងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានបញ្ជាក់ក្នុងច្បាប់ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ហើយទទួលការជួសជុលដូចគ្នាដែរ។

មាត្រា ២៥០ ៖ នាយកសហគ្រាសគ្រប់រូបត្រូវចាត់ ឬ ប្រើឱ្យគេចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបង្ការគ្រោះថ្នាក់ការងារផ្សេងៗ។

មាត្រា ២៥២ ៖ អ្នករងគ្រោះ ឬ អ្នកសិទ្ធិវន្ត មានសិទ្ធិត្រូវបានទទួលប្រាក់បំណាច់អំពីនាយកសហគ្រាស ឬ និយោជក ក្នុងករណីដែលមានគ្រោះថ្នាក់ការងារធ្លាក់លើខ្លួនបណ្តាលឱ្យអាក់ខានធ្វើការមិនកើតមួយរយៈពេល ប៉ុន្តែប្រាក់បំណាច់នេះអាចបានតែក្នុងលក្ខខណ្ឌដែលគ្រោះថ្នាក់នោះបណ្តាលឱ្យខានធ្វើការ លើសពីបួនថ្ងៃទៅ។ បើគ្រោះថ្នាក់ការងារបណ្តាលឱ្យអាក់ខានធ្វើការមិនកើត ក្នុងរយៈពេលបួនថ្ងៃ ឬ តិចជាងនេះអ្នករងគ្រោះត្រូវបានទទួលប្រាក់ឈ្នួលធម្មតា។ អ្នករងគ្រោះដែលបានបង្កគ្រោះថ្នាក់ដោយចេតនាខ្លួនឯង មិនត្រូវបានប្រាក់បំណាច់អ្វីទេ។ តុលាការមានសមត្ថកិច្ចអាច ៖ (១). បន្ថយប្រាក់បំណាច់សម្រាប់ជួសជុលនេះបាន កាលណារកឃើញថាគ្រោះថ្នាក់បណ្តាលមកពីកំហុសធ្ងន់នៃអ្នករងគ្រោះ។ (២). បន្ថែមប្រាក់បំណាច់នេះបាន កាលណាគេរកឃើញថាគ្រោះថ្នាក់បណ្តាលមកពីកំហុសធ្ងន់នៃនិយោជក ឬ អ្នកជំនួសជននេះក្នុងកិច្ចដឹកនាំការងារ។

មាត្រា ២៥៣ ៖ ក្នុងករណីដែលមានគ្រោះថ្នាក់ដល់ស្លាប់ ឬ គ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ ប្រាក់បំណាច់ត្រូវបើកឱ្យអ្នករងគ្រោះ ឬ អ្នកសិទ្ធិវន្តជាធនលាភ។ ត្រូវឱ្យប្រាក់បំណាច់បន្ថែម ដល់អ្នករងគ្រោះថ្នាក់ណាដែលតម្រូវឱ្យមានមនុស្សដទៃម្នាក់នៅថែទាំខ្លួនជានិច្ច។ ក្នុងករណីធ្វើការមិនកើតប្រាក់បំណាច់នេះត្រូវបើកឱ្យយ៉ាងយូណាស់ នៅថ្ងៃទីប្រាំ ក្រោយពីគ្រោះថ្នាក់។

៣.២.៤. ច្បាប់ភូមិបាល ឆ្នាំ២០០១

ច្បាប់ភូមិបាល ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហាឆ្នាំ២០០១។ ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣ ៖ ជនគ្រប់រូបត្រូវគោរពតាមទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បទ

បញ្ញា និងនីតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនឹងត្រូវកំណត់ដោយអនុក្រឹត្យ [អនុក្រឹត្យស្តីលេខ ១១៨]។

មាត្រា ១៥ ៖ រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ៖

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវា ឬ ក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេ ដែលនាវា ឬ ក្បូនចេញចូលបាន បណ្តែតបាន និងត្រើយសមុទ្រ។
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅដូចជា តឹរហានកំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ។
- ទ្រព្យទាំងឡាយណាដែលត្រូវបានដាក់ឱ្យប្រើជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណី។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈដូចជា សាលារៀន ឬ អគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ។
- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិការពារដោយច្បាប់។
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។ អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។

មាត្រា ១៦ ៖ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះមិនអាចកំណត់អាជ្ញាយុកាលបានទេ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចបិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេសនៃជំពូកទី៤ នៃច្បាប់នេះ (អំពីការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុតាមលទ្ធកម្មពិសេសនៃកោគៈ) បានទេ ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋអាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ ឬ ប្រើប្រាស់ជា បណ្តោះអាសន្នមិនទៀង ហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាមជំពូក៣ នៃច្បាប់នេះ(អំពីកម្មសិទ្ធិរបស់សមូហភាព)។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬ ជាសិទ្ធិកណ្តាលជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនោះបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវបាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុបយោគ។

មាត្រា ១៧ ៖ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ អាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬ ការផ្ទេរសិទ្ធិតាមការកំណត់ដោយច្បាប់។ ទ្រព្យទាំងនោះអាចផ្តល់ឱ្យតាមរយៈកតិសន្យា និងជាកម្មវត្ថុនៃកិច្ចសន្យា ដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់។ លក្ខខណ្ឌទាំងឡាយ និងនីតិវិធីនៃការលក់ និងការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈនឹងកំណត់ដោយអនុក្រឹត្យ។ គ្មានការលក់ណាមួយអាចត្រូវបានសម្រេចដោយគ្មានអនុក្រឹត្យនេះឡើយ។ ដីជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុនៃសម្បទានក្នុងលក្ខខណ្ឌដែលមានចែងក្នុងជំពូកទី៥ នៃច្បាប់នេះ (អំពីសម្បទានដី)។ គ្មានការចាប់យកដីតាមទំនើងចិត្តណាមួយអាចកើតឡើងទៅលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬ របស់នីតិបុគ្គលសាធារណៈបានឡើយ

ចាប់ពីច្បាប់នេះចូលជាធរមាន ទោះបីស្របនឹងជំពូកទី៤ នៃច្បាប់នេះក៏ដោយ (អំពីការការបង្កើតឡើងវិញនូវកម្ម សិទ្ធិលើអចលនវត្ថុតាមលទ្ធកម្មពិសេសនៃកោគៈ)។

មាត្រា ២៣ ៖ សហគមន៍ជនជាតិភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រ កម្ពុ ជាដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាម ប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជា សមូហភាព។

ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែង មកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណីហើយត្រូវអនុវត្តតាមបញ្ញត្តិ នៃច្បាប់នេះ។

មាត្រា ២៤ ៖ ចាត់ទុកជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចដែលអាចទទួលគុណប្រយោជន៍ពី ការធានាសិទ្ធិនិងការពារដែលរៀបចំឡើងដោយច្បាប់នេះ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិ ពន្ធុ អំពីវប្បធម៌ និងសង្គមរបស់សហគមន៍ដែលទទួលស្គាល់ដោយមតិភាគច្រើននៃសមាជិកដទៃទៀតនឹងដោយ ព្រមទទួលនូវសោមគ្គីភាព និងភាពចំណុះដែលនាំឱ្យមានការចូលក្នុងសហគមន៍ ។

មាត្រា ២៥ ៖ ដីសហគមន៍ជនជាតិដើមភាគតិចគឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពីណី ។

ដីសហគមន៍ជនជាតិភាគតិចមិនមែនមានតែដីបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបម្រុងចាំបាច់ក្នុង ការដូរវេនដំណាំថែមទៀតដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួល ស្គាល់ដោយអាជ្ញាធររដ្ឋបាល ។

ការវាស់វែង និងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះត្រូវកំណត់ទៅតាមស្ថានភាព ជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ដោយមានការព្រមព្រៀងពីអ្នកជិតខាងនិងដែលបានកំណត់តាម នីតិវិធីក្នុងមាតិកាទី ៦ នៃច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ។

មាត្រា ២៦ ៖ កម្មសិទ្ធិនៃអចលនវត្ថុដែលបានចែកក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធដូចកម្ម សិទ្ធិឯកជនដែរ។ ប៉ុន្តែសហគមន៍នោះគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យ សម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅបុគ្គល ឬ ក្រុមណាមួយបានឡើយ។

ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់ពួកគេហើយត្រូវដាក់ឱ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅទាក់ទងនឹងអចលនវត្ថុ ដូចជាច្បាប់ការពារបរិស្ថានជាដើម។

បញ្ញត្តិនៃមាត្រានេះមិនមែនជាឧបសគ្គដល់សកម្មភាពការងាររបស់រដ្ឋដែលជាតម្រូវការនៃផលប្រយោជន៍ ជាតិ ឬ តម្រូវការជាបន្ទាន់របស់ជាតិឡើយ។

មាត្រា ២៧ ៖ ដើម្បីសម្រួលការវិវត្តន៍វប្បធម៌ សេដ្ឋកិច្ច និងសង្គមនៃសមាជិកសហគមន៍ជនជាតិដើមភាគ តិច និងដើម្បីអនុញ្ញាតឱ្យពួកគេបានចេញដោយសេរីពីសហគមន៍ ឬ រួចផុតពីការបង្កិតបង្ខំសិទ្ធិនៃកម្មសិទ្ធឯកជន អាចនឹងត្រូវផ្ទេរជាពិសេសឱ្យពួកគេបានលើចំណែកសមស្របមួយនៃដីដែលប្រើដោយសគមន៍ ប៉ុន្តែចំណែកនៃដី

ដែលជាកម្មវត្ថុនៃការយកធ្វើជាកម្មសិទ្ធិឯកជននោះ មិនអាចជាដីដែលចូលក្នុងនិយមន័យទូទៅនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទេ។

មាត្រា ៣០ ៖ បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥(ប្រាំ) ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាស់ឱ្យប្រើច្បាប់នេះលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្តាពរ។

ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្តាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំ នៅលើអចលនវត្ថុដែលមានទំនាស់ ឬ យកភស្តុតាងដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភោគីដើម ឬ ពីសិទ្ធិវន្តស្របច្បាប់ ឬ អ្នកទទួលផ្ទេរកម្មសិទ្ធិ ឬ ពីសន្តតិជនរបស់ខ្លួន។

មាត្រា ៣១ ៖ បុគ្គលដែលបានអាស្រ័យផលនៃភោគៈកន្លងមក គិតមកដល់កាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ប្រសិនបើបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌទាំងឡាយក្នុងការក្លាយទៅជាកម្មសិទ្ធិករ អាចត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចឱ្យបន្តែមរយៈពេលកាន់កាប់ភោគៈរបស់ខ្លួនរហូតគ្រប់រយៈពេលស្របច្បាប់ ៥ (ប្រាំ) ឆ្នាំ និងមានប័ណ្ណកម្មសិទ្ធិស្តាពរ ។ ការអនុញ្ញាតឱ្យបន្តរយៈពេលមិនអាចត្រូវបានបដិសេធដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ ប្រសិនបើភោគៈបានមកដោយសន្តិវិធីនិងមិនមានការជំទាស់ ។

អាជ្ញាធរមានសមត្ថកិច្ចដែលបដិសេធដោយរំលោកនូវការអនុញ្ញាតឱ្យបន្តរយៈពេល ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះមុខច្បាប់ ។ការទទួលស្គាល់ដោយរំលោកដោយអាជ្ញាធរមានសមត្ថកិច្ចនូវភោគៈដែលមិនបំពេញលក្ខខណ្ឌនៃច្បាប់ ត្រូវចាត់ទុកជាមោឃៈនិងគ្មានអានុភាព។ អាជ្ញាធរដែលបានទទួលស្គាល់ដោយរំលោកនេះត្រូវទទួលខុសត្រូវដោយផ្ទាល់ខ្លួនចំពោះមុខច្បាប់។

មាត្រា ៣២ ៖ អចលនវត្ថុទាំងឡាយដែលមិនអាចក្លាយទៅជាកម្មសិទ្ធិនៃអ្នកកាន់កាប់ស្របតាមច្បាប់នេះក្នុងករណីភោគីបំពេញមិនបាននូវលក្ខខណ្ឌនៃច្បាប់ដោយហេតុមកពីលក្ខណៈសម្បត្តិរបស់ខ្លួនជាភោគីកេងបន្លំ ឬ ដោយឥរិយាបទរបស់ខ្លួនជាភោគីដែលលួចលាក់នឹងច្បាប់ ឬ ដែលមិនចេញមុខ ឬ ជាភោគីដោយប្រើហឹង្សា។ អចលនវត្ថុនោះត្រូវទុកជាសម្បត្តិរដ្ឋ ហើយមិនអាចឱ្យជនណាចូលកាន់កាប់ជាភោគីថ្មីសម្រាប់លទ្ធកម្មនៃសិទ្ធិក្នុងលក្ខខណ្ឌនៃជំពូកនេះបានឡើយ។

មាត្រា ៣៣ ៖ ក្នុងករណីមានការដកហូតអចលនវត្ថុដោយហិង្សា ឬ ដោយប្រើអំណាចរំលោករបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវបានបង្វិលមករដ្ឋវិញហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយប្រសិនបើគ្មានបណ្តឹងទាមទារពីភោគីស្របច្បាប់នៃអចលនវត្ថុដែលត្រូវបានដកហូត ។ បណ្តឹងទាមទារនេះមានរយៈពេល ៣ (បី) ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត។

មាត្រា ៤៨ ៖ សម្បទានដីជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្តចេញដោយអាជ្ញាធរមានសមត្ថកិច្ចតាមអំណាចឆន្ទានុសិទ្ធិឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ឬ ក្រុមមនុស្សដើម្បីកាន់កាប់ដី និងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់នេះ។

មាត្រា ៤៩ ៖ សម្បទានដីត្រូវឆ្លើយតបទៅនឹងប្រយោជន៍សង្គម ឬ ទៅនឹងប្រយោជន៍សេដ្ឋកិច្ច។ សម្បទានដី ឆ្លើយតបទៅនឹងប្រយោជន៍សង្គម អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍រៀបចំដីដើម្បីសង់លំនៅដ្ឋាន ឬ/និងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋដើម្បីជានាការចិញ្ចឹមជីវិត។ សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍

សេដ្ឋកិច្ច អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍កាន់កាប់ឆ្ការទាញយកផលដោយធ្វើអាជីវកម្ម កសិ-ឧស្សាហកម្មលើដីនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៥៦ ៖ សិទ្ធិរបស់សម្បទានិកលើដីដែលបានផ្តល់ជាសម្បទានក្នុងកំឡុងពេលនៃសម្បទានគឺជាសិទ្ធិដែលទទួលស្គាល់ដូចជាកម្មសិទ្ធិករ លើកលែងតែការផ្ទេរសិទ្ធិ។ សម្បទានិកមានសិទ្ធិពិសេសក្នុងការការពារស្ថានភាពរបស់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច។ សម្បទានិកអាចការពារដីដែលបានផ្តល់ឱ្យខ្លួនចំពោះការទន្ទ្រាន ឬការប៉ះពាល់ទោះជាតាមរូបភាពណាក៏ដោយ។ សម្បទានិកអាចទាញយកនូវផលិតផលពីដីរបស់ខ្លួនធ្វើការរៀបចំដាំដុះស្របតាមគោលបំណងនៃសម្បទាន។ សម្បទានិកមិនអាចកែប្រែគោលបំណងនៃសម្បទានធ្វើឱ្យប៉ះពាល់ដល់រចនាសម្ព័ន្ធធម្មជាតិ និងធ្វើអាជីវកម្មដែលមានលក្ខណៈជាការបំផ្លាញនៅចុងបញ្ចប់នៃសម្បទានបានឡើយ។

មាត្រា ៥៨ ៖ សម្បទានដីអាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ សម្បទានដីមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សម្រាប់ថែទាំ ក៏ដូចជាផ្លូវទឹក ត្រពាំង បឹង និងដែនទឹកបម្រុងដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ។

មាត្រា ៦២ ៖ រាល់សម្បទានដីសម្រាប់ដំណាំឧស្សាហកម្ម ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីការផ្តល់សម្បទាន បើមិនដូច្នោះទេនឹងត្រូវទុកជាមោឃៈ។ ការខកខានធ្វើអាជីវកម្មរយៈពេលលើសពី១២(ដប់ពីរ)ខែ នាំឱ្យមានមោឃភាពសម្បទាន ប្រសិនបើការខកខាននោះពុំមានមូលហេតុត្រឹមត្រូវ។ រាល់សម្បទានដីដែលបានផ្តល់ឱ្យមុនច្បាប់នេះចូលជាធរមាន ហើយមិនបានធ្វើអាជីវកម្មចាប់ពី១២(ដប់ពីរ)ខែឡើងទៅគិតពីថ្ងៃដែលច្បាប់នេះចូលជាធរមានត្រូវទុកជាមោឃៈ ប្រសិនបើការខកខានមិនបានធ្វើអាជីវកម្មនោះពុំមានមូលហេតុត្រឹមត្រូវ។ រាល់ការមិនបានបំពេញកិច្ចតាមសៀវភៅបន្ទុកដោយសម្បទានិក នាំឱ្យមានការដកហូតសម្បទាន។ ក្នុងករណីនៃការដកហូតសម្បទាន ទោះជាមានមូលហេតុអ្វីក៏ដោយ សម្បទានិកគ្មានសិទ្ធិទាមសំណងនៃការខូចខាតណាមួយឡើយ។

៣.២.៥. ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ២០០១

ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១។ ខ្លឹមសារសំខាន់ៗដែលទាក់ទងនឹងច្បាប់នេះមានដូចខាងក្រោម ៖

មាត្រា ១ ៖ ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រតិបត្តិប្រេងកាត និងឧស្ម័នត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក។

មាត្រា ២ ៖ ធនធានរ៉ែទាំងអស់ដែលស្ថិតនៅក្នុងដី លើដី ឬ ក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោមបាតសមុទ្រក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាសម្បត្តិរដ្ឋ។

មាត្រា ៥ ៖ គ្មានរូបវន្តបុគ្គល ឬ នីតិបុគ្គលណាអាចធ្វើការស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ដែលចេញឱ្យដោយស្ថាប័នមានសមត្ថកិច្ចឡើយ លើកលែងតែម្ចាស់កម្មសិទ្ធិ ឬ អ្នកកាន់កាប់ស្របច្បាប់លើដីធ្លីដែលជាឯកជនអាចប្រើប្រាស់ក្រួស ខ្សាច់ ឬ ដីឥដ្ឋ ដោយមិនចាំបាច់មានអាជ្ញាប័ណ្ណ តែមិនអនុញ្ញាតឱ្យដឹកជញ្ជូនចេញផុតពីព្រំដីធ្វើជាកម្មសិទ្ធិដើម្បីធ្វើអាជីវកម្មនោះទេ។ ប្រជាពលរដ្ឋខ្មែរអាចធ្វើបុរេសនានៅលើដីរបស់រដ្ឋ ឱ្យតែដីនោះរដ្ឋមិនទាន់ចេញអាជ្ញាប័ណ្ណធនធានរ៉ែទៅបុគ្គលដទៃ។

៣.២.៦. ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២

ច្បាប់ស្តីពីព្រៃឈើ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម លេខ នស/រកម/០៨០២/ ០១៦ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២។

មាត្រា ១ ៖ ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះគឺជានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌។

មាត្រា ២ ៖ ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬ ដោយដាំក្តី។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផែល-អនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀត។

មាត្រា ៣ ៖ ការគ្រប់គ្រងព្រៃឈើ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក។ រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដោយព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើ ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី១៤ នៃច្បាប់នេះ។ សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

មាត្រា ៤ ៖ ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។ សកម្មភាពចម្បង។ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។ រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បង។ ពាក់ព័ន្ធនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម។ ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ។

មាត្រា ១០ ៖ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន ៖

១. ព្រៃបម្រុងទុកអចិន្ត្រៃយ៍។

២. ព្រៃឯកជន។

ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមាន បី (០៣) ប្រភេទ ៖

១- ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផល-អនុផលព្រៃឈើប្រកបដោយនិរន្តរភាពដែលក្នុងនោះ មុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់។ ព្រៃផ្តល់ផលមានជាអាទិ៍ ៖

- ព្រៃសម្បទាន
- ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន
- ព្រៃត្រូវស្តារឡើងវិញ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ដាំដើមឈើឡើងវិញ ឬ ចម្ការព្រៃឈើ
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់បន្តពូជព្រៃឈើ
- ផ្ទៃដីព្រៃរេចរិល
- ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង។

២- ព្រៃការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ។ ព្រៃការពារមានជាអាទិ៍ ៖

- ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស
- ព្រៃសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃនិយតកម្មប្រភពទឹក
- ព្រៃការពារទីជម្រាល
- ព្រៃលំហែកំសាន្ត
- សួនកូតគាម
- ព្រៃជំនឿសាសនា

ព្រៃការពារទាំងនេះអាចអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណី ដែលមានផលប៉ះពាល់ទាបដោយសហគមន៍មូលដ្ឋាន។

៣- ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិព្រៃបន្ទាប់បន្សំដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយត្រូវតែជាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍសម្រាប់គោលបំណងផ្សេងទៀត ដោយរាជរដ្ឋាភិបាល។

ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍ និងប្រមូលផលប្រើប្រាស់ លក់ចែកចាយផលិតផលរបស់ខ្លួនដោយផ្ទាល់។

មាត្រា ៣៧ ៖ សហគមន៍មូលដ្ឋានដែលប្រកបរបរចម្ការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីការរួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្តន៍ចម្ការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ប៉ះពាល់ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។

ដីព្រៃដែលរៀបចំបម្រុងសម្រាប់ចម្ការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៤០ ៖ ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬ ក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននោះសម្រាប់គោលបំណងទំនៀមទម្លាប់ ជំនឿសាសនា និងការរស់នៅដូចមានចែងក្នុងមាត្រានេះ។

សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល អនុផលព្រៃឈើដោយសហគមន៍មូលដ្ឋានមិនតម្រូវឱ្យមានលិខិតអនុញ្ញាតប្រមូលផលឡើយ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីក្រោមមាត្រានេះ រួមមាន ៖

១- ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការរុករកឃ្មុំ ការចោះយកជ័រ និងរុករកអនុផលព្រៃឈើដទៃទៀតទាំងអស់។

២- ការប្រើប្រាស់ឈើមកសង់លំនៅដ្ឋាន ក្រោលសត្វ របង និងសម្រាប់ធ្វើឧបករណ៍កសិកម្ម។

៣- ការច្រូតយកស្មៅ ឬ លែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ។

៤- ការប្រើប្រាស់ផល អនុផលព្រៃឈើផ្សេងទៀតស្របតាមការប្រើប្រាស់ជាប្រពៃណី ជាលក្ខណៈគ្រួសារ។

៥- សិទ្ធិដោះដូរ ឬ លក់អនុផលព្រៃឈើដោយពុំចាំបាច់មានលិខិតអនុញ្ញាត ប្រសិនបើការលក់ដូរនេះមិនគំរាមកំហែងដល់និរន្តរភាពនៃព្រៃឈើ។ អតិថិជន ឬ ភាគីទីបីណាមួយដែលបានប្រមូលទិញអនុផលព្រៃឈើទាំងនោះពីសហគមន៍មូលដ្ឋានក្នុងគោលបំណងពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អាចធ្វើការដឹកជញ្ជូនទៅកាន់ទិសដៅបានដោយតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូន ក្រោយពេលបានបង់ថ្លៃសួយសារ និងបុព្វលាភលើអនុផលព្រៃឈើទាំងនោះរួច។

សហគមន៍មូលដ្ឋានមិនអាចផ្ទេរសិទ្ធិប្រើប្រាស់ជាប្រពៃណីឱ្យទៅភាគីទីបីបានឡើយ ទោះបីជាមានកិច្ចព្រមព្រៀងទៅវិញទៅមកក្តី ឬ ស្ថិតក្រោមកិច្ចសន្យាក្តី។ សិទ្ធិប្រើប្រាស់ជាប្រពៃណីត្រូវ ៖

១- ស្របតាមលំនឹងធម្មជាតិ មាននិរន្តរភាពចំពោះធនធានព្រៃឈើ និងគោរពសិទ្ធិអ្នកដទៃ។

២- ស្របតាមការអនុញ្ញាត និងការហាមឃាត់ ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះ។

មាត្រា ៤៥ ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលស្គាល់ព្រៃពាក់ព័ន្ធជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬ ក្បែរព្រៃនោះ ទុកជាព្រៃការពារសម្រាប់គោលបំណងសាសនា វប្បធម៌ ឬ ការអភិរក្ស។ ដើមឈើជំនឿសាសនាអាចត្រូវបានដៅសម្គាល់ជាពិសេសមិនអនុញ្ញាតឱ្យកាប់រំលំ និងត្រូវកំណត់ក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍។

មាត្រា ៤៩ ៖ ហាមឃាត់ដាច់ខាតរាល់សកម្មភាពបរបាញ់ យាយីបំផ្លិចបំផ្លាញសត្វព្រៃគ្រប់ប្រភេទដោយ ៖

១- ការប្រើប្រាស់មធ្យោបាយបង្កគ្រោះថ្នាក់គ្រប់ប្រភេទ។

២- ការប្រមាញ់ក្នុងរដូវកាលហាមឃាត់។

៣- ការប្រមាញ់ក្នុងតំបន់ការពារ និងទីសាធារណៈពិសេស។

ដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតអនុញ្ញាតចំពោះប្រភេទសត្វក្នុងប្រភេទជិតផុត និងក្រុមប្រភេទមានដោយកម្រ សម្រាប់គោលបំណងដូចខាងក្រោម ៖

១- ការសិក្សាអប់រំ ឬ ការស្រាវជ្រាវវិទ្យាសាស្ត្រ។

២- ការគាំទ្រដល់កម្មវិធីនៃការចាប់បង្កាត់ពូជ។

៣- ការផ្លាស់ប្តូងប្រភេទសត្វ អនុលោមតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិ។

រាល់ការធ្វើសកម្មភាពដូចខាងក្រោម ចំពោះប្រភេទសត្វក្នុងក្រុមប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រត្រូវហាមឃាត់ ៖

១- ការយាយី ឬ បំផ្លិចបំផ្លាញដល់ប្រភេទសត្វខាងលើ និងជម្រករបស់ប្រភេទសត្វទាំងនេះ។

២- ការបរបាញ់ ទាក់ចាប់ ដាក់អង្គុប បំពុល។

៣- ការយកធ្វើជាកម្មសិទ្ធិ សន្និធី ឬ ថៃរក្សាជាំលក្ខណៈសួនសត្វ ឬ គ្រួសារ។

៤- ការដឹកជញ្ជូន។

៥- ការធ្វើពាណិជ្ជកម្ម។

៦- ការនាំចេញ នាំចូល។

វិធានការនៃការធ្វើសកម្មភាពចំពោះសត្វព្រៃគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។

៣.២.៧. ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៤) និង ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (២០០៣)

ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័តឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ០៣ ន.ស.៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤។ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០០៣។

មាត្រា ១ ៖ ច្បាប់នេះ មានវិសាលភាពចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលធ្វើឡើងដោយបុគ្គលណាមួយ។ មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ។

មាត្រា ២ ៖ ក្នុងន័យនៃច្បាប់នេះ វាក្យសព្ទដូចខាងក្រោម ៖

- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហៅកាត់គ.ល.គ មានន័យថា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។
- វិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ៧ មាត្រា៧នៃច្បាប់នេះ។

មាត្រា ៧ ៖ ...ក្នុងរយៈពេល ២៨ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។ ការចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ មិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួចផុតពីការទទួលនូវលិខិតអនុញ្ញាតនានាដែលក្រសួងស្ថាប័នមានសមត្ថកិច្ចបានកំណត់ឡើយ។ ទោះបីផុតរយៈពេល ២៨ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌ៦ ខាងលើក៏ដោយ រាល់ស្ថាប័នមានសមត្ថកិច្ចត្រូវតែចេញលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានា។ កាលបរិច្ឆេទនៃការចេញជូននូវវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ គឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

មាត្រា ១២ ៖ រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដែលមានចែងក្នុងជំពូកនេះ ដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

មាត្រា ១៣ ៖ ការលើកទឹកចិត្តមាន ការលើកលែងទាំងស្រុង ឬ មួយផ្នែកនៃពន្ធគយ និងពន្ធអាករ។

៣.២.៨. ច្បាប់ស្តីពីជលផល ឆ្នាំ២០០៦

ច្បាប់ស្តីពីជលផល ត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយផ្លូវការតាមព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។ ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ដំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២ ៖ ច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិ ទាំងជលផលកែច្នៃ និងទាំងវារីវប្បកម្ម។ រដ្ឋធានាសិទ្ធិប្រើប្រាស់ធនធានជលផលជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្រោមបទបញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀត។

មាត្រា ៣ ៖ ការគ្រប់គ្រងជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹក និងព្រៃកោងកាងដែលពាក់ព័ន្ធនឹងវដ្តជីវិតនៃធនធានជលផល ត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ។ រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ចំពោះរាល់បទល្មើសជលផលដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថានស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី១៤ នៃច្បាប់នេះ។ សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

មាត្រា ៨ ៖ ដែននេសាទរួមមាន ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរនាចនៃសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទ និងការការពារប្រព័ន្ធអេកូឡូស៊ីជលផល។ ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ។ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្តៅ វាលភក់ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវដំឡើង និងនាទីព្រៃលិចទឹក។ ដែនដីដែលទទួលរបបទឹកជោរនាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោងកាង។

មាត្រា ១៨ ៖ តំបន់គ្រប់គ្រងជលផល ជាអាទិ៍ តំបន់ទឹកជ្រៅ អន្លង់ជ្រៅៗនៅតាមដងទន្លេ បឹងទន្លេសាបបឹង ព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផល ត្រូវរៀបចំចាត់ថ្នាក់ជាកន្លែងការពារ និងអភិរក្សធនធានជលផល។

មាត្រា ១៩ ៖ ហាមឃាត់ ៖

១- ការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងកន្លែងអភិរក្សជលផល លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់រដ្ឋបាលជលផលធ្វើការពិសោធន៍ស្រាវជ្រាវបច្ចេកវិទ្យាសាស្ត្រជលផល

២- ការធ្វើនាវាចរឆ្លងកាត់ ឬ ធ្វើសកម្មភាពផ្សេងទៀតក្នុងកន្លែងអភិរក្សជលផល លើកលែងតែមន្ត្រីមានសមត្ថកិច្ចនៅពេលដែលចាំបាច់ក្នុងការអនុវត្តច្បាប់ និង

៣- ការតាំងទីលំនៅថ្មីដែលស្ថិតនៅតិចជាងពីរ(២)គីឡូម៉ែត្រពីព្រំប្រទល់កន្លែងអភិរក្សជលផល លើកលែងតែទីលំនៅរបស់រដ្ឋបាលជលផលដែលប្រើសម្រាប់គោលបំណងអនុវត្តច្បាប់។

មាត្រា ២០ ៖ ហាមឃាត់ដាច់ខាតចំពោះការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទ ដោយប្រើឧបករណ៍ ផ្សេងៗដែលបង្កមហន្តរាយដល់ធនធានជលផលដូចជា ឧបករណ៍ឆក់ គ្រឿងផ្ទុះ សារធាតុពុលគ្រប់ប្រភេទ ឧបករណ៍បូម បាច ពង្រីង ជាដើម។

មាត្រា ២២ ៖ ហាមឃាត់ការចាក់ចោល ការបោះចោល ការបង្ហូរ ឬ ការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬ រាវ ឬ សារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬ សន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬ ការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុល ឬ ការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។

មាត្រា ២៥ ៖ ការធ្វើទំនប់កាត់ ឬ ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹង ប្រឡាយ អាងទឹក និងអាងធម្មជាតិ ឬ ការជីកប្រឡាយ រណ្តៅ និងស្រះទ្រង់ទ្រាយធំ ឬ ការសាងសង់សំណង់ថ្មីនានា ឬ ការបូមទឹកដែលអាចបង្កមហន្តរាយដល់ធនធានជលផលនៅក្នុងដែននេសាទ ត្រូវមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នពាក់ព័ន្ធ។

៣.២.៩. ច្បាប់ស្តីពីកិច្ចការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ច្បាប់ស្តីពីកិច្ចការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការតាមព្រះរាជក្រមលេខនស\រកម\០៦០៧\០១៦ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧។ ច្បាប់នេះ មានគោលដៅជំរុញឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះកំណត់ ៖

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
- គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹកក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព

មាត្រា ១១ ៖ បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងទៀត រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះ មិនតម្រូវឱ្យសុំអាជ្ញាប័ណ្ណទឹកឡើយ។

មាត្រា ១២ ៖ ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្មលើសកម្រិតដែលមានចែងក្នុងមាត្រា១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត។ បែបបទនៃការសុំនេះនឹងមានចែងនៅក្នុងអនុក្រឹត្យ។

ការយកខ្សាច់ ដី ថ្ម ក្រួស ប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរសមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក។ បែបបទនៃការសុំនេះនឹងមានចែងនៅក្នុងអនុក្រឹត្យ។

ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹងបួ ប្រឡាយ អាងទឹក នឹងអាងធម្មជាតិ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត។ បែបបទនៃការសុំនេះនឹងមានចែងនៅក្នុងអនុក្រឹត្យ។

ការសាងសង់ស្ពានតូច ធំកាត់ទន្លេ ស្ទឹង កំពង់ផែ ឬ សំណង់អាគារតូចធំលើច្រាំង និងឆ្នេរ តម្រូវឱ្យមានការឯកភាពផ្នែកបច្ចេកទេសជលសាស្ត្រជាមុនពីក្រសួងធនធានទឹក និងឧតុនិយម។

ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

មាត្រា ២២ ៖ រាល់ការបញ្ចេញចោល ការទុកចោល ឬ ការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬ ការ អនុញ្ញាត។ ប្រភេទនៃសារធាតុពុលដែលមានចែងខាងលើ និងបទដ្ឋានបច្ចេកទេសនៃការបញ្ចេញទឹកសំណល់ នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

មាត្រា ២៧ ៖ កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីផ្នែកខាងលើអាចត្រងទឹកទុក ប្រើប្រាស់ទឹកភ្លៀង និងទឹកហូរកាត់លើដីកម្មសិទ្ធិសម្រាប់គោលបំណងដូចមានចែងក្នុងមាត្រា១១នៃច្បាប់នេះ ដោយមិនប៉ះពាល់ដល់ផលប្រយោជន៍អ្នកប្រើប្រាស់ទឹកផ្នែកខាងក្រោម។ កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីផ្នែកខាងក្រោមអាចទទួលត្រងទឹកទុក និងប្រើប្រាស់បាននូវបរិមាណទឹកធម្មជាតិដែលហូរពីដីផ្នែកខាងលើ ក៏ប៉ុន្តែបុគ្គលទាំងនេះគ្មានសិទ្ធិរារាំងចរន្តទឹកដោយការសាងសង់ផ្លូវ ទំនប់តូចធំ ឬ សំណង់ផ្សេងៗទៀតដែលអាចរក្សាទឹកទុកបានឡើយ លើកលែងតែមានការអនុញ្ញាត។ ការខូចខាតណាមួយបណ្តាលមកពីកម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីដែលបានរំលោភទៅនឹងបទប្បញ្ញត្តិនៃមាត្រានេះ ត្រូវចេញសងនូវការខូចខាតនោះ។

មាត្រា ២៨ ៖ កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីកសិកម្ម ត្រូវអនុញ្ញាតឱ្យចរន្តទឹកហូរកាត់លើដីរបស់ខ្លួនតាមលំនាំធម្មជាតិទៅកាន់ដីអ្នកជិតខាង ដើម្បីបំពេញនូវតម្រូវការស្រោចស្រពលើដីកសិកម្ម ឬ តម្រូវការផ្សេងទៀត។

៣.២.១០. ច្បាប់ស្តីពីដីវិសុវត្តិភាព ឆ្នាំ២០០៨

ច្បាប់ស្តីពីដីវិសុវត្តិភាព ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/០២០៨/ ០០៦ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨។ ច្បាប់នេះ មានគោលបំណង ៖

- អនុវត្តគោលការណ៍ប្រុងប្រយ័ត្នស្តីពីដីវិសុវត្តិភាព
- ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សដីវៈចម្រុះនិងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលបណ្តាលមកពីការផលិតការដឹកជញ្ជូនឆ្លងដែនការអភិវឌ្ឍន៍
- ការលើកដាក់ការផ្ទេរការប្រើប្រាស់ការស្តុកទុក និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ដែលបង្កើតឡើងដោយជីវបច្ចេកវិទ្យាទំនើប

- ធានាប្រសិទ្ធភាពនៃការអភិរក្ស និងការប្រើប្រាស់ដីវៈចម្រុះដោយនិរន្តរភាពព្រមទាំងយកចិត្តទុកដាក់ចំពោះហានិភ័យដល់សុខភាពមនុស្ស
- ធ្វើឱ្យមានតម្លាភាពក្នុងនីតិវិធីពិនិត្យ និងក្នុងការធ្វើសេចក្តីសម្រេចចំពោះសារពាង្គកាយកែច្នៃរស់ និងសកម្មភាពទាំងឡាយដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់
- លើកកម្ពស់ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើប សំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថាននិងសុខភាពមនុស្ស។

មាត្រា ២ ៖ ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានអត្ថន័យដូចខាងក្រោម

- **ការប្រើប្រាស់ក្នុងដែនកំណត់** ៖ សំដៅដល់ប្រតិបត្តិការ ឬ សកម្មភាពណាមួយដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ដែលធ្វើឡើងនៅក្នុងទីកន្លែង ឬ មធ្យោបាយ ឬ ឧបករណ៍ណាមួយ ហើយស្ថិតនៅក្រោមវិធានការជាក់លាក់ ដែលទប់ស្កាត់មិនឱ្យសារពាង្គកាយកែច្នៃរស់ទាំងនោះប៉ះពាល់ទៅដល់ បរិស្ថានខាងក្រៅ។
- **ការបញ្ចូលសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថានដោយចេតនា** ៖ សំដៅដល់ការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ដែលបានបញ្ញត្តិក្នុងច្បាប់នេះ ដើម្បីយកទៅដាំ ឬ សាបព្រួសនៅទីស្រែចម្ការ ឬ ដាក់ចូលទៅក្នុងទឹក ឬ បញ្ចេញទៅក្នុងបរិយាកាស ការដាក់លក់នៅទីផ្សារ ការធ្វើអំណោយ ការ ផ្តល់ឱ្យ តែពុំមែនជាសារពាង្គកាយកែច្នៃរស់ប្រើប្រាស់ក្នុងព្រំដែនកំណត់ ឬ នាំចូលសម្រាប់ប្រើប្រាស់ផ្ទាល់ជាមួយម្ហូបអាហារ ឬ ចំណីសត្វ ឬ សម្រាប់ធ្វើការកែច្នៃទៅជាអ្វីផ្សេងទៀតឡើយ។
- **ជីវបច្ចេកវិទ្យាទំនើប** ៖ សំដៅដល់ការអនុវត្តនូវ ៖
  - ក- បច្ចេកទេសអាស៊ីតនុយក្លេអ៊ិកអាំងវីត្រូមានការប្រមូលផ្តុំនូវអាស៊ីតដេអុកស៊ីរីបូនុយក្លេអ៊ិក និងការចាក់អាស៊ីតនុយក្លេអ៊ិកដោយផ្ទាល់ទៅក្នុងកោសិកា ឬ សរីរាង្គ។
  - ខ- ការលាយចូលគ្នានៃកោសិកាដែលមិនមែនគ្រួសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនូវការផលិតឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិ ឬ ជាឧបសគ្គដល់ការផ្តុំបញ្ចូលគ្នាឡើងវិញ ហើយក៏មិនមែនជាបច្ចេកទេសប្រើប្រាស់នៅក្នុងការបង្កាត់ពូជ ឬ ការជ្រើសរើសតាមរបៀបបុរាណ។
- **សារពាង្គកាយកែច្នៃរស់** ៖ សំដៅដល់សារពាង្គកាយរស់ដែលមានផ្ទុកនូវសេនេទិចថ្មី ទទួលយកតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប។
- **សារពាង្គកាយរស់** ៖ សំដៅដល់អង្គជីវៈចម្រុះទាំងឡាយណាដែលមានសមត្ថភាពក្នុងការផ្ទេរ ឬ ផលិតឡើងវិញនូវសារធាតុសេនេទិច រួមទាំងសារពាង្គកាយដែលមិនអាចបន្តពូជបាន វីរុស និងវីរ៉ូអ៊ីត។

មាត្រា ៤៖ រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានផ្តល់ដំណឹងថាមានបំណងធ្វើសកម្មភាព ឬ ប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ ដូចជាការប្រើប្រាស់ក្នុងព្រំដែនកំណត់ ការបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា និង ឬ ដើម្បីប្រើប្រាស់ដោយផ្ទាល់ធ្វើជាម្ហូបអាហារ ជាចំណីសត្វ ឬ ដើម្បីកែច្នៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការឯកភាពជាមុនពីក្រសួងបរិស្ថាន មុននឹងសុំការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។ សកម្មភាព ឬ ប្រតិបត្តិការណាមួយដែលពាក់ព័ន្ធនឹងសារពាង្គកាយកែច្នៃរស់ ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវអនុវត្តស្របតាមបទដ្ឋានកំណត់ក្នុងនីតិវិធីស្តីពីការវាយតម្លៃហានិភ័យ ដូចបានចែងក្នុងជំពូកទី៤ ហើយនឹងមានចែងលម្អិតដោយប្រកាសរបស់ក្រសួងបរិស្ថាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

មាត្រា ១១៖ ការនាំចូលសារពាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវបានតម្រូវឱ្យមានការវាយតម្លៃហានិភ័យ ព្រមទាំងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។ ម្ចាស់ស្នើត្រូវដាក់ពាក្យទៅក្រសួងបរិស្ថានអំពីគោលបំណងនៃការនាំចូលរបស់ខ្លួន។

មាត្រា២២៖ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលនាំចូល ឬ នាំចេញពីព្រះរាជាណាចក្រកម្ពុជា នូវសារពាង្គកាយកែច្នៃរស់ ក្នុងគោលបំណងណាមួយក៏ដោយ ត្រូវផ្តល់នូវឯកសារភ្ជាប់ជាមួយដោយបញ្ជាក់យ៉ាងច្បាស់លាស់ពីអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់នោះ ពិតជាសារពាង្គកាយកែច្នៃរស់ប្រាកដមែន ព្រមទាំងបញ្ជាក់អំពីលក្ខខណ្ឌតម្រូវការសម្រាប់សុវត្ថិភាពក្នុងការវេចខ្ចប់ ការលើកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការរក្សាទុក។

៣.២.១១. ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨

ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។ ច្បាប់នេះមានគោលដៅ គ្រប់គ្រង និងត្រួតពិនិត្យលើការបង្កាត់ ការបញ្ចេញឱ្យប្រើ ការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញពូជដំណាំ និងការការពារពូជថ្មីនៃដំណាំ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះក៏មានគោលបំណងធានានូវការគ្រប់គ្រង ការលើកទឹកចិត្ត និងការអភិវឌ្ឍពូជដំណាំដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន។

មាត្រា ៤៥ ៖ ពូជដំណាំ ដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ត្រូវតែជាពូជដំណាំមានគុណភាព និងត្រូវឆ្លងកាត់ការធ្វើពិសោធន៍ ឬ ការដាំសាកល្បងដោយអង្គភាពជំនាញ គ្រឹះស្ថានស្រាវជ្រាវ សាធារណៈ ឬ ផ្នែកឯកជនធ្វើសេវាកម្មបច្ចេកទេសពូជដំណាំ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ៥១ ៖ ការនាំចេញ នាំចូលពូជដំណាំ រួមទាំងការសាកល្បង ការសិក្សា និងការពិសោធត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការផ្ទេរសិទ្ធិទៅឱ្យបុគ្គលដទៃនូវលិខិតអនុញ្ញាតនាំចេញ នាំចូលពូជដំណាំ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ៥២ ៖ រូបវន្តបុគ្គល ឬ នីតិបុគ្គលដ ដែលនាំចូលពូជដំណាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម

១- ធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ

២- មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំចេញដោយសមត្ថកិច្ចនៃប្រទេសនាំចេញ

៣- មានលិខិតអនុញ្ញាតឱ្យនាំចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤- ជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យ៉ាងតិច ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ មុនពេលពូជដំណាំមកដល់ច្រកទ្វារនាំចូលនៃព្រំដែនព្រះរាជាណាចក្រកម្ពុជា

៥- បំពេញលក្ខខណ្ឌភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៥៣ ៖ ការនាំចូលពូជដំណាំដែលបង្កគ្រោះថ្នាក់ចូលមកព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់ដាច់ខាត។ បញ្ជីឈ្មោះពូជដំណាំដែលបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣.២.១២. ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ឆ្នាំ២០១២

ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២។ ច្បាប់នេះមានគោលបំណង ៖

- គាំទ្រគោលនយោបាយជំរុញការប្រើប្រាស់សក្តានុពលនៃវិស័យកសិកម្មឱ្យមានប្រសិទ្ធិភាពខ្ពស់ដើម្បីអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ
- ធានាការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ប្រកបដោយប្រសិទ្ធិភាព និងសុវត្ថិភាព ព្រមទាំងមានសង្គតិភាព (Consistent) ជាមួយនឹងបទមាណីយអន្តរជាតិ (International Standard)
- លើកកម្ពស់ការយល់ដឹងជាសាធារណៈ លើការអនុវត្តការតម្រូវបទមាណីយសម្រាប់ថ្នាំកសិកម្ម និងជីកសិកម្ម នៅក្នុងគ្រប់សកម្មភាពពាក់ព័ន្ធនឹងផលិតផលនេះ
- កាត់បន្ថយហានិភ័យដែលបង្កដោយការប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្ម ដើម្បីផលប្រយោជន៍របស់កសិករ និងប្រជាពលរដ្ឋទូទាំងប្រទេស ដោយធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពស្បៀង សុខភាពសាធារណៈ និងនិរន្តរភាពនៃបរិស្ថាន។

មាត្រា ៣ ៖ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រង និងការតម្រូវហមាណីយលើ ៖

- ថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ វត្ថុធាតុដើម ឬ សារធាតុសកម្ម និងសមាសធាតុផ្សេងទៀតនៃថ្នាំកសិកម្ម និងជីកសិកម្មគ្រប់ប្រភេទ ដែលប្រើប្រាស់ជាធាតុចូលនៅក្នុងផលិតកម្មកសិកម្ម។

មាត្រា ៤១ ៖ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្ម ត្រូវមានការយល់ដឹងដូចខាងក្រោម ៖

- ត្រូវជ្រើសរើសប្រភេទថ្នាំកសិកម្មសមស្របសម្រាប់ប្រភេទដំណាំ ឬ ប្រភេទផលិតផល និងប្រភេទសមាសភាពចង្រៃ
- ត្រូវប្រើប្រាស់តែប្រភេទថ្នាំកសិកម្មដែលមិនស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានប្រភពដើមផ្តត់ផ្តង់ចែកចាយស្របតាមច្បាប់នេះ មានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និងមានលេខបញ្ជីការផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅលើសម្បកវេចខ្ចប់
- ត្រូវប្រើប្រាស់ថ្នាំកសិកម្មស្របតាមសេចក្តីណែនាំអំពីការប្រើប្រាស់ និងត្រូវអនុវត្តតាមរយៈពេលបញ្ឈប់ការប្រើប្រាស់មុនពេលប្រមូលផលនៅលើស្លាក់សញ្ញាព័ត៌មាននៃសំបកវេចខ្ចប់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយល់ព្រមលើការចុះបញ្ជី
- ត្រូវយល់ដឹងពីបច្ចេកទេសប្រើប្រាស់ថ្នាំកសិកម្ម និងត្រូវប្រើប្រាស់ឧបករណ៍សុវត្ថិភាពក្នុងពេលធ្វើប្រព្រឹត្តិកម្មលើសមាសភាពចង្រៃ
- ត្រូវយល់ដឹងពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ដើម្បីទប់ស្កាត់ភាពប្រឈមនិងងគ្រោះថ្នាក់ចំពោះខ្លួនឯង អ្នកដទៃ និងបរិស្ថាន។

មាត្រា ៤២ ៖ ក្រុមហ៊ុនថ្នាំកសិកម្ម ឬ ម្ចាស់កសិកម្ម ត្រូវមានករណីកិច្ចចំពោះកម្មករនិយោជិតរបស់ខ្លួនដូចខាងក្រោម ៖

- ផ្តល់ការបណ្តុះបណ្តាលវិធានការសុវត្ថិភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់ថ្នាំកសិកម្ម
- ផ្តល់ឧបករណ៍សុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការថ្នាំកសិកម្មផ្ទាល់

- កំណត់បទដ្ឋានសម្រាប់ឧបករណ៍ប្រើប្រាស់ថ្នាំកសិកម្ម និងឧបករណ៍ការពារសុវត្ថិភាព
- អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំងសុខភាពជាប្រចាំ។

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្មគ្រប់ប្រភេទក្នុងកសិដ្ឋាន មានករណីកិច្ចចូលរួមក្នុងគ្រប់សកម្មភាពអប់រំណែនាំស្តីពីវិធានសុវត្ថិភាពដោយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ៤៣ ៖ ការបោះចោលសំណល់ប្រើប្រាស់ថ្នាំកសិកម្ម និងសម្បកវេចខ្ចប់ថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវអនុវត្តតាមវិធានដូចខាងក្រោម ៖

- មិនត្រូវបោះចោល កប់ ឬ ដុតបំផ្លាញសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម នៅទីកន្លែងដែល គ្មានការអនុញ្ញាតពីអង្គភាពកសិកម្ម ឬ អាជ្ញាធរមានសមត្ថកិច្ច
- មិនត្រូវប្រើប្រាស់ឡើងវិញនូវសម្បកវេចខ្ចប់ថ្នាំកសិកម្ម ដើម្បីវេចខ្ចប់ផលិតផលដែលមិនមែនជាថ្នាំកសិកម្ម ជាពិសេសចំណីអាហារ ឬ ចំណីសត្វ។

គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះចោលសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

មាត្រា ៤៤ ៖ ប្រជាពលរដ្ឋគ្រប់រូបដែលបានឃើញ ឬ បានដឹង មានករណីយកិច្ចផ្តល់ព័ត៌មានដល់អង្គភាពកសិកម្មមូលដ្ឋាន ឬ អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត អំពីករណីផ្តត់ផ្តង់ចែកចាយ ប្រើប្រាស់ ឬ បោះចោលសំណល់ថ្នាំកសិកម្មទាំងឡាយណាដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

មាត្រា ៤៥ ៖ រូបវន្តបុគ្គល ឬ នីតិបុគ្គលើដែលប្រើប្រាស់ថ្នាំកសិកម្ម ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព មនុស្ស សត្វ ខូចខាតបរិស្ថាន ឬ ទ្រព្យសម្បត្តិសាធារណៈ ត្រូវជួសជុលការខូចខាត ឬ ត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

មាត្រា ៤៩ ៖ ត្រូវហាមឃាត់ចំពោះការប្រើប្រាសថ្នាំកសិកម្មគ្រប់ប្រភេទដូចខាងក្រោម ៖

១- ការប្រើប្រាស់ថ្នាំកសិកម្ម ដែលស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីកម្ចាត់សមាសភាពចង្រៃគ្រប់ប្រភេទ។

៣- ការប្រើប្រាស់ថ្នាំកសិកម្ម ឬ ការធ្វើសេវាកម្មដោយប្រើថ្នាំកសិកម្មប្រភេទនិយ័តករការលូតលាស់ ឬ ប្រភេទជំរុញការលូតលាស់រុក្ខជាតិ ឬ ដំណាំ ខុសប្រក្រតីលើសពៅកម្រិតប្រើប្រាស់ ឬ លាយចម្រុះជាមួយនិងសារធាតុគីមីគ្រោះថ្នាក់ដែលហាមឃាត់ ឬ លាយជាមួយនិងសារធាតុគីមីផ្សេងទៀតដោយផ្ទុយនិងបទដ្ឋានបច្ចេកទេស ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

មាត្រា ៥១ ៖ ត្រូវហាមឃាត់ចំពោះការនាំចូលសំណល់ថ្នាំកសិកម្ម ឬ សម្បកវេចខ្ចប់ថ្នាំកសិកម្ម ដែលប្រើរួច ឬ ថ្នាំកសិកម្មចាស់ ផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ និងអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ។ ត្រូវហាមឃាត់ចំពោះការបោះចោល ការកប់ចោល ការដុតចោល ការចាក់ចូល ឬ ការបង្ហូរចូលដោយចេតនានូវសំណល់ថ្នាំកសិកម្ម សំបក វេចខ្ចប់ថ្នាំកសិកម្ម ឬ ថ្នាំកសិកម្មចាស់នៅក្នុងប្រភពទឹក ឬ ក្នុងមជ្ឈដ្ឋានផ្សេងទៀតផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា ៦៦ ៖ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលនាំចូលដីកសិកម្ម ក្នុងគោលបំណងប្រើប្រាស់ចុងក្រោយសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនក្នុងកសិដ្ឋានគ្រប់ប្រភេទ ទោះជាឯកជន ឬ រដ្ឋ និងសម្រាប់តម្រូវការសាធារណៈជាក់លាក់ ឬ សម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មផ្សេងទៀត ត្រូវស្នើសុំលិខិតអនុញ្ញាតនាំចូលនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបញ្ជាក់អំពីប្រភេទដីកសិកម្ម គោលបំណងប្រើប្រាស់ និងបរិមាណសមស្របដែលត្រូវស្នើសុំនាំចូល។

៣.២.១៣. ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ២០០៤

មាត្រា១ ៖ ច្បាប់ស្តីពីសារពើពន្ធលើប្រាក់ចំណេញបានចូលជាធរមានក្នុងឆ្នាំ១៩៩៤ ដោយព្រះរាជក្រមលេខ ០២ ស.ន ឆ្នាំ១៩៩៣ និងត្រូវបានធ្វើវិសោធនកម្មពីរលើក (លើកទី១ក្នុងឆ្នាំ១៩៩៤ និងលើកទី២ ក្នុងឆ្នាំ ១៩៩៥) ហើយបានប្រកាសឲ្យចូលជាធរមានដោយព្រះរាជក្រមលេខ ០៨ ន.ស និង ១១ន.ស៩៤ ក្នុងឆ្នាំ ១៩៩៤ និង១៩៩៥។

មាត្រា២ ៖ ពន្ធលើប្រាក់ចំណេញ គឺជាបំណុលនៃប្រាក់ចំណូលរបស់រូបវន្តបុគ្គលជនជាតិកម្ពុជាដែលរកចំណូលបាននៅលើទឹកដីកម្ពុជា និងទឹកដីបរទេស និងនីតិបុគ្គលដែលមិនមែនជនជាតិកម្ពុជាដែលរកចំណូលបានលើទឹកដីកម្ពុជា។

មាត្រា៣ ៖ គោលបំណងនៃច្បាប់សារពើពន្ធ

១. ពាក្យថា អ្នកជាប់ពន្ធ សំដៅទៅលើ ៖

ក. រូបវន្តបុគ្គលទាំងឡាយណាដែលរស់នៅលើទឹកដីកម្ពុជា ឬ ក៏រស់នៅលើទឹកដីកម្ពុជាចាប់ពី១៨២ ថ្ងៃក្នុងមួយឆ្នាំ។

ខ. នីតិបុគ្គលទាំងឡាយណា ឬ អង្គភាពទាំងឡាយណានៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ក៏នីតិបុគ្គលទាំងឡាយណាដែលធ្វើអាជីវកម្មនៅលើទឹកដីកម្ពុជា។

២. ពាក្យថា មិនមែនជនជាតិកម្ពុជា គឺសំដៅទៅលើជនទាំងឡាយណាដែលមានប្រភពចំណូលមកពីកម្ពុជា។

៣. នីតិបុគ្គលគឺជាក្រុមហ៊ុន ឬ អង្គភាពទាំងឡាយណាដែលកំពុងប្រកបអាជីវកម្មនៅលើទឹកដីកម្ពុជា ទោះជាចុះបញ្ជី ឬ មិនចុះបញ្ជីក្តី ទួទួលស្គាល់ ឬ មិនទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច។ ពាក្យនេះរាប់បញ្ចូលទាំងរាល់ស្ថាប័នរដ្ឋ អង្គភាពសាសនា និងអង្គការមិនមែនរដ្ឋាភិបាល [...]

៤. ពាក្យ ការបង្កើតក្រុមហ៊ុនជាអចិន្ត្រៃយ៍ គឺសំដៅទៅលើទីតាំងជាក់លាក់មួយនៃអាជីវកម្មនៅក្នុងទឹកដីកម្ពុជា ជាសាខាក្រុមហ៊ុនបរទេសនៅក្នុងទឹកដីកម្ពុជា ដែលកាន់កាប់/គ្រប់គ្រងដោយជនជាតិបរទេស។ ពាក្យនេះក៏រួមបញ្ចូលទាំងបណ្តាញ ឬ សហគមន៍ទាំងឡាយណាដែលជនបរទេសចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅលើទឹកដីកម្ពុជា។

មាត្រា៧ ៖ ប្រាក់ចំណេញដែលអាចយកពន្ធបាន ជាពន្ធដែលទទួលបានពីលទ្ធផលនៃរាល់ប្រតិបត្តិការរបស់សហគ្រាស រាប់បញ្ចូលទាំងចំណេញមូលធនពីការប្រាក់ទ្រព្យសកម្ម ឬ អសកម្ម នៅក្នុងពេលដំណើរការអាជីវកម្ម ឬ ពេលបិទអាជីវកម្ម ក៏ដូចជាចំណូលពីហិរញ្ញវត្ថុ ឬ ការវិនិយោគប្រតិបត្តិនានា និងការប្រាក់ ការជួល និងចំណូលពីសិទ្ធិកម្មសិទ្ធិបញ្ញា។

៣.២.១៤. ច្បាប់ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យ ប្រជុំដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៤ នីតិកាលទី២ ហើយក្រមរដ្ឋប្បវេណីនេះពាក់ព័ន្ធនឹងគម្រោងរួមមាន៖

មាត្រា៤៖ ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបានបញ្ញត្តទុក មិនអាចទទួលស្គាល់អានុភាព នៃការប្រើសិទ្ធិនោះឡើយ។

មាត្រា៧៖ ការកម្រិតក្នុងការទទួលសិទ្ធិចំពោះជនបរទេស

ជនជាតិបរទេស មិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។

មាត្រា១១៖ សិទ្ធិទាមទារឱ្យបញ្ឈប់

ប្រសិនបើមានការបារម្ភថា នឹងអាចមានការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់ ឬមានការបារម្ភថាការរំលោភសិទ្ធិបុគ្គលដែលបានកើតឡើងហើយនោះ នឹងអាចបន្ត ឬនឹងអាចកើតឡើងទៀតដោយខុសច្បាប់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឱ្យបញ្ឈបនូវការរំលោភនោះបាន។

មាត្រា៨២៖ ការបង្កើត និងលក្ខន្តិក:

១- ដើម្បីបង្កើតនីតិបុគ្គសាជីវកម្មទទួលខុសត្រូវមានកម្រិត បុគ្គលដែលមានបំណងធ្វើជាសមាជិកត្រូវសហការគ្នាបង្កើតលក្ខន្តិក:ហើយចុះហត្ថលេខារៀងៗខ្លួន។

២- លក្ខន្តិក:ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវគ្រប់ចំណុចដូចខាងក្រោម:

ក- គោលបំណង។

ខ- នាមការណ៍។

គ- ទីតាំងនៃទីស្នាក់ការកណ្តាល។

ឃ- បញ្ជាត្តិស្តីពីចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋានដែលត្រូវជានាក្នុងនាមជានីតិបុគ្គល និងទ្រព្យធនសកម្ម។ ក្នុងករណីដែលមានវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវសរសេរនូវឈ្មោះ ឬនាមករណ៍របស់បុគ្គលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ឈ្មោះ និងតម្លៃនៃទ្រព្យសម្បត្តិនោះ ឬក្នុងករណីដែលបុគ្គលណាម្នាក់បានសន្យា ថានឹងធ្វើអនុប្បទានទ្រព្យសម្បត្តិណាមួយក្រោយពីការបង្កើតនីតិបុគ្គល ត្រូវសរសេរនូវតម្លៃនៃទ្រព្យសម្បត្តិនោះ និងឈ្មោះ ឬនាមករណ៍របស់អនុប្បទាយី ឬត្រូវសរសេរនូវចំនួនប្រាក់នៃសោហ៊ុយដែលចំណាយ ក្នុងការបង្កើនីតិបុគ្គល ហើយដែលនីតិបុគ្គលត្រូវទទួលបន្ទុក។

ង- ឆ្នាំអនុវត្តកិច្ចការ។

ច- ចំណុចស្តីពីអភិបាល អ្នកត្រួតពិនិត្យ និងអ្នកមានតួនាទីផ្សេងទៀត។

ឆ- បញ្ញត្តិស្តីពីការទទួល និងការបាត់បង់សមាជិកភាព។

ជ- ចំណុចស្តីពីគណនេយ្យ។

ឈ- ចំណុចស្តីពីការរំលាយ។

ញ- ចំណុចស្តីពីការកែប្រែលក្ខន្តិក:។

ដ- វិធីផ្សព្វផ្សាយជាសាធារណៈ។

៣- លក្ខន្តិក:ពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការីទេ។

៤- លក្ខន្តិក:ត្រូវរក្សាទុកនៅពីស្នាក់ការកណ្តាល់ និងទីស្នាក់ការសាខា។

មាត្រា១៣៩៖ បានចែងថា (១) កម្មសិទ្ធិដីត្រូវមានអានុភាពទាំងផ្នែកលើដី និងផ្នែកក្រោមដីនៅក្នុងទំហំ នៃការកម្រិតដែលច្បាប់ និងបទដ្ឋានគតិយុត្តបានកំណត់ ហើយក្នុងទំហំដែលមានផលប៉ះពាល់ប្រយោជន៍សម្រាប់កម្មសិទ្ធិករ (២) កម្មសិទ្ធករនៃដីមិនអាចប្រើ ដីរបស់ខ្លួនក្នុងគោលបំណង់ព្យាបាទអ្នកដទៃ ឬរំខានដល់ដីវិភាពរស់នៅរបស់ អ្នកដទៃបានឡើយ។

មាត្រា១៤០៖ ក្នុងករណីដែលអំពើរំខានដល់ដីវិភាពរស់នៅដែលមកពីឧស្ម័ន ចំហាយទឹក ក្លិន ផ្សែង ម្រែង ភ្លើង កម្តៅ សំឡេង រំញ័រដោអាទិ៍ ដែលកើតពីដីរបស់អ្នកដទៃ ស្ថិតក្នុងទំហំនៃការប្រើប្រាស់ជាធម្មតា ហើយបទដ្ឋានគតិយុត្ត មិនបានហាមឃាត់ទេ កម្មសិទ្ធករនៃដីមិនអាចទាមទារឱ្យអ្នកដទៃបញ្ឈប់នូវអំពើដែលធ្វើឱ្យមានឥទ្ធិពលដល់ដីខ្លួនបាន ឡើយ។ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ កម្មសិទ្ធិករនៃដីដែលទទួលឥទ្ធិពលអាក្រក់ដ៏ធ្ងន់ ធ្ងរ តាមភាពជាក់ស្តែង អាចទាមទារឱ្យអ្នកដែលរំខានដល់ដីវិភាពរស់នៅនោះសងសំណងសមរម្យបាន។ ម្យ៉ាងទៀត បញ្ញត្តិមិនរារាំងកម្មសិទ្ធិករដី ក្នុងការទាមទារសំណងនៃការខូចខាតដោយផ្អែកលើអណាពើអនីត្យានុកូឡើយ។

មាត្រា១៤៣៖ សិទ្ធប្រើដីដែលជាប់គ្នា

កម្មសិទ្ធិករនៃដីអាចទាមទារប្រើដីដែលជាប់គ្នាបាន ក្នុងទំហំចាំបាច់ដើម្បីធ្វើរបង ឬសង់សំណង់ ឬជួសជុលរបស់ទាំងពីរនេះ នៅព្រំប្រទល់ដី ឬនៅក្បែរព្រំប្រទល់នោះ។ ប្រសិនបើអ្នកជិតខាងទទួលការខូចខាត ដោយសារការសាងសង់ ឬជួសជុលនេះកម្មសិទ្ធិករនៃដីត្រូវបង់ប្រាក់សំណង។

មាត្រា១៤៨៖ សិទ្ធិធ្វើផ្លូវទឹកដើម្បីស្រោចស្រព

កម្មសិទ្ធករដែលចង់ឱ្យទឹកដែលខ្លួនមានសិទ្ធិប្រើប្រាស់ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើ និងរក្សាទុកនូវផ្លូវទឹកឆ្លងកាត់ដីដែលស្ថិតនៅចន្លោះប្រភពទឹកដីរបស់ខ្លួនបាន ដោយបង់ប្រាក់សំណងនៃការខូចខាតដល់កម្មសិទ្ធិករនៃដីដែលត្រូវឆ្លងកាត់នោះ។

មាត្រា១៥៤៖ ដើមឈើនៅជិតព្រំដី

កម្មសិទ្ធិករនៃដីមិនអាចដាំដើមឈើ គុម្ពោត ឬចុល្លព្រឹក្សដែលមានកម្ពស់លើសពី២(ពីរ)ម៉ែត្រក្នុងចម្ងាយ២(ពីរ)ម៉ែត្រ ពីព្រំប្រទល់ដីអ្នកជិតខាងបានឡើយ។ ក្នុងករណីដែរធ្វើផ្ទុយពីបញ្ញត្តិនេះ កម្មសិទ្ធិករនេះមានករណីយកិច្ចដក់ចេញ តាមការទាមទាររបស់កម្មសិទ្ធិករនៃដីជិតខាង។

មាត្រា១៨៤៖ កម្មសិទ្ធនៃកោះ

ប្រសិនបើទន្លេ ស្ទឹង ឬព្រែកបានបង្កើតផ្លូវទឹកថ្មី ហើយកាត់ផ្តាច់ដីរបស់កម្មសិទ្ធិករនៅជាប់មាត់ច្រាំង ហើយបង្កើតជាកោះ ទោះបីជាកោះនោះដុះនៅក្នុងទន្លេ ស្ទឹង ឬព្រែកដែលនាវា ឬក្បូនអាចចេញចូលបានបណ្តែតបានក៏ដោយ ក៏កម្មសិទ្ធិករនៅជាប់មាត់ច្រាំង មិនបាត់បងនូវកម្មសិទ្ធិនៃដីនោះឡើយ។

៣.២.១៥. ច្បាប់ស្តីពីផ្លូវថ្នល់ ឆ្នាំ២០១៤

ច្បាប់ស្តីពីផ្លូវថ្នល់ត្រូវបានប្រកាសអោយប្រើជាផ្លូវការនៅថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៤។ ខ្លឹមសារសំខាន់ៗមានដូចតទៅ៖

<u>មាត្រា១៖</u> ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងធានាសុវត្ថិភាពចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

<u>មាត្រា២៖</u> ច្បាប់នេះមានគោលដៅដូចតទៅ៖

- ការពារទ្រព្យសម្បត្តិសាធារណៈ ការពារ និងលើកកម្ពស់ផ្លូវថ្នល់ រក្សាសណ្តាប់ធ្នាប់ សម្រួលការធ្វើដំណើរនិងការដឹកជញ្ជូនតាមផ្លូវគោក
- កំណត់គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍសម្រាប់សាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ព្រមទាំងកំណត់វិធាន និងបទប្បញ្ញត្តិបច្ចេកទេស
- ជំរុញ និងលើកទឹកចិត្តអោយវិស័យឯកជនចូលរួមក្នុងការសាងសង់ ការជួសជុល ការថែទាំ និងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- លើកទឹកចិត្តចំពោះការសិក្សាស្រាវជ្រាវបច្ចេកទេស និងការផ្ទេរបច្ចេកវិជ្ជាថ្មីៗ ដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- អភិវឌ្ឍធនធានមនុស្សក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

<u>មាត្រា២៥៖</u> អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូនលើផ្លូវថ្នល់ ត្រូវអនុវត្តតាមការកំណត់អំពីការផ្ទុកទម្ងន់ដូចចែងក្នុងមាត្រានៃច្បាប់នេះ និងត្រូវចូលរួមត្រួតពិនិត្យថ្លឹងទម្ងន់នៅស្ថានីយថ្លឹងយានយន្តដែលស្ថិតនៅតាមបណ្តោយថ្នល់នីមួយៗ ព្រមទាំងគោរពតាមបទដ្ឋានបច្ចេកទេសទំហំផ្លូវកម្រិតកំណត់។

បទដ្ឋានបច្ចេកទេសទំហំផ្លូវកម្រិតកំណត់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន និងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

ការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការដឹកជញ្ជូនត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសកម្រិតកំណត់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា២៦៖</u> ទម្ងន់ដឹកជញ្ជូនអតិបរមាលើបណ្តាញផ្លូវថ្នល់មានដូចតទៅ៖

១. លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវរាជធានី ផ្លូវក្រុង ផ្លូវទីប្រជុំជននានាក្នុងខេត្ត និងផ្លូវជនបទ ត្រូវអនុវត្តដូចខាងក្រោម៖

ក. ការកំរិតទម្ងន់អតិបរមាសង្កត់លើភ្លៅរថយន្ត រ៉ឺមក ឬសឺមីរ៉ឺមកត្រូវកំណត់ត្រឹម៖

- ៦តោនសំរាប់ភ្លៅ ទោលដែលមានកង់២ស្ថិតនៅផ្នែកចង្កូតរថយន្ត
- ១១តោនសម្រាប់ភ្លៅដែលមានកង់៤ស្ថិតនៅផ្នែកចង្កូតរថយន្ត
- ១០តោនសម្រាប់ភ្លៅទោលដែលមានកង់៤
- ១៩តោនសម្រាបភ្លៅភ្លោះដែលមានកង់៨
- ២៤តោនសម្រាប់ភ្លៅបីជិតគ្នាដែលមានកង់១២

ខ. ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្ត ត្រូវកំណត់ត្រឹម៖

- ១៦តោនសម្រាប់រថយន្តដែលមានភ្លៅ២គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់២ និងភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់៤